សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ចំណាត់ការលើបទឃាតកម្មដែលប្រព្រឹត្តដោយអនីតិជន នៅដំណាក់កាលសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

តាក់តែងឡើងដោយ

និស្សិតឈ្មោះ លោក **យិន មុនីរិទ្ធ**

លោក **យ៉ាន វាសនា**

សាស្ត្រាចារ្យណែនាំ

លោក **រុន ពណ្ណារិទ្ធ**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

**ជំនាន់ទី ១៧**

ឆ្នាំចូលរៀន ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី ១៧ ក្រុម L4A5 នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៣-២០១៧ ទាំងពីររូប រួមមានខ្ញុំបាទឈ្មោះ **យ៉ាន វាសនា** និងខ្ញុំបាទឈ្មោះ **យិន មុនីរិទ្ធ** ។

**យើងខ្ញុំសូមគោរពប្រតិបត្តិលំអោនកាយវាចាចិត្ត ដើម្បីសម្តែងនូវនាពកតញ្ញូដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ ៖**

លោក **ឪពុក** និងអ្នក **ម្តាយ** ដែលអ្នកមានគុណទាំងពីរបានផ្តល់កំណើត និងជីវិតដែលពោរពេញទៅដោយអត្ថន័យដល់រូបកូន។ លើសពីនេះក្រៅពីផ្តល់ជីវិត ដល់រូបកូន លោកឪពុក និងអ្នកម្តាយបានលះបង់ពេលវេលា កម្លាំងកាយ និងកម្លាំងចិត្តក្នុងការយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅ ភាពកក់ក្តៅ និងផ្តល់នូវដំបូន្មានល្អៗ ដល់រូបកូនដើម្បីជាទុន ក្នុងការរស់នៅក្នុងសង្គម ក៏ដូចជាការសិក្សា។ ជាពិសេសលោកទាំងពីរបានជម្នះនូវរាល់បញ្ហាស្មុគស្មាញយ៉ាងច្រើន ដើម្បីទំនុកបម្រុងដល់កូនក្នុងការសិក្សា តាំងពីថ្នាក់បឋមសិក្សា រហូតដល់បានសិក្សានៅថ្នាក់សាកលវិទ្យាល័យជំនាញនីតិសាស្ត្រនេះថែមទៀតផង។ តាមរយៈការខិតខំអស់ពីកម្លាំងកាយចិត្តរបស់លោកទាំងពីរនេះហើយ បានធ្វើអោយរូបកូនមានមោទនភាព គោរពកោតសរសើរចំពោះទង្វើដ៏ល្អប្រពៃយកមកធ្វើជាគម្រូ និងមិនអាចបំភ្លេចបានឡើយនូវរាល់ពាក្យសម្តីទូន្មានល្អៗ ជាពិសេសគុណូបការៈដ៏សែនធំរកអ្វីប្រៀបប្រដូចពុំបាន កូនមានថ្ងៃនេះក៏ព្រោះព្រហ្មវិហារធម៌របស់លោកឪពុក និងអ្នកម្តាយ កូនចង់ចាំជានិច្ចរហូតដល់ថ្ងៃអវសាន ។

- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងសាស្ត្រាចារ្យគ្រប់រូប ដែលបានចំណាយកម្លាំងកាយ កម្លាំងចិត្តក្នុងការយកចិត្តទុកដាក់ និងបង្កលក្ខណៈងាយស្រួលក្នុងការផ្តល់ចំណេះដឹង ព្រមជាមួយនូវបទពិសោធន៍ល្អៗដល់រូបខ្ញុំបាទទាំងពីររហូតដល់រូបខ្ញុំទាំងពីរទទួលបាននូវឱកាសក្នុងការធ្វើសារណាបញ្ចប់ការសិក្សា ។
- លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** នឹងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ដែល លោកទាំងពីរបានចំណាយកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការណែនាំ ផ្តល់នូវគំនិតយោបល់ ដំបូន្មាន វិធីសាស្ត្រល្អៗដែលពាក់ពន្ធ័និងប្រធានបទ និងកែលម្អទៅលើចំណុចខ្វះខាតរបស់ខ្ញុំបាទទាំងពីរ តាំងពីដើមរហូតដល់ខ្ញុំបាទទាំងពីរបានចងក្រងស្នាដៃដែលជាសារណានេះឡើងបាន។ ហើយស្នាដៃដែលកើតឡើងពីការខិតខំស្រាវជ្រាវមួយនេះពិតជាមិនមានអត្ថិភាពឡើយ ប្រសិនបើគ្មានការជួយជ្រោមជ្រៀង និងការណែនាំពីសំណាក់សាស្ត្រាចារ្យទាំងពីរ ។

- លោកគ្រូ អ្នកគ្រូ និងព្រឹទ្ធាចារ្យ ដែលបានប្រៀនប្រដៅ និងបណ្តុះបណ្តាលតាំងពីថ្នាក់បឋមសិក្សារហូតឈានដល់បញ្ចប់ការសិក្សាថ្នាក់ចំណេះដឹងទូទៅ ដែលជាស្ពានចម្លងយ៉ាងសំខាន់រហូតមកដល់សិក្សាថ្នាក់បរិញ្ញាបត្រនេះ ។

- លោក លោកស្រីបណ្ណារក្ស រៀមច្បង និងមិត្តនិស្សិតដទៃទៀត ដែលបានផ្តល់ភាពងាយស្រួល និងគាំទ្រដោយផ្តល់ជាគំនិតយោបល់ ក្នុងការតាក់តែងសារណានេះឡើងទៅបាន និងមានភាពប្រសើរឡើង ។

ខ្ញុំបាទទាំងពីរសូមថ្លែងអំណរគុណយ៉ាងក្រៃលែងជាថ្មីម្តងទៀត និងសូមលើកម្រាមទាំងដប់បួងសួងដល់វត្ថុសក្តិសិទ្ធិទាំងពួង សូមប្រសិទ្ធិពរជ័យសិរីសួស្តីកើតមានដល់អ្នកមានគុណទាំងទ្វេព្រមទាំងអ្នកដែលជួយទំនុកបម្រុងទាំងអស់ ជាពិសេសខ្ញុំបាទទាំងពីរសូមបួងសួងប្រសិទ្ធិពរជ័យ និងធ្វើសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំខ ស៊ីណាត** ជាថ្មីម្តងទៀត ដែលលោកទាំងពីរបានផ្តល់ឱកាសដល់ខ្ញុំបាទទាំងពីរអោយទទួលបាននូវការណែនាំ និងគំនិតយោបល់សំខាន់ៗជាច្រើនក្នុងការធ្វើសារណានេះរហូតបានសម្រេច ហេតុដូច្នេះសូមលោកគ្រូ នឹងអ្នកគ្រូ ទទួលនូវការដឹងគុណពីរូបខ្ញុំបាទទាំងពីរនាក់ និងសូមឲ្យលោកគ្រូ និងអ្នកគ្រូទាំងពីរ ជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

អស់រយៈពេល ៣(បី)ឆ្នាំ កន្លះ ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ពួកយើងបានសិក្សានូវមុខវិជ្ជាជាច្រើន និងទទួលបានចំណេះដឹងយ៉ាងក្រៃលែងពាក់ព័ន្ធនឹងវិស័យច្បាប់នៅប្រទេសកម្ពុជា។ ដោយសារ ចំណេះដឹង ការរៀនសូត្រកន្លងមក បូករួមទាំងការចាប់អារម្មណ៍ចង់ស្វែងយល់បន្ថែមជុំវិញប្រធានបទ ជាកត្តាមួយជុំរុញឱ្យពួកខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទក្រោមចំណងជើងថា "**ចំណាត់ការលើបទឃាតកម្មដែលប្រព្រឹត្តដោយអនីតិជននៅសាលាដំបូង**"។ យើងឃើញហើយថា អនីតិជនជាជនមួយដែលត្រូវបានគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ យកចិត្តទុកដាក់ ការពារសិទ្ធិរបស់ជននោះ។ អាស្រ័យហេតុនេះ ទើបឃើញមាន ច្បាប់អន្តរជាតិ រួមមាន អនុសញ្ញា កតិសញ្ញា ផ្សេងៗ និងច្បាប់ជាតិ ក្នុងនោះមាន រដ្ឋធម្មនុញ្ញ ក្រមទាំងបួនរបស់ព្រះរាជាណាចក្រកម្ពុជា (ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ) រហូតដល់មានការបង្កើតនូវច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលទើបនឹងប្រកាសឱ្យប្រើនាឆ្នាំ២០១៦ ថ្មីៗនេះ ដោយច្បាប់ទាំងអស់នោះត្រូវបានបង្កើតឡើង ដើម្បីធានាការការពារសិទ្ធិអនីតិជនគ្រប់រូប ក៏ដូចជាចង្អុលបង្ហាញអំពីនីតិវិធីដាច់ឡែកសម្រាប់អនីតិជន នៅពេលដែលជននោះបានប្រព្រឹត្តបទល្មើសរួច។

ការសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទខាងលើនេះ គឺមានគោលបំណងក្នុងការបង្ហាញអំពីនីតិវិធីដែលត្រូវអនុវត្តតាមដំណាក់កាលនីមួយៗ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទឃាតកម្មដែលជាបទឧក្រិដ្ឋ។ តាមរយៈនីតិវិធីនេះ គឺអាចជួយដល់អ្នកអាន ឬនិស្សិតៗដែលគាត់ចង់ស្វែងយល់លម្អិតថា នៅពេលដែលអនីតិជនបានធ្វើឃាតអ្នកណាមួយ តើមន្ត្រីសមត្ថកិច្ចណាខ្លះមានសមត្ថកិច្ចទៅលើករណីនោះ? តើអនីតិជនរូបនោះត្រូវបានគេធ្វើចំណាត់ការយ៉ាងដូចម្តេចខ្លះ? តើអនីតិជននោះទទួលបានសិទ្ធិមូលដ្ឋានអ្វីខ្លះ? តើអនីតិជនរូបនោះប្រឈមមុខការផ្តន្ទាទោសយ៉ាងដូចម្តេច? បន្ថែមពីនេះ សម្រាប់អ្នកអានដែលគាត់បានយល់ដឹងពីនីតិវិធីអនុវត្តលើបទឃាតកម្មរបស់នីតិជន សារណានេះអាចជួយបង្ហាញគាត់ពីជ្រុងមួយផ្នែកទៀតនៃ នីតិវិធីសម្រាប់អនីតិជន ដូច្នេះសារណានេះអាចជួយដល់គាត់ក្នុងការប្រៀបធៀប និងអាចរកឃើញ លក្ខណៈខុសគ្នារវាងចំណាត់ការសម្រាប់នីតិជន និងចំណាត់ការសម្រាប់អនីតិជននៅពេលជនទាំងនោះបាន ប្រព្រឹត្តបទឃាតកម្ម។ ម៉្យាងវិញទៀត ដើម្បីជាការជួយសម្រួលដល់ការស្វែងយល់អំពី ចំណាត់ការនៅតាមដំណាក់កាលនីមួយៗនោះ ពួកយើងខ្ញុំក៏មានដាក់បញ្ចូលនូវករណីសិក្សាជាឧទាហរណ៍ បន្ថែមពីលើទ្រឹស្តីដែលយើងបានបង្ហាញ។ ដូច្នេះ វាធ្វើឱ្យអ្នកអានអាចយល់ពី ភាពស៊ីចង្វាក់រវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅក្នុងសង្គម ព្រោះថារាល់ករណីសិក្សាទាំងនោះ គឺជាបទល្មើសដែលកើត

មានឡើងជាក់ស្តែងនៅក្នុងប្រទេសកម្ពុជារបស់យើង ដែលពួកយើងប្រមូលបានតាមរយៈសារព័ត៌មានផ្សេងៗ ដោយយើងធ្វើការកែប្រែនូវឈ្មោះបុគ្គលទាំងអស់នៅក្នុងករណីនោះ ជំនួសដោយការតាងជាអក្សរ។

ចំពោះសារណាមួយនេះ ពួកយើងបានខិតខំពិនិត្យ កែសម្រួលអត្ថបទ ខ្លឹមសារ យ៉ាងយកចិត្តទុកដាក់។ យ៉ាងណាមិញ កំហុសឆ្គងតែងតែអាចកើតមានឡើងជៀសមិនផុតឡើយ អាស្រ័យហេតុនេះ ពួកយើងខ្ញុំសូមធ្វើការអភ័យទោសជាមុន រាល់កំហុសឆ្គងដោយអចេតនានា ទាំងកំហុសលើពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លាប្រយោគខ្វះខាត ដែលបានប្រើនៅក្នុងអត្ថបទនេះ។

ពួកយើងទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបង ប្អូន មិត្តអ្នកអានទាំងអស់ដែលបានចំណាយពេលអានអត្ថបទសារណាមួយនេះសម្រាប់ជាចំណេះដឹងមួយបន្ថែម។ ពួកយើងខ្ញុំរង់ចាំទទួលរាល់ការរិះគន់ក្នុងន័យស្ថាបនាពីប្រិយមិត្តអ្នកអានដោយក្តីសោមនស្សរីករាយ ដើម្បីកែរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងឱ្យបានកាន់ប្រសើរឡើងនាពេលអនាគត។

ខ្ញុំសង្ឃឹមថា សារណាមួយនេះផ្តល់អត្ថប្រយោជន៍ និងជាជំនួយចំណេះដឹងបន្ថែមដល់អ្នកស្រាវជ្រាវ សិស្ស និស្សិត និងអ្នកអានទាំងអស់ ដែលចង់សិក្សាស្វែងយល់អំពីចំណាត់ការទៅលើបទឃាតកម្មដែលប្រព្រឹត្តដោយអនីតិជន។

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១ : ការស៊ើបអង្កេតលើបទឃាតកម្មដែលប្រព្រឹត្តដោយអនីតិជន**

**ផ្នែកទី១ : តួអង្គក្នុងការស៊ើបអង្កេត** ........ ៤

កថាខណ្ឌទី១ : សមាសភាពមន្ត្រីមានសមត្ថកិច្ចក្នុងកិច្ចស៊ើបអង្កេត ........ ៤

កថាខណ្ឌទី២ : វិសាលភាពដែនសមត្ថកិច្ចរបស់មន្ត្រីមានសមត្ថកិច្ចក្នុងកិច្ចស៊ើបអង្កេត ........ ៥

**ផ្នែកទី២ : ការពិនិត្យ វិភាគ និងប្រមូលភស្តុតាងនៅទីកន្លែងកើតហេតុ** ........ ៦

កថាខណ្ឌទី១ : បទល្មើសជាក់ស្តែង ........ ១០

កថាខណ្ឌទី២ : បទល្មើសមិនជាក់ស្តែង ........ ១១

**ផ្នែកទី៣ : ការឆែកឆេរ** ........ ១២

កថាខណ្ឌទី១ : បទល្មើសជាក់ស្តែង ........ ១៣

កថាខណ្ឌទី២ : បទល្មើសមិនជាក់ស្តែង ........ ១៣

**ផ្នែកទី៤ :ការពិនិត្យទៅលើសាកសព** ........ ១៤

កថាខណ្ឌទី១ : ការកំនត់អត្តសញ្ញាណសាកសព ........ ១៥

កថាខណ្ឌទី២ : ការសង្កេតមុខរបួសសាកសព ........ ១៧

**ផ្នែកទី៥ :ការស្តាប់ចម្លើយ** ........ ២០

កថាខណ្ឌទី១ : ការស្តាប់ចម្លើយរបស់ជនសង្ស័យ បុគ្គលពាក់ព័ន្ធ និងបុគ្គលដែលអាចផ្តល់ព័ត៌មានជុំវិញបទល្មើស ........ ២០

កថាខណ្ឌទី២ : សិទ្ធិមូលដ្ឋានដែលអនីតិជនទទួលបាន ........ ២៣

**ផ្នែកទី៦ : ការឃាត់ខ្លួន និងការបញ្ជូនខ្លួនជនសង្ស័យជាអនីតិជន** ........ ២៤

កថាខណ្ឌទី១ : លក្ខខណ្ឌនៃការឃាត់ខ្លួនអនីតិជន ........ ២៤

កថាខណ្ឌទី២ : ការសម្រេចបញ្ជូនខ្លួនជនសង្ស័យ និងសំណុំរឿងទៅព្រះរាជអាជ្ញា ........ ២៥

កថាខណ្ឌទី៣ : ការដោះលែងឲ្យមានសេរីភាព ........ ២៥

**ជំពូកទី ២: ការសម្រេចរបស់អង្គការអយ្យការលើការចោទប្រកាន់បទល្មើស**

**ផ្នែកទី១ : ការតម្កល់រឿងទុកឥតចាត់ការ** ........................ ២៧

កថាខណ្ឌទី១ : លក្ខខណ្ឌនៃការតម្កល់រឿងទុកឥតចាត់ការ ........................ ២៧

កថាខណ្ឌទី២ : ការប្តឹងតវ៉ានឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ...... ២៨

**ផ្នែកទី២ : ការសម្រេចចោទប្រកាន់** ........................ ២៩

កថាខណ្ឌទី១ : ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ........................ ៣០

កថាខណ្ឌទី២ : ការឲ្យដំណឹងអំពីការចោទប្រកាន់ ........................ ៣០

**ជំពូកទី ៣: ការស៊ើបសួរលើបទល្មើសដោយចៅក្រមស៊ើបសួរ**

**ផ្នែកទី១ : កិច្ចចាប់ដំណើរការនៃការស៊ើបសួរ** ........................ ៣២

កថាខណ្ឌទី១ : សមត្ថកិច្ចនៃការស៊ើបសួរ ........................ ៣២

កថាខណ្ឌទី២ : គោលបំណងនៃនីតិវិធីស៊ើបសួរ ........................ ៣២

**ផ្នែកទី២ : ការស្រាវជ្រាវបន្ថែមរបស់ចៅក្រមស៊ើបសួរ** ........................ ៣៣

កថាខណ្ឌទី១ : ការសួរ និងស្តាប់ចម្លើយភាគីដែលពាក់ព័ន្ធក្នុងរឿងក្តី...... ៣៣

កថាខណ្ឌទី២ : ការឆែកឆេរនិងការចាប់យកនូវវត្ថុតាង ........................ ៣៥

កថាខណ្ឌទី៣ : ការធ្វើកោសលវិច័យ ........................ ៣៦

**ផ្នែកទី៣ : ការចេញដីការបស់ចៅក្រមស៊ើបសួរ** ........................ ៣៧

កថាខណ្ឌទី១ : ដីកាបង្គាប់ឲ្យចូលខ្លួន ........................ ៣៨

កថាខណ្ឌទី២ : ដីកាបង្គាប់ឲ្យនាំខ្លួន ........................ ៤០

កថាខណ្ឌទី៣ : ដីកាបង្គាប់ឲ្យចាប់ខ្លួន ........................ ៤២

កថាខណ្ឌទី៤ : ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ........................ ៤៤

**ផ្នែកទី៤ : ការបិទការស៊ើបសួរ** ........................ ៤៧

កថាខណ្ឌទី១ : ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ........................ ៤៩

កថាខណ្ឌទី២ : ដីការសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ........................ ៥០

**ជំពូកទី ៤: ការជំនុំជម្រះលើបទល្មើស**

**ផ្នែកទី១ : ដំណើរការនីតិវិធីជំនុំជម្រះ**............................................................. ៥២
កថាខណ្ឌទី១ : សិទ្ធិពិសេសដែលអនីតិជនទទួលបានក្នុងការជំនុំជម្រះ ... ៥៣
ក. អាទិភាពក្នុងការជំនុំជម្រះ........................................................ ៥៣
ខ. ភាពអសាធារណនៃសវនាការ ................................................ ៥៣
កថាខណ្ឌទី២ : នីតិវិធីជំនុំជម្រះ .......................................................... ៥៤
ក. សមត្ថកិច្ចក្នុងការជំនុំជម្រះ ..................................................... ៥៤
ខ. នីតិវិធីនៃដំណើរការក្នុងពេលសវនាការ.................................... ៥៤
**ផ្នែកទី២ : ការចេញសាលក្រមផ្ដន្ទាទោសលើអនីតិជន**...................................... ៥៨
កថាខណ្ឌទី១ : ទោសដែលត្រូវអនុវត្តលើអនីតិជន................................ ៥៨
កថាខណ្ឌទី២ : ការអនុវត្តទោស .......................................................... ៥៩
**សេចក្ដីសន្និដ្ឋាន និង អនុសាសន៍** ........................................................................ ៦៣
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលប្រកាន់នូវរបបប្រជាធិបតេយ្យ។ យើងឃើញថា ច្បាប់ជាច្រើនត្រូវបានអនុម័ត និងធ្វើវិសោធនកម្មឱ្យមានលក្ខណៈស៊ីជម្រៅ និងលម្អិតជាងមុន ជាការធានាដល់ការការពារសណ្តាប់ធ្នាប់សាធារណៈ និងបង្ការនូវរាល់បទល្មើសនានា។ ទោះជាយ៉ាងណា បទល្មើសនៅតែកើតមានឡើងជាបន្តបន្ទាប់ក្រោមរូបភាព និងលក្ខណៈផ្សេងៗពីគ្នា។ ក្នុងចំណោមបទល្មើសទាំងអស់ បទល្មើសដែលមហាជនទូទៅមានការភ័យខ្លាច និងទាមទារឱ្យមានការផ្តោលទោសឱ្យបានធ្ងន់ធ្ងរនោះ គឺបទឃាតកម្ម។ ដោយហេតុថា បទឃាតកម្ម ជាបទល្មើសមួយដែលប៉ះពាល់ដល់ជីវិតមនុស្សជាតិ និងមានភាពសាហាវឃោរឃៅ ហេតុដូច្នេះហើយទើបបទឃាតកម្ម ត្រូវបានចែងពីនីតិវិធី និងទោសទណ្ឌនៃបទល្មើសនោះយ៉ាងលម្អិត។ ក្រឡេកមកមើលទិដ្ឋភាពសង្គមនាពេលបច្ចុប្បន្ន បទឧក្រិដ្ឋដូចជាបទឃាតកម្មជាដើម ភាគច្រើនគឺនីតិជនជាអ្នកប្រព្រឹត្ត គេកម្រឃើញអនីតិជនប្រព្រឹត្តបទឃាតកម្មនេះណាស់។ ក្នុងន័យនេះបានន័យថា នៅក្នុងប្រទេសកម្ពុជាយើង នៅតែមានអនីតិជនដែលជាជនដែលមានអាយុក្រោម ១៨ឆ្នាំ ប្រព្រឹត្តបទឃាតកម្ម។ នៅពេលករណីនេះបានកើតឡើង នីតិវិធីដែលអនុវត្តលើបទឃាតកម្មដែលប្រព្រឹត្តដោយអនីតិជននោះ គឺជារឿងចាំបាច់មួយ។ ដូច្នេះ ការសរសេរសារណាក្រោមប្រធានបទ **"ចំណាត់ការលើបទឃាតកម្មដែលប្រព្រឹត្តដោយអនីតិជននៅដំណាក់កាលសាលាដំបូង"** ក៏ជាចំណុចមួយដ៏សំខាន់ផងដែរ ក្នុងការបង្ហាញអំពីចំណាត់ការដែលត្រូវអនុវត្ត ក្នុងករណីបទឃាតកម្មនោះប្រព្រឹត្តដោយអនីតិជន។ ចំណាត់ការ គឺជានីតិវិធីដែលត្រូវអនុវត្ត។ បទឃាតកម្ម គឺជាបទល្មើសនៃការសម្លាប់មនុស្ស។ អនីតិជន គឺជាជនដែលមានអាយុក្រោម ១៨ឆ្នាំ។

អាស្រ័យហេតុនេះ មានសំនួរចោទសួរឡើងថា "តើគេត្រូវធ្វើចំណាត់ការយ៉ាងដូចម្តេច នៅពេលដែលអនីតិជនប្រព្រឹត្តបទឃាតកម្ម? តើគេត្រូវយកគោលការណ៍ច្បាប់ណាខ្លះមកអនុវត្ត ហើយអនីតិជនរូបនោះអាចទទួលបានសិទ្ធិអ្វីខ្លះ?

សម្រាប់ចំណាត់ការនេះ គឺឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីនីតិវិធីដែលត្រូវអនុវត្ត នៅពេលបទឃាតកម្មបានកើតឡើង ដែលអនីតិជនត្រូវបានគេសង្ស័យថាបានប្រព្រឹត្តបទល្មើសនោះ។ តាមរយៈស្វែងយល់អំពីចំណាត់ការនេះច្បាស់លាស់ គឺដើម្បីធានាដល់ការអនុវត្តនីតិវិធី និងសិទ្ធិឱ្យបានត្រឹមត្រូវ ព្រោះទោះបីជាអនីតិជនជាអ្នកសម្លាប់ក៏ដោយ ក៏អនីតិជនរូបនោះត្រូវបានការការពារសិទ្ធិមួយចំនួនដែលច្បាប់កំណត់។ ដូច្នេះនៅពេលដែលអនីតិជនណាមួយបានប្រព្រឹត្តបទឃាតកម្ម

ឬជាប់សង្ស័យថាបានប្រព្រឹត្ត នោះចំណាត់ការតាមផ្លូវច្បាប់នឹងកើតមានឡើង ដូចជាការស៊ើបអង្កេត ការស្តាប់ចម្លើយ ជាដើម ដើម្បីរកពីពិរុទ្ធភាពនៃអនីតិជននោះឱ្យបានច្បាស់លាស់ មុនឈានដល់ការចោទប្រកាន់ និងការប្រកាសទោស។ ដូចដែលបានដឹងស្រាប់ហើយថា កាលណាអនីតិជនរងការចោទប្រកាន់ខុស នូវបទល្មើសដែលខ្លួនមិនបានប្រព្រឹត្ត ឬចូលរួមសោះ នោះប្រាកដណាស់ នាំឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់អនាគតរបស់អនីតិជននោះ និងសង្គមផងដែរ ដូចជាប្រវត្តិរូបរបស់អនីតិជនត្រូវបានប្រលាក់ដោយឈ្មោះបទល្មើស ជាហេតុនាំឱ្យមានការប៉ះពាល់ដល់វិស័យការងារនាពេលអនាគតរបស់អនីតិជននោះ និងអាចរងការរើសអើងនានា។ អាស្រ័យហេតុនេះហើយ នីតិវិធីដែលត្រូវអនុវត្តក្នុងករណីបទឃាតកម្មប្រព្រឹត្តដោយអនីតិជន គឺមានភាពចាំបាច់ និងទាមទារឱ្យមានការយកចិត្តទុកដាក់ខ្លាំង ជៀសវាងនូវការមានកំហុសនីតិវិធីកើតមានឡើង។

ក្រោមប្រធានបទសារណាមួយនេះ គឺកំណត់ទំហំត្រឹមព្រំដែននៃសាលាដំបូងរាជធានី-ខេត្តតែប៉ុណ្ណោះ។ ក្នុងន័យនេះ គឺសារណាមួយនេះនឹងធ្វើការផ្តោតតែទៅលើចំណាត់ការចាប់ពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ស៊ើបអង្កេត រហូតដល់អនីតិជនរូបនោះរងការចោទប្រកាន់ពីអង្គការអយ្យការ នឹងឈានដល់ការចេញសាលក្រមប្រកាសទោសរបស់សាលាដំបូងរាជធានី-ខេត្តតែប៉ុណ្ណោះ ដោយយើងពុំពន្លាតនីតិវិធីនេះដល់ដំណាក់កាលសាលាឧទ្ធរណ៍ ឬតុលាការកំពូលនោះទេ។

ប្រាកដណាស់ មានប្រជាពលរដ្ឋមួយចំនួនធំបានយល់អំពីចំណាត់ការទៅលើបទឃាតកម្មដែលប្រព្រឹត្តដោយនីតិជនទោះបីជាមិនបានលម្អិតទៅលើនីតិវិធីក៏ដោយ។ តួយ៉ាងត្រង់ចំណុចនេះក៏មានប្រជាពលរដ្ឋមួយចំនួនមានការខ្វះចន្លោះ ឬមានលក្ខណៈស្រពិចស្រពិលចំពោះចំណាត់ការក្នុងករណីជនល្មើសនោះជាអនីតិជនវិញម្តង។ ហេតុដូច្នេះ តាមរយៈសារណាមួយនេះនឹងជួយបំពេញបន្ថែមនូវភាពខ្វះចន្លោះ និងលក្ខណៈស្រពិចស្រពិលទាំងនោះ ដោយពួកខ្ញុំធ្វើការស្រាវជ្រាវរាល់ឯកសារជាតិទាំងឡាយដែលពាក់ព័ន្ធទៅនឹងចំណាត់ការនេះ ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ ជាពិសេសគឺច្បាប់ស្តីពីយុត្តិធម៌នីតិជន ឆ្នាំ២០១៦ ដែលទើបនឹងចូលជាធរមានថ្មីៗនេះ នឹងសៀវភៅមួយចំនួនដែលត្រូវបានចងក្រងដោយអ្នកជំនាញ។ ផ្សារភ្ជាប់នឹងទ្រឹស្តីច្បាប់ទាំងអស់នេះ ពួកខ្ញុំក៏បានបញ្ចូលនូវករណីសិក្សាមួយចំនួនដែលបានកើតឡើងជាក់ស្តែងនៅក្នុងសង្គមខ្មែរយើង ដើម្បីឱ្យមិត្តអ្នកអានបានយល់កាន់តែច្បាស់ទៅលើចំណុចទាំងនោះ។ មិនតែប៉ុណ្ណោះ ពួកខ្ញុំក៏មានស្រាវជ្រាវបន្ថែមផងដែរទាក់ទងឯកសារអន្តរជាតិមួយចំនួនដូចជា អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៩០ ដែលឆ្លុះបញ្ចាំងអំពីសិទ្ធិរបស់អនីតិជន ដែលសង្គម

អន្តរជាតិទទួលស្គាល់។ តាមរយៈព័ត៌មានដែលប្រមូលបាន ពួកខ្ញុំធ្វើការញែកចំណុចទាំងនោះទៅតាមដំណាក់កាលនីមួយៗ ដើម្បីងាយស្រួលក្នុងការចងក្រង។ ជាក់ស្តែង សារណាបញ្ចប់ការសិក្សាមួយនេះ ត្រូវបានបែកជា ៤ជំពូកធំ៖ ជំពូកទី១៖ ការស៊ើបអង្កេតលើបទឃាតកម្មដែល ប្រព្រឹត្តដោយអនីតិជន។ ជំពូកទី១នេះ នឹងបង្ហាញពីការស៊ើបអង្កេតរបស់មន្ត្រីមានសមត្ថកិច្ចនៅពេលមានបទឃាតកម្មដែលបង្កដោយអនីតិជន ជាពិសេសគឺមានរួមបញ្ចូលទាក់ទងនឹងការវិភាគសាកសពដែលអនីតិជននោះបានសម្លាប់។ ជំពូកទី២៖ ការសម្រេចរបស់អង្គការអយ្យការលើ ការចោទប្រកាន់ បទល្មើស។ ក្នុងជំពូកនេះ ផ្តោតទៅលើតើអង្គការអយ្យការសម្រេចយ៉ាងដូចម្តេច បន្ទាប់ពីពិនិត្យសំណុំរឿង និងជនសង្ស័យដែលបញ្ជូនមក បានន័យថាគួរចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។ ជំពូកទី៣៖ ការស៊ើបសួរលើបទល្មើសដោយចៅក្រមស៊ើបសួរ។ ដោយ បទឧក្រិដ្ឋទាមទារមានការបើកការស៊ើបសួរជាចាំបាច់ ដូច្នេះជំពូកនេះនឹងរៀបរាប់អំពីដំណើរនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ ជំពូកទី៤៖ ការជំនុំជម្រះលើបទល្មើស។ ជំពូកចុងក្រោយនេះ នឹងបង្ហាញអំពីការបើកសវនាការជំនុំជម្រះទៅលើជនជាប់ចោទដែលជាអនីតិជននោះ នឹងទោសដែលជននោះអាចប្រឈមមុខទទួលតាមច្បាប់ដែលបានកំណត់។

## ជំពូកទី១: ការស៊ើបអង្កេតលើបទឃាតកម្មដែលប្រព្រឹត្តដោយអនីតិជន

ជាការពិតណាស់ ការស៊ើបអង្កេតគឺជានីតិវិធីចាំបាច់មួយនៅក្នុងបទឃាតកម្ម ហើយវាក៏ផ្តល់សារៈសំខាន់ខ្លាំងនៅក្នុងដំណើរការរឿងក្តីនោះ ព្រោះតាមរយៈការស៊ើបអង្កេត សមត្ថកិច្ចអាចទទួលបានភស្តុតាងបន្ថែម និងស្វែងយល់អំពីបទល្មើសនោះកាន់តែស៊ីជម្រៅ។ បន្ថែមពីនេះ អាស្រ័យដោយអនីតិជន ជាជនដែលត្រូវបានគេការពារយកចិត្តទុកដាក់ខ្លាំង ហេតុនេះហើយ នៅពេលដែលអនីតិជននោះប្រព្រឹត្តបទឃាតកម្ម គេត្រូវធ្វើការស៊ើបអង្កេតទៅលើបទល្មើសនោះឱ្យបានច្បាស់លាស់ ជៀសវាងមានការភ័ន្តច្រលំដែលនាំឱ្យឈានដល់ការដាក់ទោសមិនត្រឹមត្រូវ ហើយវាជះឥទ្ធិពលដល់អនាគតរបស់អនីតិជនរូបនោះ។

### ផ្នែកទី១: តួអង្គក្នុងការស៊ើបអង្កេត

#### កថាខណ្ឌទី១: សមាសភាពមន្ត្រីមានសមត្ថកិច្ចក្នុងកិច្ចស៊ើបអង្កេត

ការស៊ើបអង្កេតជាដំណាក់កាលដំបូងនៃចំណាត់ការបទឃាតកម្ម ដែលត្រូវតែអនុវត្តជាចាំបាច់។ ជាទូទៅ ប្រជាពលរដ្ឋមួយចំនួនតែងតែងយល់ឃើញថា ពាក់ព័ន្ធនឹងការស៊ើបអង្កេតជាសមត្ថកិច្ចរបស់ប៉ូលីស។ ការយល់ឃើញដូច្នេះពុំខុសទាំងស្រុងនោះទេ។ ក្រឡេកទៅមើលមូលដ្ឋានច្បាប់វិញឃើញថា មន្ត្រីដែលមានសមត្ថកិច្ចទៅលើកិច្ចស៊ើបអង្កេតលើបទឃាតកម្មមុនដំណាក់កាលកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ អាចត្រូវបានបែងចែកជា ២ធំៗ គឺ អង្គការអយ្យការ និង នគរបាលយុត្តិធម៌។ ទោះជាយ៉ាងណាក្តី ក៏មន្ត្រីសមត្ថកិច្ចទាំង ២នេះ មានការសហការ និងប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកក្នុងការស៊ើបអង្កេត។

អង្គការអយ្យការ ជាស្ថាប័នមួយដែលមានតួនាទីក្នុងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់[1]។ អង្គការអយ្យការនេះក៏ជាម្ចាស់ដើមបណ្តឹងអាជ្ញាផងដែរ។ ចៅក្រមអយ្យការ ជាអ្នកទទួលបន្ទុកលើការងាររួមនៃដំណើរការអង្គការអយ្យការ ដែលត្រូវបានប្រគល់សិទ្ធិ អំណាច និងតួនាទីតាមក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀតដែលមានជាធរមាន។

ចៅក្រមអយ្យការ នៅក្នុងអង្គការអយ្យការនេះរួមមាន៖

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង។[2]

[1] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[2] មាត្រា ២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នគរបាលយុត្តិធម៌ ជាជំនួយរបស់អំណាចតុលាការដែលមានភារកិច្ចធ្វើការត្រួតពិនិត្យ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង[3]។ ចំពោះករណីដែលអនីតិជនប្រព្រឹត្តបទឃាតកម្ម គឺនគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារ អនីតិជន សម្រាប់ការងារត្រួតពិនិត្យបទល្មើសនោះ កំណត់អត្តសញ្ញាណ ប្រមូលភស្តុតាង និងចាប់អនីតិជន[4]។ នគរបាលយុត្តិធម៌ អនុវត្តសិទ្ធិ និងតួនាទីអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងបទដ្ឋានគតិយុត្តិនានា ក្រោមការឃ្លាំមើល ដឹកនាំ និងសម្របសម្រួលការងាររួមពីអង្គការអយ្យការ។

មន្ត្រីដែលត្រូវបានគេចាត់ទុកជានគរបាលយុត្តិធម៌រួមមាន៖

- មន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលយុត្តិធម៌
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។[5]

### កថាខណ្ឌទី២: វិសាលភាពដែនសមត្ថកិច្ចរបស់មន្ត្រីមានសមត្ថកិច្ចក្នុងកិច្ចស៊ើបអង្កេត

ការបែងចែកដែនសមត្ថកិច្ចរបស់មន្ត្រីមានសមត្ថកិច្ចក្នុងកិច្ចស៊ើបអង្កេត ក៏ជាកត្តាមួយជួយជំរុញឱ្យការស៊ើបអង្កេតលើបទល្មើសនោះមានដំណើរការប្រកបដោយរលូន និងមានប្រសិទ្ធភាព ព្រោះនៅពេលដែលអនីតិជនបានធ្វើឃាតទៅលើជនណាម្នាក់នៅទីកន្លែងណាមួយនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា គេប្រាកដជាដឹងច្បាស់ថាបទល្មើសនោះស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់មន្ត្រីណា ដើម្បីជាការងាយស្រួលក្នុងការធ្វើចំណាត់ការទៅលើបទល្មើសនោះ។ ចំពោះដែនសមត្ថកិច្ចនោះទៀតសោតក៏មានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ។

នៅក្នុងប្រទេសកម្ពុជា មានអង្គការអយ្យការអមសាលាដំបូងនៅតាមបណ្តារាជធានី-ខេត្តនីមួយៗ ដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងជាតំណាងឱ្យអង្គការនោះ។ អង្គការអយ្យការអមសាលាដំបូងនោះផងដែរ មានដែនសមត្ថកិច្ចតែនៅក្នុងរង្វង់ដែនដីរាជធានី-ខេត្ត ដែលស្ថាប័នខ្លួនតាំងនៅតែប៉ុណ្ណោះ។ រីឯចំពោះដែនសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ត្រូវបានបែងជា ៣គឺមាន៖

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស

[3] មាត្រា ២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[4] មាត្រា ១២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[5] មាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស។[6]

ការកំណត់សមត្ថកិច្ចរបស់ព្រះរាជាអាជ្ញា បង្កលក្ខណៈងាយស្រួលដល់ព្រះរាជអាជ្ញានោះ ក្នុងការដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងដែនដីរបស់ខ្លួន ដើម្បីឱ្យចំណាត់ការលើបទល្មើសនោះប្រកបដោយប្រសិទ្ធភាពខ្ពស់។ នៅក្នុងកិច្ចស៊ើបអង្កេត ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេតនោះ និងណែនាំដល់មន្ត្រីក្រោមឱវាទរបស់ខ្លួន[7]។ ព្រះរាជអាជ្ញា ក៏អាចបែងចែកនៅអំណាចរបស់ខ្លួនឱ្យទៅព្រះរាជអាជ្ញារង ក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើសណាមួយ[8]។ ការធ្វើបែបអាចជួយជម្រុញឱ្យការងារមានភាពឆាប់រហ័ស ជៀសវាងការយឺតយ៉ាវនៃសំណុំរឿង។

នៅក្នុងកិច្ចស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឱ្យទៅបំរើការងារ[9]។ បញ្ញត្តិនេះមិនបានដាក់កំហិតដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការប្រតិបត្តិការងាររបស់ខ្លួនតែនៅក្នុងដែនដីនៃអង្គភាពរបស់ខ្លួននោះទេ។ មានករណីមួយចំនួនដូចជា បទឃាតកម្មនោះជាបទល្មើសជាក់ស្តែង ហើយមន្ត្រីនគរបាលយុត្តិធម៌ណាដែលទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតនោះធ្វើឡើងដោយផ្ទាល់មាត់ក៏ដោយ គឺមន្ត្រីនគរបាលយុត្តិធម៌នោះអាចធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីព្រះរាជាណាចក្រកម្ពុជាទាំងមូល ប៉ុន្តែការអនុញ្ញាតនោះត្រូវតែចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត[10]។ នៅក្នុងបទឧក្រិដ្ឋដូចជាបទឃាតកម្មជាដើម ភ្នាក់ងារនគរបាលយុត្តិធម៌ពុំសូវមានសមត្ថកិច្ចមុខការទេ ពោលគឺភ្នាក់ងារនគរបាលយុត្តិធម៌នោះគ្រាន់តែជាជំនួយដល់ការងារនានារបស់មន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះ។

**ផ្នែកទី២ : ការចុះពិនិត្យ វិភាគ និងប្រមូលភស្តុតាងនៅទីកន្លែងកើតហេតុ**

ផ្អែកទៅលើភស្តុតាងដែលប្រមូលបាន ភស្តុតាងទាំងនោះជាមូលដ្ឋានក្នុងការវិភាគវិនិច្ឆ័យទៅលើពិរុទ្ធភាពរបស់អនីតិជនដែលបានប្រព្រឹត្តបទល្មើសនោះ។ ភស្តុតាង អាចជាភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។ ភស្តុតាងដាក់បន្ទុក គឺជាខ្លឹមសារនៃភស្តុតាងទាំងឡាយណាដែលទម្រង់

[6] មាត្រា ៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[7] មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[8] មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[9] មាត្រា ៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[10] មាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

របស់វាធ្វើឱ្យមានពិរុទ្ធភាពទៅលើជនជាប់ចោទ ឬភស្តុតាងដែលធ្វើឱ្យមានការទទួលខុសត្រូវនូវកំហុសរបស់ជនដែលបានប្រព្រឹត្តបទល្មើសនោះ[11]។ រីឯភស្តុតាងដោះបន្ទុកវិញ គឺជាខ្លឹមសារនៃភស្តុតាងទាំងឡាយណាដែលទម្រង់របស់វាច្រានចោលការចោទប្រកាន់ ដោយក្នុងនោះគ្រប់ខណៈនៃភស្តុតាង មានសញ្ញាណគាំទ្រដល់ភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ ឬភស្តុតាងទាំងនោះធ្វើឱ្យថយចុះកាន់តែតូចទៅៗនូវពិរុទ្ធភាព[12]។ ភស្តុតាង អាចត្រូវបានប្រមូលតាមរយៈរូបភាពផ្សេងៗដូចជាតាមការចង្អុលបង្ហាញរបស់សាក្សី ភស្តុតាងបន្សល់នៅទីកន្លែងកើតហេតុ ឬតាមការសួរចម្លើយបុគ្គលពាក់ព័ន្ធជាដើម។ ជាធម្មតា នៅពេលដែលបទឃាតកម្មកើតឡើងនៅកន្លែងណាមួយ គេតែងតែសង្កេតឃើញមានមន្ត្រីសមត្ថកិច្ចនានាចុះទៅដល់ទីតាំងនៃកន្លែងដែលបានកើតហេតុនោះ ដើម្បីធ្វើការពិនិត្យ និងប្រមូលភស្តុតាងដែលបានបន្សល់ទុកនៅទីកន្លែងនោះ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ ភាគីនៃសំណុំរឿងគ្មានកាតព្វកិច្ចត្រូវស្វែងរកភស្តុតាងនោះទេ តែជាបន្ទុករបស់អង្គការរដ្ឋដែលមានសមត្ថកិច្ចក្នុងការចោទប្រកាន់នោះជាអ្នកបំពេញ[13]។ ក្នុងន័យនេះ មិនមែនហាមឃាត់ភាគីសំណុំរឿងមិនឱ្យចង្អុលបង្ហាញភស្តុតាងដែលគាត់បានដឹង លឺ ឬមាននោះទេ គ្រាន់តែក្នុងន័យនេះ គឺភាគីសំណុំរឿងមិនមានកាតព្វកិច្ចចាំបាច់ក្នុងការស្វែងរកភស្តុតាង។

***<u>ករណីសិក្សាទី១</u>***

យុវជនសង្ស័យម្នាក់ត្រូវបានឃាត់ខ្លួន ដោយជាប់ពាក់ព័ន្ធក្នុងករណីរំលោភ និងសម្លាប់ក្មេងស្រី "ខ" ម្នាក់អាយុ ១៨ឆ្នាំដែលសាកសពក្មេងស្រីនោះត្រូវបានរកឃើញនៅក្នុងវាលស្រែមួយក្នុងខេត្តកំពតកាលពីថ្ងៃពុធ។

នៅល្ងាចថ្ងៃច័ន្ទ ក្មេងស្រី "ខ" បានបាត់ខ្លួនពីផ្ទះរបស់នាងក្នុងឃុំល្បើក ស្រុកឈូក។

នៅថ្ងៃពុធ វេលាម៉ោង៦ព្រឹក សាកសពក្មេងស្រី "ខ" ត្រូវបានប្រទះឃើញដោយបងស្រីនាងនៅលើវាលស្រែដែលមានចម្ងាយជាង ១០០ម៉ែត្រ ពីផ្ទះរបស់ក្មេងស្រីនោះ ជាមួយនឹងស្នាមរបួសយ៉ាងធ្ងន់ធ្ងរនៅលើ ក មុខ និងថ្គាម។

លោក "ច" នាយកនៃអង្គការការពារកុមារភ្នំពេញ បានបង្ហាញថា មានសាក្សីម្នាក់ដែលបានលឺសម្លេងស្រែកពីចម្ងាយនៅវេលាដែល ក្មេងស្រី "ខ" បានបាត់ខ្លួននោះ ប៉ុន្តែពេលនោះគាត់គិតថាប្រហែលគ្មានរឿងអ្វីកើតឡើង។

[11] ទំព័រ១០០ នៃសៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូផា ឆ្នាំ២០១៦

[12] ទំព័រ១០១ នៃសៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូផា ឆ្នាំ២០១៦

[13] ទំព័រ៥១ នៃសៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូផា ឆ្នាំ២០១៦

ការបាត់ខ្លួនរបស់ក្មេងស្រី "ខ" ពុំបានរាយការណ៍ទៅសមត្ថកិច្ចនោះទេ ដោយគ្រួសារនាងគិតថាក្មេងស្រីនោះប្រហែលជានៅផ្ទះរបស់មិត្តភក្តិនាង។

លោក "ស" ប្រធានការិយាល័យបច្ចេកទេសនៃនាយកដ្ឋានប៉ូលីសខេត្តកំពត បានប្រាប់ថា "យើងអាចសន្និដ្ឋានបានថា ចំពោះករណីនេះជារឿងរំលោភសម្លាប់ ព្រោះខោក្នុងរបស់ជនរងគ្រោះនោះត្រូវបានស្រាតចេញ"។

លោក "ហ" អធិការនគរបាលស្រុកឈូក ក៏បានបន្ថែមទៀតថា "វាមិនមែនជាករណីលួច ឬប្លន់នោះទេ ព្រោះក្មេងស្រីជនរងគ្រោះនោះជាជនក្រីក្រ"។

លោក "ផ" នគរបាលឃុំល្បើក បានប្រាប់ថា "ប៉ូលីសឃុំបានឃាត់ខ្លួនយុវជនអាយុ ១៧ឆ្នាំម្នាក់ ជាអ្នកជិតខាងរបស់ជនរងគ្រោះ ដោយជាប់សង្ស័យថាមានការពាក់ព័ន្ធនឹងរឿងក្តីនេះ បន្ទាប់ពីសមត្ថកិច្ចរកឃើញស្បែកជើងមួយចំហៀងរបស់ជនសង្ស័យនោះ ស្ថិតនៅចម្ងាយ ៧០ម៉ែត្រពីកន្លែងកើតហេតុ"។

កាលពីថ្ងៃព្រហស្បតិ៍ក្រោយពីថ្ងៃប្រទះឃើញសាកសព លោក "ច" ដែលបានចូលរួមក្នុងការស៊ើបអង្កេតជាមួយមន្ត្រីនគរបាលខេត្តកំពត បានប្រាប់ថាមន្ត្រីដែលចុះប្រតិបត្តិការស៊ើបអង្កេតនោះជឿជាក់ថាធាងដូងមានប្រលាក់ឈាមនោះ ដែលត្រូវបានរកឃើញនៅកន្លែងកើតហេតុកាលពីថ្ងៃប្រទះឃើញសាកសពនោះ ជាអាវុធរបស់ឃាតករ។ លោកបានបន្ថែមទៀតថា "ជាដំបូងសមត្ថកិច្ចព្យាយាមរកដាវសាម៉ូរៃ ប៉ុន្តែបែរជារកឃើញធាងដូងដែលមានប្រវែងជាង ១ម៉ែត្រទៅវិញ វាប្រៀបដូចជាដាវ ដោយសារវាមុខមុតទាំងសងខាង"។ លោកក៏បានបន្ថែមថា ចំពោះឈាមដែលប្រលាក់លើធាងដូងនោះ គឺជាឈាមរបស់មនុស្ស ហើយឈាមនោះនឹងត្រូវបញ្ជូនទៅប្រទេសវៀតណាមសម្រាប់ធ្វើតេស្តឌីអិនអេ(DNA)។

លោក "គ" ប៉ូលីសព្រហ្មទណ្ឌខេត្តកំពត បានប្រាប់ថា ជនសង្ស័យទី២ដែលគាត់ពុំស្គាល់ឈ្មោះ ត្រូវបានកំណត់អត្តសញ្ញាណថាជាអ្នកជិតខាតរបស់ជនរងគ្រោះផងដែរ។

លោក "ផ" នគរបាលឃុំល្បើក បានបន្ថែមថា "ជនសង្ស័យទី២ នោះមានអាយុប្រហែល ១៦ ឬ ១៧ឆ្នាំ។ កត្តាដែលឱ្យនាំមានការសង្ស័យនោះ គឺជនសង្ស័យនោះឧស្សាហ៍មកសាកថ្មទូរស័ព្ទនៅផ្ទះបងស្រីរបស់ក្មេងស្រីជនរងគ្រោះ ហើយពេលខ្លះទៀតពួកគេក៏ធ្លាប់ផឹកជាមួយគ្នាផងដែរ"។

ប៉ូលីសភ្នំពេញធ្វើការសហការជាមួយប៉ូលីសខេត្តកំពតក្នុងការស្វែងរកជនសង្ស័យទី២[14]។

---

[14] ដកស្រង់ និងបកប្រែចេញគេហទំព័រ *http://www.phnompenhpost.com/national/suspect-detained-rape-murder-kampot-teen*

ជនសង្ស័យទី១ ជាក្មេងប្រុសអាយុ ១៧ឆ្នាំ បាននាំខ្លួនសម្រាប់ធ្វើការសួរចម្លើយ។ ២ថ្ងៃក្រោយមក ប៉ូលីសរាជធានីភ្នំពេញបានឃាត់ខ្លួនជនសង្ស័យទី២ និងបានបញ្ជូនជននោះទៅឱ្យនគរបាលខេត្តកំពត។ តាមការរាយការណ៍របស់ លោក "អ" ប៉ូលីសខេត្តកំពត បានបញ្ជាក់ថាក្មេងប្រុសទាំង២ (ជនសង្ស័យទី១ និងជនសង្ស័យទី២) ត្រូវបានដោះលែង។

ក្រោយមក នគរបាលបានឈានដល់ការឃាត់ខ្លួនជនសង្ស័យទី៣ នៅក្នុងរឿងក្តីសង្ស័យចាប់រំលោភ និងសម្លាប់ក្មេងស្រីអាយុ ១៩ឆ្នាំនេះ ព្រោះគេបានរកឃើញនូវវត្ថុដែលគេសង្ស័យថាជាអាវុធទី២ ក្នុងបទឃាតកម្មនោះ។

ជនសង្ស័យថ្មី មានអាយុ ២៩ឆ្នាំ ឈ្មោះ "គ" ត្រូវបានចាប់ខ្លួននៅថ្ងៃសៅរ៍ វេលាម៉ោង ៩ព្រឹក។ លោក "ផ" ប៉ូលីសឃុំល្បើក បានបញ្ជាក់ថា "ជនសង្ស័យនោះត្រូវបានរកឃើញនៅក្នុងផ្ទះ ដែលស្ថិតនៅចម្ងាយ ១៥ម៉ែត្រពីផ្ទះរបស់ជនរងគ្រោះ"។ គាត់បានបញ្ជាក់ទៀតថា នគរបាលកំពតច្បាស់ ១០០% ថាជនសង្ស័យទី៣ នោះឃាតករពិតប្រាកដ។

លោក "អ" នគរបាលខេត្តកំពត បានបង្ហាញថា ទោះបីជាជនសង្ស័យទី៣នោះបដិសេធមិនបានសម្លាប់ក្មេងស្រីនោះក៏ដោយ ក៏អ្នកស៊ើបអង្កេតបានរកឃើញនូវភស្តុតាងដូចជា "ឈាមនៅលើកអាវ និងស្លាកស្នាមដាច់រលាត់នៅលើមុខ និងករបស់គាត់"។ គាត់បានបន្ថែមទៀតថា "យើងនិងបញ្ជូនខ្លួនជនសង្ស័យទី៣នោះទៅកាន់សាលាដំបូងខេត្ត នៅថ្ងៃច័ន្ទសម្រាប់ចោទប្រកាន់គាត់ពីបទរំលោភ និងសម្លាប់។"

យោងតាម ប៉ូលីសឃុំ "ផ" បានបញ្ជាក់ថា អ្នកភូមិបានប្រាប់ទៅកាន់អ្នកស៊ើបអង្កេតថាពួកគេអាចធ្វើជាសាក្សីក្នុងការបង្ហាញថា ជនសង្ស័យទី៣បានឈ្លោះជាមួយជនរងគ្រោះនៅយប់ដែលក្មេងស្រី "ខ" បានបាត់ខ្លួន។

លោក "ច" បានប្រាប់ថា "សមត្ថកិច្ចបានរកឃើញនូវវត្ថុតាងសង្ស័យថ្មីនៅទីកន្លែងកើតហេតុកាលពីថ្ងៃសៅរ៍។ វត្ថុតាងសង្ស័យនោះ គឺបន្ទះក្តារប្រវែង ១០សង់ទីម៉ែត្រ ដែលត្រូវបានដកចេញពីរបងរបស់ជនសង្ស័យនោះផ្ទាល់តែម្តង។ ហើយសមត្ថកិច្ចបានធ្វើការសាកល្បងយកបន្ទះក្តារនោះទៅដាក់ចូលចន្លោះរបងរបស់សង្ស័យដែលប្រហោងនោះ ឃើញថាដាក់ចូលត្រូវល្អឥតខ្ចោះ[15]។

ចំពោះករណីសិក្សាទី១ ខាងលើនេះ បានបង្ហាញឱ្យឃើញថាបន្ទាប់ពីសាកសពក្មេងស្រី "ខ" ត្រូវបានប្រទះឃើញដោយបងស្រីរបស់ជនរងគ្រោះ មន្ត្រីនគរបាលយុត្តិធម៌ខេត្តកំពតបានចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យសាកសព និងស្វែងរកភស្តុតាងនានានៅទីកន្លែងនោះតែ

---

[15] ដកស្រង់ និងបកប្រែចេញគេហទំព័រ *http://www.phnompenhpost.com/national/third-suspect-held-kampot-murder*

ម្តង។ ក្នុងអំឡុងពេលពិនិត្យទីកន្លែងនោះ មន្ត្រីសមត្ថកិច្ចបានប្រទះឃើញនូវស្បែកជើងមួយចំហៀងដែលបន្សល់នៅចម្ងាយ ៧០ម៉ែត្រពីទីកន្លែងកើតហេតុនោះ។ តាមរយៈស្បែកជើងនោះ នាំឱ្យមន្ត្រីនគរបាលយុត្តិធម៌ដែលចុះក្នុងប្រតិបត្តិការនោះមានការសង្ស័យថាជារបស់ជនបង្ក ដែលត្រូវបានគេស្គាល់អត្តសញ្ញាណថាជាអ្នកជិតខាងរបស់ជនរងគ្រោះ។ ក្រៅពីស្បែកជើង សមត្ថកិច្ចបានរកឃើញនូវធាងដូងប្រវែងមួយម៉ែត្រ ដែលមានប្រលាក់ឈាមនៅពីលើ ហើយគេជឿជាក់ថា ធាងដូងនោះអាវុធរបស់ជនបង្ក។ ក្រោយមក វត្ថុតាងទី២ក្នុងរឿងក្តីនោះគឺបន្ទះក្តារប្រវែង ១០សង់ទីម៉ែត្រ។ វត្ថុតាងទាំងអស់នេះហើយ ជាភស្តុតាងសម្រាប់ធ្វើការចោទប្រកាន់ជនសង្ស័យដែលបានប្រព្រឹត្តបទឃាតកម្មនោះ។

**កថាខណ្ឌទី១ : បទល្មើសជាក់ស្តែង**

ប្រជាពលរដ្ឋមួយចំនួនយល់ឃើញថា បទល្មើសជាក់ស្តែងជាបទល្មើសដែលទើបនឹងកើតឡើង ហើយបទល្មើសនោះត្រូវបានគេឃើញដោយផ្ទាល់ភ្នែក។ ការយល់ឃើញដូច្នេះ គឺមានលក្ខណៈពុំខុសនោះទេ ព្រោះនិយមន័យរបស់បទល្មើសជាក់ស្តែង ត្រូវបានចែងយ៉ាងច្បាស់លាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។ តើចំពោះបទឃាតកម្មយ៉ាងដូចម្តេចទើបចាត់ទុកថាជាបទឧក្រិដ្ឋជាក់ស្តែង? យោងតាមមាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា៖

*បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ*

*- បទល្មើសដែលកំពុងប្រព្រឹត្ត*

*-បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ។*

*ត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក:*

*-ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រគឹង*

*-បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។*

ក្រៅពីករណីខាងលើ គេក៏ចាត់ទុកថាបទឧក្រិដ្ឋជាក់ស្តែងផងដែរ នៅពេលអ្នកកាន់កាប់ទីកន្លែងដែលបទឧក្រិដ្ឋនោះកើតមានឡើង បានស្នើសុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីគ្មានមន្ត្រីនគរបាលយុត្តិធម៌[16]។

[16] មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជាការពិតណាស់ នៅពេលដែលបទឃាតកម្មជាក់ស្តែងកើតមានឡើង គ្រប់បុគ្គលទាំងអស់សុទ្ធតែអាចធ្វើការចាប់ខ្លួនជនល្មើសនោះប្រគល់ទៅមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតទីកន្លែងនោះ[17]។ ជាក់ស្តែងដូចករណីសិក្សាទី១ខាងលើ បានបង្ហាញថាស្បែកជើងមួយចំហៀងរបស់យុវជនសង្ស័យទី១ ត្រូវបានរកឃើញនៅក្នុងបរិវេណកើតហេតុនោះ។ ដូច្នេះ ផ្អែកលើនិយមន័យ នៃបទល្មើសជាក់ស្តែងខាងលើ ជនសង្ស័យទី១នោះអាចត្រូវបានគេចាប់ខ្លួន ដើម្បីនាំខ្លួនមកសួរចម្លើយពាក់ព័ន្ធបទល្មើសដែលបានកើតឡើងនោះ។ តួយ៉ាង ការចាប់ខ្លួនជនសង្ស័យទី១នោះ ក៏ទាមទារឱ្យមានការគោរពសិទ្ធិរបស់ជននោះផងដែរដូចជាបញ្ចៀសពីភាពអាម៉ាស់ និងគោរពលើសេចក្តីថ្លៃថ្នូររបស់ជននោះ ដោយហេតុជនសង្ស័យទី១ ជាអនីតិជន មានអាយុ ១៧ឆ្នាំនៅឡើយ។ បន្ថែមពីនេះ ក្រោយពីការចាប់ខ្លួនជនសង្ស័យទី១ខាងលើ មន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចនោះត្រូវតែជូនដំណឹងទៅព្រះរាជអាជ្ញា អ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជន អ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬមន្ត្រីនគរបាលយុត្តិធម៌ប៉ុន្តែត្រូវមានការយល់ព្រមពីអនីតិជនរូបនោះ ភ្នាក់ងារសង្គមកិច្ច មេធាវីប្រសិនបើពុំមានមេធាវីទេ មន្ត្រីនគរបាលយុត្តិធម៌អាចឱ្យអនីតិជនជ្រើសរើសនូវមេធាវីមិនយកកម្រៃចេញពីបញ្ជីឈ្មោះមេធាវីដែលខ្លួនមាន អ្នកបកប្រែដោយមិនយកកម្រៃ ប្រសិនបើអនីតិជនរូបនោះពុំមានអ្នកបកប្រែផ្ទាល់ខ្លួន ។ ម្យ៉ាងវិញទៀត ដើម្បីជានាដល់រក្សានូវតម្រុយភស្តុតាងទាំងឡាយនៅជុំវិញបរិវេណទីកន្លែងកើតហេតុ មន្ត្រីនគរបាលយុត្តិធម៌នៅទីនោះមានសិទ្ធិក្នុងការហាមឃាត់បុគ្គលទាំងឡាយណាមិនឱ្យចាកចេញឆ្ងាយពីបរិវេណទីតាំងនោះ[18]។ ព្រះរាជអាជ្ញាក៏មានសិទ្ធិក្នុងការចុះទៅកាន់ទីកន្លែងកើតហេតុនោះផងដែរ ប្រសិនជាយល់ឃើញថាមានភាពចាំបាច់។ ក្រោយពីពិនិត្យទីកន្លែងកើតហេតុរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន[19]។

### កថាខណ្ឌទី២ : បទល្មើសមិនជាក់ស្តែង

គេចាត់ទុកជាបទល្មើសមិនជាក់ស្តែង លុះត្រាតែបទល្មើសនោះ ពុំមានលក្ខណៈដូចមានចែងក្នុងមាត្រា៨៦ និងមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដែលមាត្រាទាំងពីរនេះចែងអំពីបទល្មើសជាក់ស្តែង។ នៅពេលដែលបទឃាតកម្មកើតឡើងក្រោមរូបភាពជាបទល្មើសមិនជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតបឋមដោយខ្លួនឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ ដូច្នេះ ករណីដែលមន្ត្រីនគរបាលយុត្តិធម៌បានដឹងលឺពីបទឃាតកម្មនៅក្នុង

[17] មាត្រា៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[18] មាត្រា៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[19] មាត្រា៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

តំបន់របស់ខ្លួន ឬតាមរយៈព្រះរាជអាជ្ញាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌នោះអាចបើកការស៊ើបអង្កេតបឋមតាមរយៈការចុះទៅពិនិត្យទីតាំងនៃបទល្មើសនោះ។ នៅក្នុងដំណាក់កាលនេះ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិស្របច្បាប់ក្នុងការកោះហៅបុគ្គលគ្រប់រូបដែលជាប់សង្ស័យទៅនឹងបទល្មើស ឬបុគ្គលនោះអាចផ្ដល់ព័ត៌មានជុំវិញរឿងហេតុដែលបានកើតឡើងនៅតំបន់នោះ[20]។ ផ្ទុយទៅវិញ ប្រសិនបើបុគ្គលនោះបដិសេធមិនចូលរួមតាមការកោះហៅទេ មន្ត្រីនគរបាលយុត្តិធម៌អាចរាយការណ៍អំពីបញ្ហានេះទៅកាន់ព្រះរាជអាជ្ញា ដើម្បីចេញបញ្ជាឱ្យចូលខ្លួន។ នៅពេលដែលទទួលបានបញ្ជាឱ្យចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចប្រើកម្លាំងសាធារណៈបង្ខំជននោះឱ្យចូលខ្លួនបានស្របច្បាប់ដោយសំអាងទៅលើបញ្ញត្តិមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ អាស្រ័យដោយវាជាបទល្មើសមិនជាក់ស្តែង ដូច្នេះមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការចាប់ខ្លួនអនីតិជនណាមួយដោយគ្មានការអនុញ្ញាតពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរទេ ព្រោះច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ បានកំណត់យ៉ាងច្បាស់លាស់ថា "នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ"[21]។ ក្រោយពីពិនិត្យ និងប្រមូលភស្តុតាងរួចហើយ មន្ត្រីនគរបាលយុត្តិធម៌នោះត្រូវធ្វើកំណត់ហេតុស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។

**ផ្នែកទី៣ : ការឆែកឆេរ**

កម្មសិទ្ធិករនីមួយៗមានសិទ្ធិផ្តាច់មុខទៅលើកម្មសិទ្ធិឯកជនរបស់ខ្លួន នឹងទទួលបានការគាំពារដោយស្របច្បាប់ទៅកម្មសិទ្ធិស្របច្បាប់របស់ខ្លួននោះ។ ហេតុដូច្នេះហើយ មិនមែនគ្រប់បុគ្គលទាំងអស់សុទ្ធតែអាចឆែកឆេរកម្មសិទ្ធិរបស់គេបាននោះទេ។ រាល់ការឆែកឆេរលំនៅឋានសម្ភារៈវត្ថុ និងលើរូបបុគ្គលត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ [22]។ ដើម្បីគាំទ្រដល់ខ្លឹមសារនៃមាត្រា៤០ កថាខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាជៀសវាងពីការប៉ះពាល់ដល់សិទ្ធិរបស់កម្មសិទ្ធិករនៃទីកន្លែងនោះក្នុងប្រតិបត្តិការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវនីតិវិធីឆែកឆេរដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ហើយចំពោះនីតិវិធីនោះទៀតសោត ត្រូវបានបែងចែកជា ២ករណី គឺសម្រាប់បទល្មើសជាក់ស្តែង និងសម្រាប់បទល្មើសមិនជាក់ស្តែង។

[20] មាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[21] មាត្រា១៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[22] មាត្រា៤០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

**កថាខណ្ឌទី១ : បទល្មើសជាក់ស្តែង**

យើងបានសិក្សារួចមកហើយថាបទឃាតកម្មមានលក្ខណៈយ៉ាងដូចម្តេចត្រូវបានគេចាត់ទុកថាជាបទល្មើសជាក់ស្តែង អនុលោមតាមមាត្រា៨៦ និងមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ ដើម្បីទទួលបាននូវវត្ថុតាងបន្ថែមជុំវិញបទល្មើសដែលបានកើតឡើង ការឆែកឆេរទីកន្លែងមួយគឺអាចធ្វើឡើងជាចាំបាច់។ ទោះបីបទឃាតកម្មនោះ ជាបទល្មើសជាក់ស្តែងក៏ដោយក៏ការឆែកឆេរនោះត្រូវតែបំពេញតាមលក្ខខណ្ឌច្បាប់បានកំណត់មួយចំនួនដូចជា[23]៖

- ការឆែកឆេរពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែទទួលការយល់ព្រមពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតនោះធ្វើឡើងដោយផ្ទាល់មាត់ក៏ដោយ។
- ការឆែកឆេរត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង។ ផ្ទុយទៅវិញ បើពុំមានវត្តមានរបស់អ្នកកាន់កាប់ទីកន្លែងនោះទេ ត្រូវធ្វើឡើងចំពោះមុខសាក្សីចំនួន ២នាក់។ សាក្សីនោះផងដែរ ត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលសាក្សីនោះមិនអាច ជានគរបាល ឬកងរាជអាវុធហត្ថចូលរួមក្នុងប្រតិបត្តិការនោះបានទេ។
- អាស្រ័យដោយវាជាប្រភេទបទល្មើសជាក់ស្តែង ដូច្នេះការឆែកឆេរអាចធ្វើបានគ្រប់ពេលវេលា។

តាមរយៈនៃការឆែកឆេរនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរដោយក្នុងនោះត្រូវមានចុះអំពីកាលបរិច្ឆេទ និងម៉ោងដែលទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញាក្នុងការចុះឆែកឆេរ រួមទាំងចុះអំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។ ក្នុងអំឡុងពេលប្រតិបត្តិការឆែកឆេរ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ស្រាវជ្រាវរកឃើញមានវត្ថុតាងដែលពាក់ព័ន្ធទៅនឹងបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ដែលចុះប្រតិបត្តិការនោះអាចចាប់យកនូវវត្ថុតាងនោះ ប៉ុន្តែត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ រួចត្រូវបង្ហាញវត្ថុតាងនោះទៅកាន់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនៅទីតាំងនោះជាមុនសិន ក៏ដូចជាកត់ត្រាអំពីវត្ថុតាងចូលក្នុងកំណត់ហេតុស្តីអំពីការចាប់យកផងដែរ[24]។ កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬផ្តិតស្នាមមេដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ ។

**កថាខណ្ឌទី២ : បទល្មើសមិនជាក់ស្តែង**

ក្នុងករណីបទឃាតកម្មជាបទល្មើសមិនជាក់ស្តែង នីតិវិធីនៃការឆែកឆេរមានលក្ខណៈខុសគ្នាបន្តិចពីបទល្មើសជាក់ស្តែង។ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌មានតម្រុយពីទីតាំងណាមួយដែលអាចឈានដល់ស្វែងរកវត្ថុតាងមានប្រយោជន៍ពាក់ព័ន្ធបទល្មើស មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរដោយផ្អែកលើលក្ខខណ្ឌមួយចំនួនដែលបានកំណត់ក្នុងច្បាប់[25]៖

[23] មាត្រា៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[24] មាត្រា៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[25] មាត្រា១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- ជាបឋម ការឆែកឆេររបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែទទួលការអនុញ្ញាតយល់ព្រមពីអ្នកកាន់កាប់ទីកន្លែង។ ការយល់ព្រមនោះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ក្នុងករណីអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរមន្ត្រីដែលចុះប្រតិបត្តិការឆែកឆេរនោះត្រូវសរសេរឱ្យច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ។
- ផ្ទុយមកវិញ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងនោះអវត្តមាន ឬបដិសេធមិនឱ្យចូលឆែកឆេរ មន្ត្រីនគរបាលត្រូវមានដីកាអនុញ្ញាតឱ្យឆែកឆេរ ដែលចេញដោយប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដីតាមការសុំរបស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនោះ។
- ដូចគ្នាទៅនឹងបទល្មើសជាក់ស្តែងផងដែរ ការឆែកឆេរត្រូវធ្វើចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬចំពោះមុខសាក្សី ២នាក់ ដែលចាត់តាំងដោយព្រះរាជអាជ្ញា ហើយមិនត្រូវជាសមាសភាពកម្លាំងចូលរួមប្រតិបត្តិការឆែកឆេរ ករណីអវត្តមានអ្នកកាន់កាប់ទីកន្លែង។
- ការឆែកឆេរមិនអាចអនុវត្តមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ បានឡើយ។

រាល់វត្ថុតាងដែលប្រមូលបានក្នុងអំឡុងពេលឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌នោះត្រូវបិទស្លាកបោះត្រាលើវត្ថុទាំងនោះ និងត្រូវបង្ហាញផងដែរនូវវត្ថុតាងដែលចាប់យកនោះដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២នាក់។ ជាការចាំបាច់ មន្ត្រីនគរបាលត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យកដោយត្រូវមានការចុះហត្ថលេខា ឬផ្តិតមេដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២នាក់ នោះ។

### ផ្នែកទី៤ :ការពិនិត្យទៅលើសាកសព

នៅក្នុងបទឃាតកម្ម សាកសពជាភស្តុតាងមួយយ៉ាងសំខាន់សម្រាប់រឿងក្តី ដោយហេតុថាសមត្ថកិច្ចអាចទទួលបានភស្តុតាង និងព័ត៌មានជាច្រើនពាក់ព័ន្ធទៅនឹងការសម្លាប់នោះពីការធ្វើកោសលវិច័យពិនិត្យសាកសពដោយមានការចូលរួមពីអ្នកជំនាញពាក់ព័ន្ធ ដើម្បីឱ្យការពិនិត្យនោះទទួលបានចម្លើយដោយសុក្រឹត្យ នឹងត្រឹមត្រូវ។ បុគ្គលជំនាញ ជាបុគ្គលដែលមានទម្លាប់ធ្វើកិច្ចការណាមួយជាញឹកញាប់ និងញយៗ ដែលការធ្វើកិច្ចការបែបនេះក្លាយជាទម្លាប់ធម្មតារបស់គាត់ ហើយទម្លាប់នោះនាំឱ្យបុគ្គលនោះចេះដឹងថ្មីកបំផុត និងអាចមានសមត្ថភាពក្នុងការកំចាត់បង់មន្ទិលសង្ស័យនានាជុំវិញជំនាញរបស់បុគ្គលនោះ[26]។ តាមធម្មតា ជនល្មើសតែងតែព្យាយាមលាក់បាំងបទល្មើស ឬបង្វែរដាននៃបទល្មើសដោយការលុបបំបាត់ភស្តុតាង ឬធ្វើឱ្យអ្នកដទៃគិតថា ការស្លាប់

[26] ទំព័រ២២៦ នៃសៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូផា ឆ្នាំ២០១៦

របស់ជនរងគ្រោះគឺបណ្ដាលមកពីជនរងគ្រោះខ្លួនឯងផ្ទាល់តែម្ដង ដូចជាការបន្លំការសម្លាប់ទៅជារូបភាពនៃការលង់ទឹក, ការធ្វើអត្តឃាតខ្លួនឯង ឬហេតុផលមួយចំនួនទៀត[27]។ ទោះជាយ៉ាងណាជនល្មើសទាំងអស់នោះមិនអាចលាក់បាំងនូវបទល្មើសខ្លួនទាំងស្រុងនោះទេ ដោយសមត្ថកិច្ចមានវិធីសាស្ត្រជាច្រើនក្នុងការធ្វើកោសលវិច័យសាកសព បូករួមមានការចូលរួមពីអ្នកជំនាញដែលនាំឱ្យការពិនិត្យនោះមានលក្ខណៈកាន់តែច្បាស់ និងត្រឹមត្រូវ។

**កថាខណ្ឌទី១: ការកំណត់អត្តសញ្ញាណសាកសព**

នៅពេលទទួលបានព័ត៌មានអំពីការប្រទះឃើញសាកសព សមត្ថកិច្ចពាក់ព័ន្ធនានាដូចជាមន្ត្រីនគរបាលយុត្តិធម៌ជាដើម ត្រូវចុះទៅកាន់កើតហេតុភ្លាមៗ។ ការកំណត់អត្តសញ្ញាណសាកសព ជាកត្តាមួយចាំបាច់ផងដែរ ដើម្បីកំណត់ថាជនរងគ្រោះជាអ្នកណាឱ្យពិតប្រាកដ ជាការងាយស្រួលក្នុងការឱ្យដំណឹងទៅកាន់សាច់ញាតិនៃសព ហើយវាក៏ជាចំណុចមួយក្នុងការស្វែងយល់ពីមូលហេតុនៃការសម្លាប់នេះផងដែរ។ យ៉ាងណាមិញ សាកសពខ្លះត្រូវបានគេស្គាល់អំពីអត្តសញ្ញាណ រីឯសាកសពខ្លះទៀតគេមិនអាចកំណត់អត្តសញ្ញាណបាន។

ជាក់ស្ដែងដូចជាករណីសិក្សាទី១ ខាងលើ ដែលបទឃាតកម្មនោះកើតឡើងនៅខេត្តកំពតដោយសារតែសាកសពក្មេងស្រី "ខ" ត្រូវបានប្រទះឃើញដោយបងស្រីនាង ដូច្នេះការកំណត់អត្តសញ្ញាណសាកសពនៅក្នុងករណីនេះគឺមានលក្ខណៈងាយស្រួល ដោយហេតុថាបងស្រីរបស់ក្មេងស្រីរងគ្រោះ "ខ" នោះបានស្គាល់សាកសពនោះគឺជាសាកសពប្អូនស្រីរបស់ខ្លួន។ ផ្ទុយមកវិញក្នុងករណីដែលសាកសពនោះពុំត្រូវបានរកឃើញដោយសាច់ញាត្តិរបស់ខ្លួនដូចករណីសិក្សាទី១ទេ មន្ត្រីមានសមត្ថកិច្ចអាចស្គាល់អត្តសញ្ញាណសាកសពបានតាមរយៈឯកសារនានារបស់ជននោះ ដូចជា កាតអត្តសញ្ញាណប័ណ្ណសម្គាល់សញ្ជាត្តិជននោះ ប័ណ្ណបើកបរ ប័ណ្ណសម្គាល់ម្ចាស់យានយន្ត ឬលិខិតនានារបស់ជននោះដែលនៅជាប់នឹងខ្លួន។ សម្រាប់សាកសពដែលគេស្គាល់អត្តសញ្ញាណ សមត្ថកិច្ចចុះស៊ើបអង្កេតនោះធ្វើរបាយការណ៍លម្អិតនូវព័ត៌មានដែលមានប្រយោជន៍នានា ដូចជាការផ្តិតម្រាមដៃសាកសព ការថតរូបសាកសព វាស់ទំហំម្រាមដៃ ក្រចកដៃ និងកាត់ត្រាព័ត៌មាននានាដែលយល់ឃើញមានភាពចាំបាច់ និងប្រយោជន៍ដល់រឿងក្ដីនោះ។ ជាការពិតណាស់ នៅពេលសាកសពត្រូវបានស្គាល់អត្តសញ្ញាណ វាមានលក្ខណៈងាយស្រួលសម្រាប់សមត្ថកិច្ចក្នុងការជូនដំណឹងទៅឱ្យក្រុមគ្រួសារនៃសពឱ្យទទួលជ្រាបពីព័ត៌មាននេះ។ ម្យ៉ាងវិញទៀតចំពោះសាកសពនោះផងដែរ គេត្រូវពិនិត្យ ធ្វើកោសវិច័យលើសាកសពនោះឱ្យបានលម្អិតជាមុនសិន មុននឹងប្រគល់សាកសពឱ្យទៅគ្រួសារនៃសពយកទៅចាត់ចែងតាមប្រពៃណី។

[27] ទំព័រ៤៦២ សៀវភៅឧក្រិដ្ឋនិច្ឆ័យ របស់សាស្ត្រាចារ្យបណ្ឌិត ឯក ឆេងហួត ឆ្នាំ២០០៦

ចំពោះសាកសពដែលមិនអាចកំណត់អត្តសញ្ញាណបាន ដូចករណីសិក្សាខាងក្រោម៖

*ករណីសិក្សាទី២*

ស្ត្រីម្នាក់អាយុជាង ៣០ឆ្នាំ មិនស្គាល់អត្តសញ្ញាណនៅឡើយនោះ ត្រូវឃាតករវាយសម្លាប់ ហើយយកសពខ្ចប់អង្រឹង ទាំងអាក្រាតកាយ រួចយកទៅបោះចោល នៅក្នុងដីឡូត៍មួយកន្លែង ស្ថិតនៅខាងលិច វត្តអង្គតាមិញ ភូមិតាពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ បង្កឱ្យមានការភ្ញាក់ផ្អើល ដល់ប្រជាពលរដ្ឋ និងសមត្ថកិច្ច កាលពីព្រឹកព្រលឹមថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៥នេះ។

លោក "យ" អធិការនគរបាលខណ្ឌពោធិ៍សែនជ័យ បានបញ្ជាក់ថា រហូតមកដល់រសៀលថ្ងៃដដែលនេះ អត្តសញ្ញាណជនរងគ្រោះ នៅមិនទាន់ស្គាលអត្តសញ្ញាណនៅឡើយទេ ដោយកំពុងស្វែងរកសាច់ញាតិ ហើយជនរងគ្រោះអាចជាកម្មករសំណង់។

លោក "យ" បានបញ្ជាក់ទៀតថា ស្ត្រីរងគ្រោះ អាចត្រូវឃាតកររំលោភហើយសម្លាប់ រួចយកមកបោះចោលនៅទីនេះ ប៉ុន្តែត្រូវរង់ចាំ ការពិនិត្យ និងធ្វើកោសល្យវិច័យ ទឹកកាមជាមុនសិន ពីមន្ត្រី និងគ្រូពេទ្យជំនាញ។

សេចក្តីរាយការណ៍បានឱ្យដឹងថា សពស្ត្រីម្នាក់ដែលគេសម្លាប់រួច រុំនឹងអង្រឹង ប្លុងចោលក្នុងដីឡូត៍ជិតក្លឹបផ្កាយផត ត្រូវបានសមត្ថកិច្ចពិនិត្យ ធ្វើកោសល្យវិច័យឃើញមាន ស្នាមបែកមាត់ ស្នាមច្របាច់ក និងស្នាមខាំលើកំភួនដៃស្តាំ។

សពនេះត្រូវគេសង្ស័យថា ជានារីបម្រើការ នៅហាងខារ៉ាអូខេ ឬកោសជប់ណាមួយក្បែរៗកន្លែងកើតហេតុ។ ប្រភពពីកន្លែងកើតហេតុបានសង្ស័យថា ឃាតករសម្លាប់ស្ត្រីរងគ្រោះអាចជាមនុស្សស្រីដូចគ្នា ហើយមានទំនាស់គ្នាក្នុងកន្លែងធ្វើការ[28]។

តាមរយៈករណីសិក្សាទី២នេះ សាកសពពុំត្រូវបានស្គាល់អត្តសញ្ញាណពិតប្រាកដនោះទេ ដូច្នេះមន្ត្រីនគរបាលយុត្តិធមិពិបាកក្នុងការទំនាក់ទំនងជូនដំណឹងទៅកាន់សាច់ញាត្តិ ក្រុមគ្រួសារនៃសាកសពនោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏មន្ត្រីនគរបាលយុត្តិធមិចុះប្រតិបត្តិការនោះ ត្រូវធ្វើនូវកាតអត្តសញ្ញាណនៃសាកសពនោះ និងកំណត់ហេតុ របាយការណ៍ដូចជា កត់ត្រានូវទីកន្លែង និងពេលវេលាដែលរកឃើញសាកសពភេទ កំពស់ និងភិនភាគផ្សេងទៀត ឧទាហរណ៍ដូចជា ភិនភាគពាក់ព័ន្ធនិងធ្មេញ រូបសណ្ឋានពិសេស សំលៀកបំពាក់ គ្រឿងសម្រាប់ពាក់នៅជើង និងគ្រឿងសម្រាប់ពាក់នៅក្បាល ពេលវេលានិងមូលហេតុបណ្តាលឱ្យស្លាប់ ប្រភេទក្រុមឈាម និងជំងឺមុនៗដែលបានពិនិត្យតាមវិជ្ជាពេទ្យនៃនីតិវេជ្ជវិទ្យា។ ដោយសាកសពខាងលើជាមនុស្សស្រី ហើយ

[28] ដកស្រង់ចេញពីគេហទំព័រ *https://www.khmerload.com/news/39944*

ត្រូវបានរកឃើញទាំងកាយអាក្រាត អ្នកស៊ើបអង្កេតត្រូវបញ្ជាក់ពីសញ្ញាសំគាល់នៃព្រហ្មចារីយ៍ ភាពមានផ្ទៃពោះ ការចាប់រំលោភ និងការរំលូតកូន[29] ដូចដែលលោក "ឃ" អធិការខណ្ឌបានលើកឡើងថាសាកសពនោះនឹងត្រូវយកទៅធ្វើកោសល្យវិច័យទឹកកាមដោយអ្នកជំនាញ ដើម្បីបញ្ជាក់ថាសាកសពនោះត្រូវបានគេរំលោភ ហើយសម្លាប់ឬអត់។ ចំពោះការកំណត់ កត់ត្រាបែបនេះ គឺជួយសម្រួលដល់ការកំណត់ពីមូលហេតុនៃបទល្មើសកាន់តែប្រសើរ។ បន្ថែមពីនេះ សមត្ថកិច្ចដែលចុះកិច្ចស៊ើបអង្កេតនោះ ត្រូវធ្វើរបាយការណ៍ពិពណ៌នាឱ្យបានលម្អិតដូចជា ការផ្តិតម្រាមដៃសាកសព ការថតរូបសាកសព វាស់ទំហំម្រាមដៃ ក្រចកដៃ និងកាត់ត្រាព័ត៌មាននានាដែលយល់ឃើញមានភាពចាំបាច់ និងប្រយោជន៍ដល់រឿងក្តីនោះ។

### កថាខណ្ឌទី២: ការសង្កេតមុខរបួសសាកសព

បទឃាតកម្ម ជាបទល្មើសមួយដែលជនល្មើសអាចប្រព្រឹត្តឡើងតាមច្រើនរូបភាព ដោយក្នុងគោលបំណងរួមមួយគឺសម្លាប់ជនរងគ្រោះ។ ជនរងគ្រោះពីបទឃាតកម្មនោះអាចស្លាប់បណ្តាលមកពីជនល្មើសប្រើប្រាស់អាវុធ ប្រើប្រាស់ហិង្សាធ្វើទារុណកម្មរហូតដល់ស្លាប់ ចង ឬច្របាច់ករជនរងគ្រោះរហូតដល់ផុតដង្ហើម ពោលគឺនៅមានរូបភាពនៃការសម្លាប់ផ្សេងៗជាច្រើនទៀត។ ទោះជាយ៉ាងណា នៅពេលដែលសាកសពត្រូវបានរកឃើញ លក្ខណៈដើម ចំនួនរបួស និងកន្លែងរបួស ទីតាំងដែលរកឃើញសាកសព និងលក្ខខណ្ឌផ្សេងៗ អាចជាចំនុចមន្ទិលសង្ស័យចំពោះការស្លាប់ ដែលសមត្ថកិច្ចផ្តោតអារម្មណ៍ពិនិត្យយ៉ាងម៉ត់ចត់។ ដោយហេតុថា ការសម្លាប់ជនរងគ្រោះអាចប្រព្រឹត្តឡើងតាមច្រើនករណី ដូច្នេះពួកយើងសូមធ្វើការសង្ខេបដោយដកស្រង់តែករណីដែលកើតឡើងជាញឹកញាប់តែប៉ុណ្ណោះ។

សម្រាប់សាកសពខ្លះដែលត្រូវបានគេរកឃើញ ហើយមានសញ្ញាណនៃអំពើហឹង្សា នោះគេនឹងធ្វើការពិនិត្យទៅលើមុខរបួស ស្លាកស្នាម ក៏ដូចជាសំលៀកបំពាក់ជនរងគ្រោះ និងចំនុចផ្សេងៗទៀត។ ទាក់ទងទៅនឹងការសង្កេតមុខរបួសសាកសព នៅក្នុងករណីសិក្សាទាំង២ខាងលើ បង្ហាញថា សាកសពទាំង២ករណីនោះសុទ្ធតែមានស្នាមរបួសនៅលើសាកសព។ សម្រាប់ករណីសិក្សាទី១ ដែលកើតឡើងនៅខេត្តកំពត សាកសពក្មេងស្រី "ខ" មានស្នាមរបួសយ៉ាងជំនំនៅត្រង់ ក មុខ និងថ្គាម។ ស្នាមរបួសទាំងនេះ អាចបញ្ជាក់បានថា ក្មេងស្រីរងគ្រោះ "ខ" ច្បាស់ជារងការវាយដំយ៉ាងចាស់ដៃ ពីសំណាក់ជនល្មើស មុននឹងត្រូវគេសម្លាប់។ ម្យ៉ាងវិញទៀត ដោយជនរងគ្រោះនោះជានារីភេទ ហើយខោក្នុងរបស់ក្មេងស្រីនោះត្រូវបានដោះចេញ នេះក៏អាចបង្ហាញបានថា ជនរងគ្រោះអាច

[29] ទំព័រ២៦៧ នៃសៀវភៅឧក្រិដ្ឋនិច្ឆ័យ របស់សាស្ត្រាចារ្យបណ្ឌិត ឯក ឆេងហួត ឆ្នាំ២០០៦

ត្រូវបានគេចាប់រំលោភសេពសន្ថវ។ មន្ត្រីនគរបាលយុត្តិធម៌ ក៏បានវិភាគផងដែលថាតើការសម្លាប់ក្មេងស្រីនោះ អាចបណ្តាលមកពីការលួច ឬប្លន់ ដែរឬទេ? ប៉ុន្តែជាលទ្ធផលសមត្ថកិច្ចយល់ឃើញថាវាមិនអាចជាប់ពាក់ព័ន្ធនឹងការលួច ឬប្លន់ទ្រព្យសម្បត្តិរបស់ជនគ្រោះទេ ព្រោះដោយផ្អែកថាក្មេងស្រីរងគ្រោះនោះមានជីវភាពក្រីក្រ ដូច្នេះក្មេងស្រីរងគ្រោះឈ្មោះ "ខ" នោះ មិនមានសំភារៈមានតម្លៃដែលត្រូវឱ្យជនល្មើសសម្លាប់សម្រាប់លួចវត្ថុនោះទេ។ សរុបជារួម យោងតាមការវិភាគខាងលើ យើងអាចប៉ាន់ស្មានជាបឋមបានថា ក្មេងស្រីរងគ្រោះនោះទំនងជាត្រូវបានគេចាប់បង្ខំរំលោភសេពសន្ថវដោយប្រើអំពើហិង្សា រួចក៏ត្រូវបានជនបង្កនោះសម្លាប់តែម្តង ដើម្បីកុំឱ្យជនរងគ្រោះនោះមានឱកាសប្តឹង ឬរាយការណ៍អំពីបទល្មើសនេះ។

ក្រឡេកមកវិភាគករណីសិក្សាទី២ នៅរាជធានីភ្នំពេញវិញម្តង ឃើញថា សាកសពដែលត្រូវបានគេមិនស្គាល់អត្តសញ្ញាណខាងលើ ត្រូវបានសមត្ថកិច្ចរកឃើញស្នាមរបួសដូចជា ស្នាមបែកមាត់ ស្នាមច្របាច់ក និងស្នាមខាំនៅលើកំភួនដៃស្តាំ។ ផ្អែកលើស្លាកស្នាមទាំងនេះ យើងអាចវិភាគបានថា ច្បាស់ណាស់ប្រាកដជាមានអំពើហិង្សាកើតឡើងទៅលើជនរងគ្រោះ ព្រោះថាស្លាកស្នាមដែលបន្សល់ទុកលើសាកសពនោះ សុទ្ធតែជាស្លាកស្នាមដែលបណ្តាលមកពីការវាយប្រតាប់។ ក្រៅពីនេះ យើងសង្កេតឃើញបានថា សាកសពនោះត្រូវបានប្រទះឃើញទាំងកាយ អាក្រាត ចំនុចនេះ ក៏ជាចំនុចសំខាន់មួយដែរក្នុងការវិភាគថាជនរងគ្រោះបានរងការចាប់រំលោភឬទេ ព្រោះថា ភាគច្រើននារីជនរងគ្រោះដែលបានស្លាប់ទាំងកាយអាក្រាតដូច្នេះ ភាគច្រើនបណ្តាលមកពីរងការចាប់រំលោភ។ ហេតុដូច្នេះ ហើយទើបលោក "ឃ" អធិការខណ្ឌពោធិ៍សែនជ័យ បានឱ្យក្រុមអ្នកជំនាញ ដូចជាក្រុមគ្រូពេទ្យជំនាញ ធ្វើកោសល្យវិច័យទឹកកាម ដើម្បីរកឱ្យឃើញថា ជនរងគ្រោះបានរងការចាប់រំលោភដែរ ឬទេ។

បន្ថែមពីលើករណីសិក្សាទាំង២ខាងលើនេះ សម្រាប់សាកសពដែលមានសញ្ញាណនៃអំពើហិង្សា សាកសពនោះត្រូវបានគេពិនិត្យបន្ថែមទៅលើសំលៀកបំពាក់ បានសេចក្តីថាសំលៀកបំពាក់របស់ជនរងគ្រោះមានសញ្ញាណនៃការដាច់រហែក ឬការបំផ្លាញ ឬមានប្រលាក់សារធាតុផ្សេងៗឬទេ (ស្នាមប្រឡាក់, ខ្លាញ់, ឈាម ជាដើម)។ ប្រសិនបើ គេសង្កេតឃើញសំលៀកបំពាក់ជនរងគ្រោះមានការរហែកនោះ នោះគេអាចទទួលបានតម្រុយនៃការវាយប្រតប់ ឬប្រទាញគ្នាពីបទល្មើសនោះ។ ជាបន្ត គេនឹងធ្វើការវិភាគស្នាមរបួសលើរាងកាយតែម្តងដូចករណីសិក្សាខាងលើ។ ចំពោះស្នាមរបួសលើរាងកាយត្រូវបានគេពិនិត្យមើលទៅលើចំនុចដូចជា[30]៖

[30] ទំព័រ៤៦៨ នៃសៀវភៅឧក្រិដ្ឋនិច្ឆ័យ របស់សាស្ត្រាចារ្យបណ្ឌិត ឯក ឆេងហួត ឆ្នាំ២០០៦

- លក្ខណៈនៃស្នាមរបួស (ស្នាមរបួសជាចំរៀកតូចៗ ស្នាមរបួសជ្រៅ ស្នាមរបួសជាលក្ខណៈខ្វែក ឬស្នាមរបួសជាំខ្មៅ)
- ទីតាំង និងចំងាយពិតប្រាកដទៅសាកសព
- ទំហំនៃស្នាមរបួសជា លក្ខណៈខ្វែង ឬស្នាមរបួសដែលមានប្រវែងវែង និងវិជ្ឈមាត្រស្នាមរបួសដែលមានទំរង់ជារង្វង់ (បើសិនជារបួសនោះប្រឡាក់ដោយសារជាតិ ឬសារធាតុផ្សេងៗ)

សម្រាប់ការពិនិត្យលើស្នាមរបួសនេះ សមត្ថកិច្ចអាចសហការជាមួយពេទ្យជំនាញ ដើម្បីឱ្យពេទ្យជំនាញនោះផ្តល់ព័ត៌មានបន្ថែមទាក់ទងទៅនឹងស្នាមរបួសនោះ ដូចជារបួសនោះបណ្តាលមកការឈឺចាប់ឬទេ ឬរបួសនោះជាសញ្ញានៃការប្រតាយប្រតប់ការពារខ្លួនឬយ៉ាងណា។

ក្រៅពីនេះ មានករណីខ្លះដែលជនល្មើសបានព្យាយាមក្លែងបន្លំបទឃាតកម្មដែលខ្លួនប្រព្រឹត្តទៅជាអំពើមួយដែលជនរងគ្រោះសម្លាប់ខ្លួនឯង។ ឧទាហរណ៍ ការយកសាកសពដែលខ្លួនសម្លាប់យកទៅចងព្យួរក ដើម្បីបន្លំភ្នែកសមត្ថកិច្ចថា ជនរងគ្រោះនោះគឺសម្លាប់ខ្លួនឯងដោយចងករហូតស្លាប់។ ទោះជាយ៉ាងណាក្តី ដូចករណីនេះដែរ សមត្ថកិច្ចមានវិធីជាច្រើនក្នុងការសង្កេតពិនិត្យទៅលើសាកសពនោះ ដើម្បីទទួលបានព័ត៌មានច្បាស់លាស់ជុំវិញការស្លាប់នោះ។ ការពិនិត្យនោះអាចមើលទៅលើ[31]៖

- មិនមានហេតុការណ៍ដូចជា ចំងាយរវាងខ្សែរឹតក និងផ្ទៃរាបស្មើមានប្រវែងវែងជាងកំពស់ជនរងគ្រោះ
- ខ្វះភាពស៊ីគ្នារវាងខ្សែព្យួរ ឬវត្ថុដែលមានលក្ខណៈកខ្វក់ ទៅនឹងដៃរបស់សាកសពដែលមិនកខ្វក់ ក៏ដូចជារវាងផ្ទៃដីកខ្វក់ទៅនឹងជើងរបស់សាកសពដែលមានភាពស្អាត
- ស្នាមរឹតក ដែលមិនស៊ីគ្នាទៅនឹងចង្អូរករ
- ភាពមិនស៊ីគ្នារវាងស្នាមចង្អូររឹតករទៅនឹងឆ្អឹងក
- មានស្នាមកាត់ឱ្យរបួសនៅពេលដាក់សាកសពដល់កន្លែងព្យួរក
- ទីតាំងឈាម និងអង្គជាតិទឹករងៃខុសពីកន្លែងរបួស (ដូចជាឈាមប្រឡាក់លើផ្ទៃមុខនៃសាកសពដែលត្រូវបានព្យួរក)។

ចំនុចទាំងអស់នេះ ជាចំណុចគោលៗដែលសមត្ថកិច្ចភាគច្រើនពិនិត្យទៅលើចំណុចទាំងអស់នោះ ជាការជៀសវាងពីការលាក់បាំងបទល្មើសដែលជនល្មើសបានប្រព្រឹត្ត។

[31] ទំព័រ៤៦៩ នៃសៀវភៅឧក្រិដ្ឋនិច្ច័យ របស់សាស្ត្រាចារ្យបណ្ឌិត ឯក ឆេងហួត ឆ្នាំ២០០៦

## ផ្នែកទី៥ :ការស្តាប់ចម្លើយ

ការស្តាប់ចម្លើយ ក៏ជាកត្តាមួយក្នុងការវិភាគបទឃាតកម្មមួយឱ្យបានជម្រៅ និងកាន់តែច្បាស់លាស់។ មន្ត្រីនគរបាលយុត្តិធម៌ អាចសាកសួរបុគ្គលគ្រប់រូប ដែលខ្លួនយល់ឃើញថា បុគ្គលនោះជាប់សង្ស័យពាក់ព័ន្ធទៅនឹងបទឃាតកម្មដែលបានកើតឡើងនោះ ឬបុគ្គលដែលអាចផ្តល់ព័ត៌មានជុំវិញបទឃាតកម្មនោះ។ មន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ច ក៏អាចសាកសួរចម្លើយជាបឋមផងដែរទៅលើអនីតិជនដែលបានប្រព្រឹត្តបទឃាតកម្មនោះ។ រាល់ចម្លើយទាំងឡាយដែលប្រមូលបានពីបុគ្គលទាំងនោះ សុទ្ធតែអាចដាក់ជាភស្តុតាងនៅក្នុងរឿងក្តីនោះផងដែរ។

### កថាខណ្ឌទី១ : ការស្តាប់ចម្លើយរបស់ជនសង្ស័យ បុគ្គលពាក់ព័ន្ធ និងបុគ្គលដែលអាចផ្តល់ព័ត៌មានជុំវិញបទល្មើស

ការស្តាប់ចម្លើយ គឺពិតជាមានភាពចាំបាច់ណាស់នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ព្រោះតាមរយៈការសាកសួរ អាចនាំឱ្យទទួលបាននូវតម្រុយព័ត៌មានបន្ថែម ឬអាចទទួលបានការសារភាពទោសជាដើម។ ប្រសិនបើបទឃាតកម្មនោះជាបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំខ្លួនមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស ដើម្បីសាកសួរ និងស្តាប់ចម្លើយរបស់ជននោះ [32]។ ខុសគ្នាបន្តិចចំពោះបទល្មើសមិនជាក់ស្តែង ក្នុងកិច្ចស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការកោះហៅ និងស្តាប់ចម្លើយជនណាដែលទាក់ទិនក្នុងបទល្មើសនោះ ប៉ុន្តែករណីមិនព្រមចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា ដើម្បីចេញបញ្ជាឱ្យចូលខ្លួន ដែលបញ្ជានេះប្រគល់អំណាចដល់មន្ត្រីនគរបាលយុត្តិធម៌អាចប្រើកម្លាំងសាធារណៈបង្ខំឱ្យជនចូលខ្លួន[33]។

*<u>ករណីសិក្សាទី៣</u>*

រឿងក្តីឃាតកម្មដ៏សាហាវមួយបានកើតឡើងទៅលើក្មេងស្រី "ល" អាយុ ៩ឆ្នាំ នៅខេត្តកណ្តាល ភូមិទំលប់ខ្ពស់ជើង។

អង្គុយនៅក្រោមផ្ទះក្នុងខេត្តកណ្តាល ភូមិទំលប់ខ្ពស់ជើង អ្នកស្រី "ស" ជាម្តាយរបស់ក្មេងស្រីរងគ្រោះអាយុ ៩ឆ្នាំខាងលើ មានអារម្មណ៍ខឹងច្រើនជាងពិបាកចិត្ត។ ប៉ុន្មានថ្ងៃមុន កូនស្រីរបស់គាត់អាយុ ៩ឆ្នាំ ឈ្មោះ "ល" ត្រូវបានរងការវាយដំរហូតដល់ស្លាប់នៅក្នុងវាលស្រែនៅក្បែរនោះ។

[32] មាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[33] មាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បន្ទាប់ពីប៉ូលីសបានចាប់ខ្លួនឈ្មោះ "ភ" អាយុ ១៦ឆ្នាំ ដែលជាអ្នកជិតខាងរបស់ក្មេងស្រីរងគ្រោះ ជនសង្ស័យឈ្មោះ "ភ" នោះបានសារភាពថាបានសម្លាប់ក្មេងស្រីនោះ ដើម្បីយកក្រវិលមាស និងចិញ្ចៀនមួយ យកទៅលក់នៅផ្សារក្បែរនោះ បានតម្លៃ ២៨ដុល្លារអាមេរិច។

ប៉ូលីសបានបង្ហាញថា ក្មេងស្រីរងគ្រោះ "ល" បានបាត់ខ្លួនកាលពីរសៀលថ្ងៃសុក្រសប្ដាហ៍មុន រីឯឈ្មោះ "ភ" ខាងលើនោះបានជួយក្នុងការស្វែងរកក្មេងស្រីនោះ ប៉ុន្តែបន្ទាប់ពីសាកសពរបស់ក្មេងស្រី "ល" ត្រូវបានរកឃើញនៅវេលាម៉ោង ៧ល្ងាចថ្ងៃបន្ទាប់ ស្រាប់តែឈ្មោះ "ភ" នោះបានទៅលាក់ខ្លួននៅក្នុងចំការមួយកន្លែង ក្រោយមកជនសង្ស័យនោះក៏ត្រូវបានរកឃើញ និងចាប់ខ្លួននៅវេលាយប់នោះតែម្ដង[34]។

សង្កេតទៅលើករណីសិក្សាទី៣ខាងលើនេះ ជនសង្ស័យ "ភ" ដែលមានអាយុ ១៦ឆ្នាំ ជាអនីតិជនត្រូវចាប់ខ្លួន និងសួរចម្លើយជុំវិញករណីឃាតកម្មសម្លាប់ក្មេងស្រី "ល" អាយុ ៩ឆ្នាំនៅខេត្តកណ្ដាល។ វាជាកត្តាមួយគួរឱ្យសង្ស័យណាស់នៅពេលដែលជនសង្ស័យនោះបានបាត់ខ្លួននៅពេលប្រទះឃើញសាកសព ចំនុចនេះក៏គួរឱ្យពិចារណាដែលថា "ហេតុអ្វីបានជាឈ្មោះ "ភ" នោះបានចូលរួមជួយសមត្ថកិច្ចក្នុងការស្វែងរកក្មេងស្រីនោះ ប៉ុន្តែបែរជាបាត់ខ្លួននៅពេលរកឃើញសាកសពក្មេងស្រីនោះ។ ក្រោយពីការសួរចម្លើយរបស់សមត្ថកិច្ច ជនសង្ស័យឈ្មោះ "ភ" នោះបានសារភាពថា ខ្លួនពិតជាបានសម្លាប់ក្មេងស្រីរងគ្រោះឈ្មោះ "ល" នោះពិតប្រាកដមែន ដើម្បីលួចក្រវិលមាស និងចិញ្ចៀនមួយរបស់ជនរងគ្រោះយកទៅលក់។ តាមរយៈចម្លើយសារភាពនេះ មន្ត្រីសមត្ថកិច្ចអាចយោងចម្លើយនោះជាភស្តុតាងដាក់បន្ទុកដ៏រឹងមាំទៅលើជនសង្ស័យឈ្មោះ "ភ" នោះ។

ប្រសិនបើក្នុងករណីជនសង្ស័យដែលបានឃាត់ខ្លួននោះពុំបានឆ្លើយសារភាពទេ តើមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើចំណាត់ការបន្តយ៉ាងដូចម្ដេច? ឆ្លើយតបទៅនឹងសំនួរនេះ យើងអាចក្រឡេកទៅមើលករណីសិក្សាទី១ ក្នុងខេត្តកំពតវិញ។ នៅក្នុងអង្គហេតុនៃករណីសិក្សាទី១ ឃើញថា ជនសង្ស័យទី១ និងជនសង្ស័យទី២ ត្រូវបានមន្ត្រីនគរបាលយុត្តិធម៌សួរចម្លើយយ៉ាងម៉ត់ចត់ដើម្បីទទួលបានព័ត៌មានជុំវិញបទឃាតកម្មដែលបានកើតឡើងលើយុវនារី "ខ"។ នៅមុនពេលសួរចម្លើយ ជនសង្ស័យទាំង២ នោះទទួលបាននូវឱកាសក្នុងការសន្ទនា ឬទំនាក់ទំនងរយៈពេល ៣០នាទីជាមួយអ្នកតំណាងដែលច្បាប់បានកំនត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច និងមេធាវីជាលក្ខណៈឯកជន និងសម្ងាត់ លើកលែងជនទាក់ទិនក្នុងបទល្មើស[35]។ ក្នុងការស្ដាប់ចម្លើយត្រូវប្រព្រឹត្ត

[34] ដកស្រង់ និងបកប្រែសង្ខេប ចេញពីគេហទំព័រ https://www.cambodianchildrensfund.org/news/child-protection-unit-despite-confession-girls-murder-still-a-mystery-phnom-penh-post/

[35] មាត្រា២១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ដោយមានវត្តមានមេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី ម្យ៉ាងវិញទៀត អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច មានសិទ្ធិចូលរួម ប៉ុន្តែមន្ត្រីនគរបាលអាចមិនអនុញ្ញាតឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួម ករណីការចូលរួមនោះផ្ទុយឧត្តមប្រយោជន៍របស់អនីតិជនទាំង២នោះ[36]។ ក្នុងការស្តាប់ចម្លើយរបស់ជនសង្ស័យទាំង២ ពួកគេពុំបានសារភាពថាខ្លួនជាអ្នកប្រព្រឹត្តនោះទេ។ ចំណុចនេះ យើងអាចវិភាគចេញបានជា២ហេតុផល៖ ហេតុផលទី១ គឺ ជនទាំង២ពុំមែនជាឃាតករពិតប្រាកដទើបពួកគេមិនសារភាពថាខ្លួនជាអ្នកប្រព្រឹត្ត និងហេតុផលទី២ គឺ ជនទាំង២នោះបានប្រព្រឹត្តនូវបទល្មើសនោះ ប៉ុន្តែមានចេតនាមិនសារភាពទោស។ ទោះជាយ៉ាងណាក៏ដោយ ជនសង្ស័យទាំង២ក៏មិនអាចត្រូវបង្ខំឱ្យសារភាព ឬទទួលទារុណកម្មឱ្យសារភាពនោះទេ។ លើសពីនេះ ការចោទប្រកាន់ជនណាមួយ មិនអាចធ្វើឡើងតាមការប៉ាន់ស្មាននោះទេ ពោលគឺទាមទារឱ្យមានភស្តុតាង ឬសាក្សីគ្រប់គ្រាន់ដែលឆ្លុះបញ្ចាំងពីពិរុទ្ធភាពនៃជនសង្ស័យនោះឱ្យបានច្បាស់។ អាស្រ័យហេតុនេះហើយ ទើបមន្ត្រីនគរបាលយុត្តិធម៌ខេត្តកំពតបានខិតខំរកភស្តុតាងបន្ថែម ដើម្បីបញ្ជាក់ថាជនទាំងពីរនោះបានប្រព្រឹត្តនូវបទឃាតកម្មនោះពិត ឬយ៉ាងណា មុននឹងពួកគាត់បន្តនីតិវិធី។ អ្វីដែលមិនអាចខ្វះបាន គឺការធ្វើកំណត់ហេតុ ដោយកត់នូវរាល់ចម្លើយដែលជនសង្ស័យទាំង២បានផ្តល់ឱ្យប្រកបដោយភាពត្រឹមត្រូវ និងភាពមិនលំអៀង។ ក្រោយពីបញ្ចប់ការសាកសួរ និងធ្វើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកបកប្រែអាននូវកំណត់ហេតុនោះ រួចឱ្យអនីតិជនដែលបានឆ្លើយនោះចុះហត្ថលេខា ឬផ្តិតស្រាមមេដៃនៅលើទំព័រនីមួយៗ។ ផ្ទុយទៅវិញ បើអនីតិជននោះមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមមេដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនោះ។ អនីតិជន នោះក៏អាចស្នើសុំឱ្យកែប្រែ ឬបន្ថែមបន្ថយចម្លើយរបស់ខ្លួនដែលបានឆ្លើយ។ នៅក្នុងកំណត់ហេតុនោះផងដែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យសមាសភាពផ្សេងទៀតដែលចូលរួមស្តាប់ដូចជា អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចចុះហត្ថលេខា ឬផ្តិតមេដៃ ប៉ុន្តែបើជនទាំងនោះមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែចុះនិទ្ទេសក្នុងកំណត់ហេតុនោះ[37]។

ក្រៅពីនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចកោះហៅនូវរាល់បុគ្គលគ្រប់រូបដែលអាចផ្តល់ព័ត៌មានជុំវិញបទល្មើសបានកើតឡើងនោះ។ ជាបឋម ការកោះហៅ ត្រូវឡើងដោយសន្តិវិធី បានន័យថា មន្ត្រីនគរបាលយុត្តិធម៌ ធ្វើការកោះហៅបុគ្គលនោះឱ្យចូលខ្លួនដោយស្ម័គ្រចិត្ត ប៉ុន្តែបើបុគ្គលនោះបដិសេធ ឬមានភាពរឹងទទឹងក្នុងការចូលខ្លួនតាមការកោះហៅ មន្ត្រីនគរបាលយុត្តិធម៌

[36] មាត្រា២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[37] មាត្រា២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា។ ក្រោយពីទទួលដំណឹង ព្រះរាជអាជ្ញាអាចចេញបញ្ជាឱ្យជននោះចូលខ្លួនមកបំភ្លឺ។ អនុលោមតាមមាត្រា៩៤ និងមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលទទួលបានបញ្ជាឱ្យចូលខ្លួនពីព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌អាចប្រើកម្លាំងសាធារណៈបង្ខំឱ្យបុគ្គលដែលបានដឹងព័ត៌មានទាក់ទងបទល្មើសចូលខ្លួនបំភ្លឺ និងផ្តល់ចម្លើយទៅតាមការសាកសួរ។

**កថាខណ្ឌទី២: សិទ្ធិមូលដ្ឋានដែលអនីតិជនទទួលបាន**

ថ្វីត្បិតតែមន្ត្រីនគរបាលយុត្តិធម៌អាចសាកសួរអនីតិជន ដែលបានប្រព្រឹត្តនូវបទឃាតកម្មនោះពិតមែន ក៏ប៉ុន្តែនៅមុនពេលស្តាប់ចម្លើយអនីតិជនរូបនោះ មន្ត្រីនគរបាលត្រូវរៀបរាប់នូវសិទ្ធិមូលដ្ឋានដែលអនីតិជននោះទទួលបាននៅក្នុងអំឡុងពេលនីតិវិធីសាកសួរនេះ។ សិទ្ធិមូលដ្ឋាននោះមានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ នៅត្រង់មាត្រា៦ ដែលមានខ្លឹមសារដូចតទៅ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួញពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឱ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តិជាធរមាន។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរព និងប្រតិបត្តិនូវរាល់សិទ្ធិដែលអនីតិជនទទួលបានតាមច្បាប់នេះ។

### ផ្នែកទី៦ : ការឃាត់ខ្លួន និងការបញ្ជូនខ្លួនជនសង្ស័យជាអនីតិជន

ជាទូទៅ ភាគច្រើននៃបទឃាតកម្ម ជនបង្កតែងតែព្យាយាមបំបាត់នូវរាល់ភស្តុតាងនានា ដើម្បីរួចខ្លួនពីការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរតាមផ្លូវច្បាប់។ ដូច្នេះ ដើម្បីបញ្ចៀសពីភាពអយុត្តិធម៌ដែលកើតឡើងដោយការគេចខ្លួន ឬបំផ្លាញភស្តុតាងក្នុងគោលបំណងរួចខ្លួនពីសំណាញ់ច្បាប់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានច្បាប់អនុញ្ញាតឱ្យធ្វើការឃាត់ខ្លួនជនល្មើសនោះ។ ទោះបីជាអនីតិជនជាជនល្មើសពិតមែន ការឃាត់ខ្លួនត្រូវធ្វើឡើងដោយគោរពទៅតាមលក្ខខណ្ឌនៃការឃាត់ខ្លួនអនីតិជនដែលច្បាប់បានកំណត់ ។ ទោះជាមានការឃាត់ខ្លួនក៏ដោយ ក៏គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន តាមអំពើចិត្តឡើយ[38] ។

#### កថាខណ្ឌទី១ : លក្ខខណ្ឌនៃការឃាត់ខ្លួនអនីតិជន

អាយុរបស់អនីតិជន ក៏ជាលក្ខខណ្ឌដ៏សំខាន់មួយផងដែរក្នុងការឃាត់ខ្លួនឱ្យត្រឹមត្រូវតាមផ្លូវច្បាប់។ យើងបានស្វែងយល់រួចរាល់មកហើយនូវពាក្យ"អនីតិជន" ជាជនដែលមានអាយុក្រោម ១៨ឆ្នាំ។ ចាប់ពីអាយុក្រោម ១៨ឆ្នាំចុះ ច្បាប់បានកំណត់នូវចន្លោះអាយុដែលមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជននោះបាន។ ចំពោះអនីតិជនណាដែលមានអាយុក្រោម ១៤ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់[39]។ ក្នុងករណីនេះ មន្ត្រីនគរបាលត្រូវតែបញ្ជូនសំណុំទៅរឿងទៅព្រះរាជអាជ្ញាភ្លាមសម្រាប់ចំណាត់ការបន្ទាប់។ រីឯ អនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនរូបនោះ ប្រសិនជាខ្លួនយល់ឃើញថាអនីតិជននោះអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬ បង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ[40]។

លក្ខខណ្ឌជាបន្ទាប់ គឺទាក់ទងទៅនឹងរយៈពេលដែលអាចឃាត់ខ្លួនអនីតិជនរូបនោះ។ សម្រាប់បទឧក្រិដ្ឋដូចជាបទឃាតកម្ម អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។ រីឯ អនីតិជនមានអាយុពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសពី ៤៨ម៉ោងឡើយ[41]។

---

[38] មាត្រា ៥ និង មាត្រា ៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័តនៅថ្ងៃទី ១០ ធ្នូ ១៩៤៨ ។

[39] មាត្រា១៤ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[40] មាត្រា១៧ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[41] មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ក្រោយពីការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬ ដល់អ្នកទទួលភារកិច្ចលើអនីតិជននោះ[42]។ ការជូនដំណឹង ដើម្បីឱ្យបុគ្គលទាំងនោះទទួលជ្រាបជាព័ត៌មាន និងសម្រាប់ត្រៀមរៀបចំ ស្វែងរកមេធាវីសម្រាប់ការពារអនីតិជនរូបនោះ។

**កថាខណ្ឌទី២ : ការសម្រេចបញ្ជូនខ្លួនអនីតិជន និងសំណុំរឿងទៅព្រះរាជអាជ្ញា**

ការបញ្ជូនខ្លួនអនីតិជនទៅព្រះរាជអាជ្ញា ជានីតិវិធីបន្ទាប់ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា។ ក្រោយពីមន្ត្រីនគរបាលយុត្តិធម៌ប្រមូលបានភស្តុតាងគ្រប់គ្រាន់ហើយ មន្ត្រីនគរបាលត្រូវតែបញ្ជូនខ្លួនអនីតិជនដែលជាជនល្មើស រួមទាំងសំណុំរឿងបន្តទៅព្រះរាជអាជ្ញាសម្រាប់ចំណាត់ការបន្ត។ ការបញ្ជូនខ្លួន និងសំណុំរឿងនេះអាចធ្វើឡើងតាមសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែប្រតិបត្តិតាមសេចក្តីសម្រេចនោះ។

ជាក់ស្តែងដូចករណីសិក្សាទី៣ នៅខេត្តកណ្តាលខាងលើ ជនសង្ស័យឈ្មោះ "ភ" អាយុ ១៦ឆ្នាំ បានសារភាពនូវអំពើដែលខ្លួនបានប្រព្រឹត្ត គឺបានសម្លាប់ក្មេងស្រីរងគ្រោះ "ល" អាយុ ៩ឆ្នាំ ដើម្បីយកក្រវិលមាស និងចិញ្ចៀនជនរងគ្រោះយកទៅលក់។ ផ្អែកលើចម្លើយសារភាពនេះ មន្ត្រីនគរបាលយុត្តិធម៌ខេត្តកណ្តាល អាចកសាងសំណុំរឿងបញ្ជូនទៅឱ្យអង្គការអយ្យការខេត្តកណ្តាលសម្រាប់ធ្វើការចោទប្រកាន់ និងបន្តនីតិវិធីតាមផ្លូវច្បាប់។

**កថាខណ្ឌទី៣ : ការដោះលែងឱ្យមានសេរីភាព**

នៅក្នុងដំណាក់កាលនេះ ប្រសិនកាលណាក្នុងថិរវេលានៃការឃាត់ខ្លួនអនីតិជនរូបនោះអស់ ប៉ុន្តែនៅតែពុំទាន់បានស្វែងរកភស្តុតាងដាក់បន្ទុកបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍អំពីបញ្ហានេះទៅកាន់ព្រះរាជអាជ្ញា ដើម្បីគាត់សម្រេចដោះលែង ឬយ៉ាងណា។ ដោយឡែកចំពោះអនីតិជនមានលក្ខណៈពិសេសខុសពីនីតិជនបន្តិចត្រង់ថា រយៈពេលនៃការឃាត់ខ្លួនរបស់អនីតិជនមិនអាចត្រូវបានពន្យារបានឡើយ។ ដូច្នេះ នៅពេលដែលមិនអាចស្រាវជ្រាវទទួលបានភស្តុតាងដាក់បន្ទុកបានទេ អនីតិជនរូបនោះអាចនឹងត្រូវបានដោះលែងឱ្យមានសេរីភាព ព្រោះបុគ្គលគ្រប់រូបមិនអាចត្រូវបានគេចោទប្រកាន់ឱ្យទទួលទោស ដោយពុំមានភស្តុតាងសំអាងពីពិរុទ្ធភាពនៃជននោះ។

ផ្អែកទៅលើទ្រឹស្តីច្បាប់ខាងលើ ឃើញថាសម្រាប់ករណីសិក្សាទី១ ក្នុងខេត្តកំពត មន្ត្រីសមត្ថកិច្ចនៅក្នុងមូលដ្ឋាននោះបានខិតខំរកភស្តុតាង និងតម្រុយបន្ថែម ដើម្បីជានាដល់ភាពយុត្តិធម៌នៅក្នុងរឿងក្តីនោះ។ ជាលទ្ធផល សមត្ថកិច្ចបានឈានដល់ការរកឃើញនូវជនសង្ស័យទី៣

[42] មាត្រា១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជាមួយនិងភស្តុតាងដែលឆ្លុះបញ្ចាំងថាជនសង្ស័យទី៣នោះគឺជាឃាតករពិត ដោយឃើញមានស្នាមឈាមប្រលាក់លើកអាវ និងមានស្នាមដាច់រលាត់នៅលើមុខ និងក របស់ជនសង្ស័យទី៣នោះ។ ផ្អែកលើចំនុចនេះតែមួយ មិនយកមកសំអាងក្នុងការដោះលែងជនសង្ស័យទី១ និងជនសង្ស័យទី២ទេ គឺមានការបូកផ្សំជាមួយនឹងកត្តាជាច្រើនដូចជា ចម្លើយដែលផ្តល់ឱ្យរបស់ជនសង្ស័យទី១ និងជនសង្ស័យទី២ ក្នុងអំឡុងពេលសួរចម្លើយឆ្លុះបញ្ចាំងថាជនទាំង២នោះ ជាជនស្អាតស្អំ។ ជាពិសេសនោះ សមត្ថកិច្ចពុំបានរកឃើញនូវភស្តុតាងដែលបង្ហាញពីពិរុទ្ធភាពរបស់ជនសង្ស័យទាំង២នោះទេ។ ដូច្នេះហើយ កត្តាទាំងអស់នោះហើយជាមូលហេតុនាំឱ្យសមត្ថកិច្ចសម្រេចធ្វើការដោះលែងជនសង្ស័យទី១ និងជនសង្ស័យទី២ ប៉ុន្តែការដោះលែងនេះពុំមែនជាកត្តានាំឱ្យមានអាជ្ញាអស់ជំនុំនោះទេ។ ជនសង្ស័យទាំង២នោះនៅតែអាចគេចាប់ខ្លួន និងចោទប្រកាន់ នៅពេលដែលសមត្ថកិច្ចស្វែងរកឃើញភស្តុតាង ដែលអាចបញ្ជាក់អំពីពិរុទ្ធភាពរបស់ពួកគេបានពេលក្រោយ។

## ជំពូកទី២ : ការសម្រេចរបស់អង្គការអយ្យការលើការចោទប្រកាន់បទល្មើស

អង្គការអយ្យការ ជាម្ចាស់បណ្ដឹងអាជ្ញា ដែលទទួលបន្ទុកក្នុងការចោទប្រកាន់បទល្មើស។ អង្គការអយ្យការ មានគ្រប់បណ្ដារាជធានី-ខេត្ត ដែលមានវិសាលភាពគ្របដណ្ដប់លើដែនដីរាជធានីខេត្តដែលអង្គការនោះតាំងនៅ។ អង្គការអយ្យការមានសមាសភាពដូចជា ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានី-ខេត្តនោះ។ អង្គការអយ្យការនេះធ្វើការចោទប្រកាន់ពី បទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[43]។ នៅពេលដែលសំណុំរឿងបានមកដល់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញាមានជម្រើសនៃការចោទប្រកាន់ដូចជាការសម្រេចតម្កល់រឿងឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើស ប៉ុន្តែប្រសិនបើ ព្រះរាជអាជ្ញាយល់ឃើញថាមានភាពខ្វះខាតភស្តុតាង ឬភាពចាំបាច់នានា ព្រះរាជអាជ្ញាអាចបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម[44]។ ដរាបណាកំហុស ឬបទល្មើសរបស់ អនីតិជនពុំបានរកឃើញទេនោះ អនីតិជននោះត្រូវចាត់ទុកថាគ្មានកំហុស។ ហេតុនេះ ទើបទាមទារឱ្យមានការស្រាវជ្រាវ ឬស៊ើបអង្កេតបន្ថែម ជៀសវាងភាពអយុត្តិធម៌កើតមានឡើង។

### ផ្នែកទី១ : ការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ ជានីតិវិធីមួយដែលផ្អាកការចោទប្រកាន់ ឬដំណើរការនៃសំណុំរឿងនោះ។ ការតម្កល់រឿងឥតចាត់ការ ជាសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា បានន័យថា មានតែព្រះរាជអាជ្ញាទេ ដែលជាអ្នកមានសិទ្ធិសម្រេចក្នុងតម្កល់រឿងទុកឥតចាត់ការ។ ទោះជាយ៉ាងណាសិទ្ធិអំណាចនៃការសម្រេចនោះក៏ត្រូវផ្អែកលើសំអាងច្បាប់ និងសំអាងហេតុឱ្យសមស្របផងដែរ ទើបអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ[45]។

#### កថាខណ្ឌទី១ : លក្ខខណ្ឌនៃការតម្កល់រឿងទុកឥតចាត់ការ

ជាគោលការណ៍ ដើម្បីតម្កល់រឿងទុកឥតចាត់ការ លុះត្រាតែរឿងនោះត្រូវមានសំអាងហេតុ និងសំអាងច្បាប់ឱ្យបានត្រឹមត្រូវ។ ការតម្កល់ទុកឥតចាត់ការនេះ ពុំមានអាជ្ញាអស់ជំនុំទេ បានន័យថា ព្រះរាជអាជ្ញាមានសិទ្ធិសើរើកែប្រែសេចក្ដីសម្រេចនេះឡើងវិញ ដរាបណាអាជ្ញាយុកាលនៃការផុតរលត់បណ្ដឹងអាជ្ញាមិនទាន់បញ្ចប់[46]។

អាយុរបស់អនីតិជនដែលជាជនជាប់សង្ស័យបានចូលរួមប្រព្រឹត្តបទល្មើស ក៏ជាលក្ខខណ្ឌមួយផងដែរក្នុងការតម្កល់រឿងឥតចាត់ការ។ លក្ខខណ្ឌនេះ មិនមែនអនុវត្តទៅលើគ្រប់អនីតិជន

---

[43] មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[44] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[45] មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[46] មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នោះទេ បានសេចក្តីថា ច្បាប់បានកំណត់កម្រិតនៃអាយុរបស់អនីតិជនដែលព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការ។ មានតែ អនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើសប៉ុណ្ណោះ ទើបព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម[47]។ ក្នុងករណីដែលអនីតិជនពុំមានអ្នកតំណាងស្របច្បាប់ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវសុំសិទ្ធិអាណាព្យាបាលលើអនីតិជននោះតាមផ្លូវតុលាការ ដើម្បីធ្វើជាអាណាព្យាបាលលើអនីតិជននោះ។ សរុបមក ក្រៅពីលក្ខខណ្ឌអាយុនេះ ព្រះរាជអាជ្ញាត្រូវសង្កេតទៅលើសំអាងច្បាប់និងសំអាងហេតុ មុនសម្រេចតម្កល់រឿងឥតចាត់ការ។ ក្រោយពីសម្រេចតម្កល់រឿងឥតចាត់ការព្រះរាជអាជ្ញាត្រូវជូនដំណឹងនេះឱ្យអ្នកប្តឹងក្នុងរយៈពេលយ៉ាងខ្លី ហើយយ៉ាងយូរបំផុតរយៈពេល២ខែគិតពីថ្ងៃចុះពាក្យប្តឹង[48]។ សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ មិនអាចជាកម្មវត្ថុក្នុងការហាមឃាត់មិនឱ្យជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ទាមទារសំណងរដ្ឋប្បវេណីបានទេ។ ជនគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យបណ្តឹងទៅតុលាការរដ្ឋប្បវេណី ដើម្បីទាមទារសំណងរដ្ឋប្បវេណីឱ្យសមាមាត្រទៅនឹងព្យសនកម្មដែលខ្លួនទទួល។

### កថាខណ្ឌទី២ : ការប្តឹងតវ៉ានឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ

នៅពេលដែលសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការត្រូវបានដាក់ចេញ ប្រាកដណាស់វាមានអានុភាពឱ្យគូភាគីអនុវត្តតាមសេចក្តីសម្រេចនោះ។ យ៉ាងណាមិញ សេចក្តីសម្រេចនោះមិនមានលក្ខណៈបិទផ្លូវតវ៉ានោះទេ។ ភាគីណាដែលមិនពេញចិត្តទៅនឹងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ភាគីនោះគាត់មានសិទ្ធិប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា។ ពាក្យបណ្តឹងជំទាស់នោះត្រូវធ្វើឡើងតាមបណ្តឹងសាមញ្ញ នៅអង្គការអយ្យការ ក្នុងរយៈពេល ២ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងឥតចាត់ការ ដើម្បីឱ្យសំណុំរឿងបញ្ជូនភ្លាមទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍សម្រាប់ពិនិត្យ[49]។ ក្រោយពីពិនិត្យ លទ្ធផលសម្រេចអាចមានដូចជា៖

- ក្នុងករណីគាត់ពិនិត្យឃើញថាការតវ៉ាមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់

[47] មាត្រា២៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[48] មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[49] មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- ផ្ទុយមកវិញ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថាសេចក្តីសម្រេចតម្កល់រឿងឥតចាត់ការនោះត្រឹមត្រូវ ឬការតវ៉ានោះគ្មានមូលហេតុសមរម្យ នោះគាត់នឹងសម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ ហើយវាមានអនុភាពអនុវត្តបន្តទៀត។

ទោះបីជា សេចក្តីសម្រេចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យ៉ាងណាក៏ដោយ ក៏អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវតែឱ្យដំណឹងទៅអ្នកប្តឹងតវ៉ា។

**ផ្នែកទី២ : ការសម្រេចចោទប្រកាន់**

ក្រោយពីពិនិត្យទៅលើសំណុំរឿងរបស់អនីតិជន និងភស្តុតាងនានាដែលបានដាក់ជូនមកព្រះរាជអាជ្ញានឹងធ្វើការថ្លឹងថ្លែងថាគួរសម្រេចចោទប្រកាន់ ឬតម្កល់រឿងឥតចាត់ការ។ ប្រសិនបើពិនិត្យឃើញថាអនីតិជនដែលបញ្ជូនខ្លួនមក ពិតជាបានប្រព្រឹត្តបទឃាតកម្មនោះ ឬភាគរយដែលសង្ស័យថាអនីតិជននោះបានប្រព្រឹត្តនោះគឺខ្ពស់ ព្រះរាជអាជ្ញានឹងសម្រេចចោទប្រកាន់ទៅលើជននោះតែម្តង និងអនុវត្តតាមនីតិវិធីបន្ត។ ជាទូទៅ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាមៈ

- ការបើកធ្វើការស៊ើបសួរ
- ការបញ្ជូនទៅជំនុំជម្រះ ឬ
- តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួន[50]។

ក្នុងករណីជនត្រូវចោទជាអនីតិជន ដូច្នេះព្រះរាជអាជ្ញាមិនអាចធ្វើការបញ្ជូនទៅជំនុំជម្រះតែម្តងបានទេ ដោយសារនីតិវិធីនេះអាចអនុវត្តបានតែទៅលើនីតិជនតែប៉ុណ្ណោះ[51]។ ដូច្នេះ នីតិវិធីបន្ទាប់ត្រូវតែបើកការស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ កុមារដែលត្រូវចោទ ឬជាប់ចោទ ថាបានរំលោភច្បាប់ព្រហ្មទណ្ឌយ៉ាងហោចណាស់ ត្រូវទទួលបាននូវការធានាដូចតទៅ ៖

ក. ចាត់កុមារថាឥតទោស រហូតទាល់តែពិរុទ្ធភាពត្រូវបានបង្ហាញស្របតាមច្បាប់ ។

ខ. ប្រាប់កុមារភ្លាមៗ និងដោយផ្ទាល់ អំពីបទចោទមកលើខ្លួន ឬបើសមស្របប្រាប់តាមរយៈឪពុកម្តាយ ឬអ្នកអាណាព្យាបាល និងផ្តល់ជំនួយសមស្របផ្សេងទៀតសម្រាប់ការរៀបចំ និងដាក់ចេញនូវមធ្យោបាយការពារខ្លួន ។

គ. ទទួលបានការដោះស្រាយបញ្ហាដោយ គ្មានការយឺតយ៉ាវ ពីសំណាក់អាជ្ញាធរ ឬស្ថាប័នតុលាការ ដែលមានសមត្ថកិច្ចឯករាជ្យនឹងមិនលំអៀងនៅក្នុងការជំនុំជម្រះដ៏យុត្តិធម៌មួយដែលស្របទៅតាមច្បាប់ ។

[50] មាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[51] មាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ក្នុងករណីសមស្របនិងចាំបាច់ វិធានការសម្រាប់ដោះស្រាយចំពោះកុមារទាំងនេះមិនចាំបាច់ឆ្លងកាត់នីតិវិធីតុលាការឡើយ ឱ្យតែធានា និងគោរពបានពេញលេញនូវសិទ្ធិមនុស្ស និងការធានាខាងផ្លូវច្បាប់[52]។

### កថាខណ្ឌទី១ : ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ជាដីកាដែលចេញដោយព្រះរាជអាជ្ញាដែលបញ្ជូនសំណុំរឿងទៅឱ្យចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបសួរបន្ត។ នៅក្នុងករណីខ្លះ នីតិជនត្រូវបានបញ្ជូនទៅជំនុំជម្រះតែម្តង ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ ឬរឿងក្តីនោះមានលក្ខណៈគ្រប់គ្រាន់សម្រាប់បើកការជំនុំជម្រះ។ ដោយឡែក ចំពោះអនីតិជនដែលបានប្រព្រឹត្តបទឃាតកម្មវិញ អនីតិជនរូបនោះមិនអាចត្រូវបានគេនាំខ្លួនឱ្យចូលបង្ហាញខ្លួនភ្លាម នៅចំពោះមុខអង្គជំនុំជម្រះរបស់សាលាដំបូងរាជធានី-ខេត្តបានទេ ព្រោះវាមិនបំពេញលក្ខខណ្ឌស្របតាមមាត្រា ៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ម្យ៉ាងវិញទៀត ដោយបទឃាតកម្មជាបទឧក្រិដ្ឋ ដូច្នេះសំណុំរឿងនោះត្រូវតែបើកការស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ប្តឹងទៅចៅក្រមស៊ើបសួរ[53]។ ទម្រង់នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរនោះ ត្រូវតែគោរពទៅតាមលក្ខណៈដែលមានចែងក្នុងមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បើពុំដូច្នេះទេ ដីកានោះត្រូវចាត់ទុកជាមោឃៈ។ លក្ខណៈទម្រង់នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរនោះមាន៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន

ក្រៅពីនេះដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ក្រោយពីដាក់បញ្ចូលនូវចំនុចដែលបានរៀបរាប់ខាងលើនេះរួចរាល់ហើយ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនោះនឹងមានអានុភាពឱ្យចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរទៅលើអនីតិជននោះតែម្តង។

### កថាខណ្ឌទី២ : ការឱ្យដំណឹងអំពីការចោទប្រកាន់

មុនឈានដល់ការចោទប្រកាន់អនីតិជនណាមួយ ព្រះរាជអាជ្ញាតែងតែពិនិត្យយ៉ាងល្អិតល្អន់ទៅលើសំណុំរឿងដែលបានដាក់មក រួមទាំងភស្តុតាងនានាដែលបានប្រមូលបាន ពីព្រោះការចោទប្រកាន់ខុសទៅលើជនណាម្នាក់ អាចនាំឱ្យមានប៉ះពាល់នានាកើតឡើង។ ជាពិសេស អនីតិជន ជា

[52] មាត្រា៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ចូលជាធរមាននៅថ្ងៃទី ២ កញ្ញា ១៩៩០

[53] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជនដែលទទួលបានការគាំពារនូវសិទ្ធិ និងការយកចិត្តទុកដាក់ខ្លាំង ពីសំណាក់សង្គមជាតិ និងសង្គមអន្តរជាតិ។ ហេតុនេះហើយ ទើបរាល់រឿងក្តីព្រហ្មទណ្ឌ ដែលអនីតិជនត្រូវបានគេសង្ស័យថាបានប្រព្រឹត្ត ត្រូវបានពិនិត្យ សង្កេតយ៉ាងល្អិតល្អន់ មុនសម្រេចចោទប្រកាន់ទៅលើជននោះ។ ក្រោយពីពិនិត្យបានច្បាស់លាស់រួចហើយ ព្រះរាជអាជ្ញាអាចសម្រេចចោទប្រកាន់ទៅលើអនីតិជនរូបនោះពីបទល្មើសដែលគេបានប្រព្រឹត្ត សម្រាប់ដំណើរការនីតិជំនុំជម្រះបន្ត។ នៅក្នុងដំណាក់កាលនេះ ព្រះរាជអាជ្ញាត្រូវតែជូនដំណឹងភ្លាមដោយផ្ទាល់និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្រប ត្រូវឱ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន[54]។

[54] មាត្រា ២៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## ជំពូកទី៣ : ការស៊ើបសួរលើបទល្មើសដោយចៅក្រមស៊ើបសួរ

ចំពោះបទឃាតកម្មទោះបីជាជនសង្ស័យជានីតិជនក្តី ជាអនីតិជនក្តី ការស៊ើបសួរដោយចៅក្រមស៊ើបសួរជាដំណាក់កាលមួយដ៏សំខាន់មិនអាចខ្វះបាន ដោយសារបទឃាតកម្មជា បទឧក្រិដ្ឋ[55] ហើយការស៊ើបសួរក្នុងដំណាក់កាលនេះត្រូវតែធ្វើឡើងជាសម្ងាត់ ។

### ផ្នែកទី ១ : កិច្ចចាប់ដំណើរការនៃការស៊ើបសួរ

#### កថាខណ្ឌទី ១ : សមត្ថកិច្ចនៃការស៊ើបសួរ

នៅក្នុងដំណាក់កាលសាលាដំបូង ការស៊ើបសួរទៅលើបទឃាតកម្មដែលប្រព្រឹត្តដោយអនីតិជន សមត្ថកិច្ចនៃការស៊ើបសួរត្រូវធ្លាក់ទៅលើចៅក្រមស៊ើបសួរដែលទទួលបន្ទុកទាក់ទងនឹងអនីតិជននៅតាមសាលាដំបូងរាជធានី-ខេត្តនីមួយៗដែលមានសមត្ថកិច្ច។ ទោះបីជាមានច្បាប់តម្រូវឲ្យមានចៅក្រមស៊ើបសួរសម្រាប់អនីតិជននោះក៏ដោយ ក៏ក្នុងការអនុវត្តជាក់ស្តែង យើងឃើញថាបច្ចុប្បន្នតុលាការពុំទាន់មានការបែងចែកតួនាទីរបស់ចៅក្រមស៊ើបសួរទៅលើអនីតិជន ឬនីតិជនឲ្យបានច្បាស់លាស់ដាច់ដោយឡែកពីគ្នានោះទេ។ គួរបញ្ជាក់ដែរថា ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចជាចៅក្រមស៊ើបសួរនៃសាលាដំបូងនៅៈ

- ទីកន្លែងដែលបទល្មើសបានកើតឡើង
- លំនៅឋាន ឬទីសំណាក់ដែលជនសង្ស័យជាអនីតិជននោះស្នាក់នៅ
- ទីកន្លែងដែលចាប់ខ្លួនអនីតិជននោះបាន

ប៉ុន្តែប្រសិនបើមានវិវាទចៅក្រមស៊ើបសួរច្រើនរូប នៅសាលាដំបូងខុសគ្នាៗ ហើយទទួលសំណុំរឿង និងពាក្យបណ្តឹងតែមួយ វិវាទនេះត្រូវបញ្ជូនទៅសភាស៊ើបសួរ ដើម្បីធ្វើការសម្រេចថាចៅក្រមស៊ើបសួរនៅសាលាដំបូងណាមួយមានសមត្ថកិច្ច ប៉ុន្តែបើមានវិវាទរវាងសភាស៊ើបសួរច្រើន វិវាទនោះត្រូវបញ្ជូនទៅប្រធានតុលាការកំពូល ដើម្បីសម្រេច និងដោះស្រាយ ហើយការសម្រេចរបស់ប្រធានតុលាការកំពូលនេះ ជាសេចក្តីសម្រេចដែលបិទផ្លូវតវ៉ាមិនអាចធ្វើការតវ៉ាបានទៀតទេ[56] ។

#### កថាខណ្ឌទី ២ : គោលបំណងនៃនីតិវិធីស៊ើបសួរ

ជាទូទៅនៅក្នុងនីតិវិធីនីមួយៗ មិនថានីតិវិធីស្ថិតនៅដំណាក់កាលណាក៏ដោយ គឺសុទ្ធតែមាន គោលបំណងច្បាស់លាស់ តែគោលបំណងទាំងនោះក៏អាចផ្តល់ផលវិជ្ជមាន និងអវិជ្ជមានមួយចំនួនផងដែរ។ ជាក់ស្តែងនៅក្នុងនីតិវិធីស៊ើបសួរ ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរទាំងការដាក់បន្ទុក និងទាំងការដោះបន្ទុកទៅលើជនដែលពាក់ព័ន្ធនិងរឿងក្តី។ ចៅក្រមស៊ើបសួរ បំពេញ

---

[55] មាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[56] មាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

កិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ថាមានប្រយោជន៍ ដើម្បីរកឲ្យឃើញនូវការពិតដោយអនុលោមទៅតាមច្បាប់។ បើរកមិនឃើញការពិតនៃបទល្មើសនោះទេ ជនល្មើសនៅតែមានឱកាសក្នុងការប្រព្រឹត្តបទល្មើសក្នុងសង្គម ហើយជនរងគ្រោះនៅតែគ្មានសុវត្ថិភាព និងមិនទទួលបានយុត្តិធម៌។ លើសពីនេះប្រសិនបើមាន ការយល់ច្រឡំចោទប្រកាន់ទៅលើជនស្លូតត្រង់ណាម្នាក់ នោះអាចបណ្តាលឲ្យជននោះខូចអនាគតអស់មួយជីវិត។ ហេតុនេះការរកឲ្យឃើញការពិតដោយអនុលោមទៅតាមនីតិវិធីផ្លូវច្បាប់គឺពិតជាសំខាន់មិនអាចខ្វះបាន ។

### ផ្នែកទី២ : ការស្រាវជ្រាវបន្ថែមរបស់ចៅក្រមស៊ើបសួរ

សម្រាប់បទឧក្រិដ្ឋ ដូចជាបទឃាតកម្មជាដើម ការស៊ើបសួរត្រូវតែធ្វើឡើងជាដាច់ខាត់[57]។ ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរបាន លុះត្រាតែមានដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា[58]។ ការស៊ើបសួររបស់ចៅក្រមស៊ើបសួរនោះ មានសារៈសំខាន់ផងដែរក្នុងបទឧក្រិដ្ឋ ព្រោះនីតិវិធីនៃការស៊ើបសួរនេះ ជួយឱ្យស្វែងយល់នូវបទល្មើសកាន់ច្បាស់តាមរយៈភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដែលរកបានក្នុងកំឡុងពេលនីតិវិធីស៊ើបសួរ ជៀសវាងការចោទប្រកាន់ និងការដាក់ទោសខុស។ ការស៊ើបសួរនេះត្រូវធ្វើឡើងជាលក្ខណៈសម្ងាត់ ហើយជនដែលធ្វើឱ្យលេចធ្លាយព័ត៌មានសម្ងាត់ទាំងនោះត្រូវតែទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ លើកលែងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ព្រះរាជអាជ្ញា ទៅលើព័ត៌មានមិនពិតនានាទាក់ទងបទល្មើស[59]។ ទាក់ទងនឹងការស៊ើបសួរនេះផងដែរ ចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវបន្ថែមតាមច្រើនវិធីដូចជាការសួរចម្លើយជនត្រូវចោទ ការសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការសួរចម្លើយសាក្សី ការឆែកឆេរ និងចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ ជាដើម។

#### កថាខណ្ឌទី១ : ការសួរ និងស្តាប់ចម្លើយភាគីដែលពាក់ព័ន្ធក្នុងរឿងក្តី

ការស្តាប់ចម្លើយបុគ្គលដែលពាក់ព័ន្ធក្នុងរឿងក្តី ជានីតិវិធីមួយដែលចៅក្រមស៊ើបសួរមិនអាចរំលងបាន ដោយធ្វើការសាកសួរអំពីព័ត៌មាននានាទាក់ទងទៅនឹងបទល្មើស។ ការស្តាប់ចម្លើយនេះ អាចធ្វើចំពោះជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី។ ដូចបានបញ្ជាក់ពីខាងលើតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ចៅក្រមស៊ើបសួរទទួលបានសិទ្ធិអំណាចក្នុងការសាកសួរ និងស្រាវជ្រាវបន្ថែម។

---

[57] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[58] មាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[59] មាត្រា១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ការសួរចម្លើយជនត្រូវចោទ ជាពិសេសក្នុងករណីជនត្រូវចោទជាអនីតិជន ត្រូវតែមានមេធាវីអមជានិច្ច លើកលែងក្នុងលក្ខខណ្ឌផ្សេងដែលច្បាប់បានកំណត់ ប៉ុន្តែប្រសិនបើអនីតិជននោះពុំមានមេធាវីទេ ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[60]។ មានករណីខ្លះដូចជា ភាពបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយ ចៅក្រមស៊ើបសួរត្រូវបានអនុញ្ញាតឱ្យសួរចម្លើយដោយពុំចាំបាច់មានវត្តមានរបស់មេធាវី[61]។ ក្រៅពីវត្តមានរបស់មេធាវី បុគ្គលផ្សេងទៀតដូចជាអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចក៏អាចចូលរួមនៅក្នុងនីតិវិធីស្តាប់ចម្លើយអនីតិជន ផងដែរ។ ក្នុងករណីដែលវត្តមានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការមិនអនុញ្ញាតជនទាំងនោះចូលរួមបាន ប៉ុន្តែការមិនអនុញ្ញាតនេះ ត្រូវពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន[62]។ រាល់ចម្លើយរបស់អនីតិជនរូបនោះ ត្រូវបានកត់ត្រាក្នុងកំណត់ហេតុ។ នាពេលបញ្ចប់ការសួរចម្លើយ អនីតិជនអាចអាននូវកំណត់ហេតុ ដែលបានកត់ត្រានោះ ប្រសិនជាខ្លួនចង់បន្ថែម ឬបន្ថយនូវចម្លើយរបស់ខ្លួន អនីតិជននោះអាចស្នើសុំ ចៅក្រមស៊ើបសួរឱ្យធ្វើការកែប្រែនូវចម្លើយនោះ។ ផ្ទុយមកវិញ ឧបមាថាអនីតិជនដែលត្រូវបាន សាកសួរចម្លើយនោះពុំចេះអានអក្សរដូច្នេះក្រឡាបញ្ជីត្រូវអានកំណត់ហេតុនោះឱ្យបានត្រឹមត្រូវ។ ក្រោយពីបញ្ចប់ការអានកំណត់ហេតុនឹងពុំមានអ្វីជំទាស់ទេ ចៅក្រមស៊ើបសួរត្រូវឱ្យអ្នកដែលចូលរួម ទាំងនោះនិងអនីតិជនចុះហត្ថលេខាលើកំណត់ហេតុនោះ ប៉ុន្តែប្រសិនបើអ្នកទាំងនោះពុំព្រមចុះហត្ថលេខាទេ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុនោះឱ្យត្រឹមត្រូវ។ ការស្តាប់ចម្លើយ ក៏អាចត្រូវបានលើកពេលផងដែរក្នុងករណីអវត្តមានមេធាវី លើកលែងករណីភាពបន្ទាន់ដូចរៀបរាប់ពីខាងលើ ប៉ុន្តែក្នុងន័យនេះ វត្តមាន ឬអវត្តមានមេធាវី មិនអាចជាកត្តាដែលនាំឱ្យរារាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការមិនឃុំខ្លួន ឬឃុំខ្លួនជាបណ្តោះអាសន្នឡើយ[63]។

សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី គាត់អាចត្រូវអមដោយមេធាវីរបស់ខ្លួននៅពេលចូលខ្លួនផ្តល់ចម្លើយ។ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ជននោះយ៉ាងតិច ៥ថ្ងៃមុនការស្តាប់ចម្លើយ ដើម្បីទុកចិរវេលានោះ សម្រាប់មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។[64] ដោយឡែក

[60] មាត្រា៣២ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[61] មាត្រា១៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[62] មាត្រា៣៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[63] មាត្រា៣៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[64] មាត្រា១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ប្រសិនបើមេធាវីនោះត្រូវបានកោះហៅត្រឹមត្រូវ ប៉ុន្តែមិនចូលរួម ឬដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវី ឬ ករណីភាពបន្ទាន់ ដូច្នេះចៅក្រមស៊ើបសួរអាចដំណើរការការស្តាប់ចម្លើយដោយពុំមានវត្តមានមេធាវី។

សាក្សី ជាតួអង្គមួយដែលមានកាតព្វកិច្ចផ្តល់ការបំភ្លឺ និងមានសិទ្ធិជាច្រើនទៀតជាអាទ៍ៈ រៀបរាប់នូវអ្វីៗទាំងអស់ដែលគាត់បានដឹងអំពីរឿងនោះនិងមានកាតព្វកិច្ចឆ្លើយនូវរាល់សំណួររបស់ស្ថាប័នស៊ើបអង្កេត តុលាការ។ សាក្សី អាចត្រូវបានសួរចម្លើយដាច់ដោយឡែក។ ការសួរចម្លើយដាច់ដោយឡែក បានន័យថា សាក្សីនោះត្រូវបានសាកសួរចម្លើយដោយពុំមានវត្តមានរបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ បុគ្គលទាំងឡាយដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅមកក្នុងឋានៈជាសាក្សី បុគ្គលទាំងនោះត្រូវតែចូលខ្លួនបានតាមកោះហៅ។ ករណីរឹងទទឹងពុំចូលខ្លួន ចៅក្រមមានសិទ្ធិក្នុងការប្រើប្រាស់កម្លាំងសាធារណៈឱ្យចាប់បង្ខំចូលខ្លួន[65]។ អាស្រ័យដោយសាក្សីជាអ្នកដែលផ្តល់នូវចម្លើយដែលអាចដាក់បន្ទុក ឬដោះបន្ទុកដល់អនីតិជនដែលជាជនត្រូវចោទ ក៏ដូចជាជៀសវាងពីការក្លែងបន្លំ ឬការផ្តល់ចម្លើយមិនពិត សាក្សីនោះត្រូវតែធ្វើការស្បថតាមសាសនា ឬជំនឿរបស់ខ្លួនជាមុនសិន មុនធ្វើការឆ្លើយបំភ្លឺ[66]។ បន្ថែមពីនេះ ក្នុងករណីដែលសាក្សី ផ្តល់ចម្លើយក្លែងក្លាយ ឬក៏ព្យាយាមលាក់បាំងរាល់ព័ត៌មានពាក់ព័ន្ធដែលខ្លួនបានដឹង សាក្សីនោះនឹងប្រឈមមុខការទទួលទោសព្រហ្មទណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ។ ជាឧទាហរណ៍ ករណីដែលបុគ្គលណាក៏ដោយ ដែលមានភស្តុតាងបង្ហាញឱ្យឃើញភាពស្លូតត្រង់របស់ជនត្រូវចោទពិរុទ្ធជន ឬទណ្ឌិត ហើយមិនផ្តល់ភស្តុតាងនោះដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតទេ ត្រូវទទួលទោសស្របតាមមាត្រា៥៣៩ នៃក្រមព្រហ្មទណ្ឌ។

ជំនួយរបស់អ្នកបកប្រែក៏ជាចំនុចមួយសំខាន់ផងដែរ ប្រសិនបើអ្នកទាំងនោះរួមមាន អនីតិជនដែលជាជនត្រូវចោទ, ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ពុំចេះភាសាខ្មែរ ដូច្នេះទាមទារឱ្យមានអ្នកបកប្រែសម្រាប់ជាជំនួយក្នុងការនិយាយ សាកសួរ និងស្តាប់ចម្លើយពីបុគ្គលទាំងនោះ។

### កថាខណ្ឌទី២ : ការឆែកឆេរនិងការចាប់យកវត្ថុតាង

នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរអាចបើកការឆែកឆេរ និងចាប់យកវត្ថុតាងប្រសិនបើខ្លួនទទួលបានតម្រុយភស្តុតាងនៃទីកន្លែងដែលត្រូវឆែកឆេរនោះ។ ជាឧទាហរណ៍ ឧបមាថាក្រោយពីបញ្ចប់ការស៊ើបអង្កេតដោយបានឆែកឆេរនិងប្រមូលភស្តុតាងរួចរាល់អស់ហើយ ស្រាប់តែដល់ដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរទទួលបានចម្លើយពីសាក្សីអំពីទីតាំងដែលមានតម្រុយ

[65] មាត្រា១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[66] មាត្រា១៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ភស្តុតាងបន្ថែមពាក់ព័ន្ធបទឃាតកម្មដែលបានកើតឡើង នោះចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការចុះទៅឆែកឆេរទីតាំងនោះតែម្តង។ គួយ៉ាង អំពីការឆែរឆេរក្នុងដំណាក់កាលស៊ើបសួរ និងការឆែកឆេរក្នុងដំណាក់កាលស៊ើបអង្កេតគឺមានលក្ខណៈមិនខុសគ្នាប៉ុន្មានទេ ពោលគឺត្រូវគោរពទៅតាមលក្ខខណ្ឌនៃការឆែកឆេរ។ អំពីលក្ខខណ្ឌនៃការឆែកឆេរក្នុងដំណាក់កាលស៊ើបសួរនោះទៀតសោតត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅត្រង់មាត្រា១៥៩ និងមាត្រា១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ លក្ខខណ្ឌទាំងនោះរួមមានៈ

- ការឆែកឆេរត្រូវធ្វើចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២នាក់ ប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែងនោះ។ សាក្សីនោះដាច់ខាតមិនអាចជាកងកម្លាំងចូលរួមក្នុងប្រតិបត្តិការឆែកឆេរទេ
- ការឆែកឆេរត្រូវតែធ្វើក្នុងចន្លោះម៉ោងពី ៦ព្រឹក ទៅដល់ម៉ោង ១៨ល្ងាច លើកលែងតែទីកន្លែងនោះបើកចំហដល់សាធារណជន
- ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពី ការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី២នាក់
- បិទស្លាកត្រាលើវត្ថុតាង និងបង្ហាញវត្ថុតាងដែលចាប់ ទៅដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២នាក់។

ដើម្បីឱ្យដំណើរការនៃការឆែកឆេរប្រកបដោយភាពរលូន និងមានប្រសិទ្ធភាព ជាពិសេសស្របច្បាប់ថែមទៀតនោះ ចៅក្រមស៊ើបសួរត្រូវតែអនុលោមតាមលក្ខខណ្ឌខាងលើឱ្យបានត្រឹមត្រូវ ព្រោះជាការជៀសវាងនៃការប៉ះពាល់សិទ្ធិរបស់អ្នកកាន់កាប់ទីកន្លែងនោះផ្ទាល់។

### កថាខណ្ឌទី៣ : ការធ្វើកោសលវិច័យ

ការធ្វើកោសលវិច័យ គឺជាសកម្មភាពស្វែងរកឱ្យឃើញទៅលើរបកគំហើញនៃខណៈនានា និងបញ្ហា ឬសំនួរទាំងឡាយដែលបានចោទឡើងខាងបច្ចេកទេស ហើយត្រូវបានធ្វើឡើងដោយអ្នកជំនាញផ្ទាល់ទៅតាមចំណេះដឹងឯកទេសដែលខ្លួនមាន[67]។ មុនឈានដល់ការសម្រេចធ្វើកោសលវិច័យលុះត្រាតែមានបញ្ហាបច្ចេកទេសចោទឡើងនៅក្នុងរឿងក្តីនោះ ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី[68]។ តាមរយៈការស្នើសុំនោះ ចៅក្រមត្រូវសង្កេតមើលផងដែរអំពីភាពចាំបាច់និងអត្ថប្រយោជន៍នៃការធ្វើកោសលវិច័យនោះផងដែរ។ ប្រសិនបើការស្នើ

[67] ទំព័រ២២៦ នៃសៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូផា ឆ្នាំ២០១៦

[68] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សុំនោះមានលក្ខណៈសមហេតុផល និងមានប្រយោជន៍ នោះចៅក្រមស៊ើបសួរនោះបើកការធ្វើកោសលវិច័យតែម្តង។ ផ្ទុយមកវិញករណីចៅក្រមស៊ើបសួរបដិសេធការស្នើសុំនោះ គាត់ត្រូវតែចេញដីកាដោយមានសំអាងហេតុក្នុងរយៈពេលដែលច្បាប់បានកំណត់។ កាលណាពាក្យសុំនោះចេញពីព្រះរាជអាជ្ញា ដីកានោះត្រូវសម្រេចក្នុងរយៈពេល ៥ថ្ងៃ ប៉ុន្តែបើជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកស្នើសុំ ដីកានោះត្រូវសម្រេចក្នុងរយៈពេល ១ខែ[69]។ អំពីការធ្វើកោសលវិច័យនោះទៀតសោត ត្រូវការអ្នកជំនាញសម្រាប់ធ្វើការងារនេះ។ ដូចដែលយើងបានស្វែងយល់រួចហើយ អ្នកជំនាញជាអ្នកដែលមានចំណេះដឹងជ្រៅជ្រះពោលគឺឯកទេសទៅលើផ្នែកណាមួយ។ អ្នកជំនាញទាំងនោះអាចមានម្នាក់ ឬច្រើននាក់ អាស្រ័យទៅតាមកាលៈទេសជាក់ស្តែង។ ម្យ៉ាងវិញទៀត អ្នកជំនាញទាំងអស់ត្រូវបានជ្រើសរើសដោយចៅក្រមស៊ើបសួរចេញពីបញ្ជីថ្នាក់ជាតិ ឬបុគ្គលផ្សេងទៀតដែលគ្មានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិនោះ[70]។ រាល់បុគ្គលដែលត្រូវបានជ្រើសរើសសម្រាប់ការធ្វើកោសលវិច័យ ត្រូវសម្រេចដោយដីការបស់ចៅក្រមស៊ើបសួរ ដោយមានបញ្ជាក់ផងដែរអំពីបេសកម្ម និងរយៈពេលនៃការធ្វើបេសកម្មនោះ។ ក្រោយពីបញ្ចប់ការធ្វើកោសលវិច័យរបស់ខ្លួន អ្នកជំនាញទាំងនោះត្រូវ ធ្វើរបាយការណ៍ស្តីពីសេចក្តីសន្និដ្ឋានមួយអំពីលទ្ធផលការងាររបស់ខ្លួនដែលបានបញ្ចប់រួចរាល់។ សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញនោះ ច្បាប់អាចចាត់ទុកជាប្រភេទនៃភស្តុតាងមួយនៅក្នុងរឿងព្រហ្មទណ្ឌបានផងដែរមានជាអាទិ៍៖ មតិយោបល់ ឬការអះអាងរបស់អ្នកជំនាញ ជាដើម ដែលគាត់បានធ្វើការរុករកឱ្យឃើញនូវរបកគំហើញនានាអំពីខណៈនៃបញ្ហាចោទជាបច្ចេកទេសទាំងនោះ[71]។ ក្នុងន័យនេះ សេចក្តីសន្និដ្ឋាននោះមិនមែនជាភស្តុតាងដែលមានតម្លៃពិសេសជាងគេនោះទេ បានន័យថាគេចាត់ទុកវាមានតម្លៃស្មើជាមួយភស្តុតាងដទៃទៀត ដោយវាបម្រើប្រយោជន៍ដល់ការវាយតម្លៃ វិភាគ ពិចារណារបស់ចៅក្រមទៅលើរឿងក្តីនោះ។ ម៉្យាងវិញទៀត សេចក្តីសន្និដ្ឋាននោះក៏អាចត្រូវបានចៅក្រមច្រានចោល ឬធ្វើប្រតិកោសលវិច័យផងដែរប្រសិនបើសេចក្តីសន្និដ្ឋាននោះមិនមានភាពស៊ីសង្វាក់គ្នាជាមួយនឹងអង្គហេតុនានា[72]។

**ផ្នែកទី ៣ : ការចេញដីការបស់ចៅក្រមស៊ើបសួរ**

ក្រៅពីដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបង្គាប់ឲ្យឃុំខ្លួនហើយនោះ ចៅក្រមស៊ើបសួរក៏អាចចេញដីកាសំខាន់ៗមួយចំនួនទៀតដែលមានអានុភាពទៅលើជនសង្ស័យជាអនីតិជន ហើយនឹងត្រូវបានបកស្រាយបន្ថែមបន្ទាប់ពីដីកាមួយចំនួនដែល

[69] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[70] មាត្រា១៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[71] ទំព័រ២២៦ នៃសៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូផា ឆ្នាំ២០១៦

[72] ទំព័រ២២៧ នៃសៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូផា ឆ្នាំ២០១៦

បានរៀបរាប់ខាងលើនេះ ។ ជាទូទៅ កុមារមិនត្រូវបានបំបែកចេញពីឪពុកម្តាយផ្ទុយពីឆន្ទៈកុមារឡើយ លើកលែងតែអាជ្ញាធរមានសមត្ថកិច្ច ដែលស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការសម្រេចស្របតាមច្បាប់ និងនីតិវិធីថាការបំបែក គឺចាំបាច់សំរាប់ឧត្តមប្រយោជន៍របស់កុមារ[73] ។

**កថាខណ្ឌទី ១ : ដីកាបង្គាប់ឱ្យចូលខ្លួន**

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[74] ។

ចៅក្រមស៊ើបសួរ ដែលទទួលបន្ទុកជំនាញផ្នែកអនីតិជនអាចចេញដីកាបង្គាប់ឲ្យអនីតិជនដែលជាជនសង្ស័យ ឬជាជនត្រូវចោទនោះឲ្យចូលខ្លួនដើម្បីបង្ហាញខ្លួននៅមុខខ្លួន។ ជាទូទៅការចេញដីកាបង្គាប់ឲ្យចូលខ្លួនគឺ ត្រូវធ្វើឡើងនៅពេលដែលព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយផ្ទេរសំណុំរឿងមកចៅក្រមស៊ើបសួរដែលទទួលបន្ទុក។ ប៉ុន្តែក្នុងករណីដែលដីកាបញ្ជូនឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា បានសម្រេចចោទប្រកាន់ទៅលើអនីតិជនដែលមិនទាន់បានស្គាល់សាវតាជាតិគ្រប់គ្រាន់ ឬមិនទាន់បានស្គាល់អត្តសញ្ញាណច្បាស់លាស់ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឲ្យចូលខ្លួនបានឡើយ ដើម្បីអាចដោះស្រាយបញ្ហានេះបានចៅក្រមស៊ើបសួរអាចចេញ ដីកាចាត់ឲ្យស៊ើបសួរជំនួស ដើម្បីស្រាវជ្រាវរកឃើញសាវតាជាតិឬអត្តសញ្ញាណរបស់អនីតិជនដែលជាជនសង្ស័យនោះឲ្យបានជាក់លាក់។ ការស្គាល់សាវតាជាតិឬអត្តសញ្ញាណរបស់អនីតិជនដែលជាជនសង្ស័យពិតជាសំខាន់ណាស់នៅក្នុងដំណាក់កាលនេះដោយសារតែនៅក្នុងដីកាបង្គាប់ឲ្យខ្លួនត្រូវចុះនិទ្ទេសជាអាទិ៍ដូចខាង ក្រោម ៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា
- ដីកានេះត្រូវមានចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឲ្យចូលខ្លួន ។

[73] វាក្យខណ្ឌ១ មាត្រា៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ចូលជាធរមាននៅថ្ងៃទី ២ កញ្ញា ១៩៩០ ។

[74] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវមានកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[75] ។

នៅពេលដែលមានលក្ខខណ្ឌសមស្របហើយនោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យអនីតិជនចូលខ្លួនបានហើយដីកានេះ នឹងត្រូវបញ្ជូនភ្លាមទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬមន្ត្រីអាជ្ញាសាលា តាមរយៈក្រឡាបញ្ជី ដើម្បីឱ្យមន្ត្រីដែលមានសមត្ថកិច្ចខាងលើ បញ្ជូនដីកានេះឲ្យទៅដល់បុគ្គលមួយចំនួនដែលពាក់ព័ន្ធនឹងបទឃាតកម្មនេះ។ បន្ទាប់ពីមន្ត្រីមានសមត្ថកិច្ចខាងលើបានបញ្ជូនដីកានេះ មកប្រគល់ដល់បុគ្គលដែលពាក់ព័ន្ធនឹងរឿងក្តីហើយនោះ មន្ត្រីមានសមត្ថកិច្ចត្រូវបញ្ជាក់ប្រាប់ទៅបុគ្គលដែលជាកម្មវត្ថុនៃដីកានេះឱ្យទទួលយកចុងដីកាហើយត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃនៅលើដើមដីកាផងដែរ នេះក្នុងករណីដែលបុគ្គលទាំងនោះព្រមទទួលយកដីកានេះ ប៉ុន្តែក្នុងករណីដែលពួកគាត់មិនព្រមទទួលយកដីកានេះ មន្ត្រីដែលទទួលបន្ទុកត្រូវធ្វើចំណារលើដីកាបង្គាប់ឲ្យចូលខ្លួននេះ ព្រមតាំងបញ្ជាក់ពីមូលហេតុនៃការមិនព្រមទទួលយកដីកានេះផងដែរ ។ ចំពោះករណីនេះ មន្ត្រីមានសមត្ថកិច្ចត្រូវបង្វិលដីកានេះទៅកាន់ចៅក្រមស៊ើបសួរវិញ ក្នុងពេលវេលាឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ម៉្យាងទៀតប្រសិនបើមានឧបសគ្គមិនអាចជៀសបានក្នុងការប្រគល់ដីកានេះ មន្ត្រីមានសមត្ថកិច្ចត្រូវជូនដំណឹងអំពីការលំបាកក្នុងការអនុវត្តនីតិវិធីនេះទៅកាន់ចៅក្រមស៊ើបសួរដូចគ្នាដែរ[76] ។

ចំពោះដីកាបង្គាប់ឱ្យចូលខ្លួន ទោះបីជាបុគ្គលដែលពាក់ព័ន្ធនឹងបទឃាតកម្មបានទទួលយកដីកានេះហើយក៏ដោយ ក៏អនីតិជនដែលជាជនសង្ស័យ និងបុគ្គលដែលពាក់ព័ន្ធនៅតែអាចមិនចូលខ្លួនតាមដីកានេះបានដោយសេរីនិយាយរួមដីកានេះមិនមានអានុភាពចាប់បង្ខំដូចដីកាបង្គាប់ឱ្យនាំខ្លួន ឬដីកាឲ្យចាប់ខ្លួននោះទេ ។ ហើយនៅក្នុងដំណាក់កាលនេះ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬមន្ត្រីអាជ្ញាសាលាដែលជាអ្នកបញ្ជូនដីកាក៏គ្មានសិទ្ធិអំណាចក្នុងការចាប់បង្ខំ នាំខ្លួន ឬចាប់ខ្លួនអនីតិជន ឬបុគ្គលដែលពាក់ព័ន្ធបញ្ជូនមកចៅក្រមស៊ើបសួរតែម្តងបាននោះទេ[77] ពោលគឺបានត្រឹមតែនាំដីកានេះតែម៉្យាងប៉ុណ្ណោះ ។

គួរបញ្ជាក់ថា ដីកាបង្គាប់ឱ្យចូលខ្លួនអាចចេញច្រើនដងទៅលើអនីតិជនដែលជាជនសង្ស័យក្នុងករណីដែលបុគ្គលនេះបានបដិសេធមិនចូលខ្លួនមកជួបចៅក្រមស៊ើបសួរ ដោយមានមូលហេតុ

---

[75] មាត្រា ១៨៧ និងមាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[76] មាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[77] សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌរបស់ក្រសួងយុត្តិធម៌ បោះពុម្ពខែកុម្ភៈ ឆ្នាំ២០០៦

ត្រឹមត្រូវ ដោយហេតុជាអាទ៍ថាជាប់ព្យាបាលជម្ងឺ ឬស្វែងរកមេធាវីដែលជំនាញខាងអនីតិជនឱ្យមកការពារខ្លួនដែលជាអនីតិជន ចៅក្រមស៊ើបសួរអាចសម្រេចពន្យាពេលនៃការចូលខ្លួនរបស់អនីតិជននេះបាន។ ទោះបីជាដីកានេះគ្មានអានុភាពចាប់បង្ខំក្តី ប៉ុន្តែការប្រឆាំង ឬការគេចវៀស និងដីកានេះជាកត្តាមួយដែលជួយជម្រុញឱ្យចៅក្រមស៊ើបសួរចេញនូវដីកាមួយទៀតគឺ ដីកាបង្គាប់ឲ្យនាំខ្លួនតែម្តង ដើម្បីឆ្លើយតបនិងស្តានជាក់ស្តែង ។

### កថាខណ្ឌទី ២ : ដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[78] ។

ដីកានេះ គឺធ្វើឡើងបន្ទាប់ពីពេលដែលចំណាត់ការនៃដីកាបង្គាប់ឲ្យចូលខ្លួន ដែលបង្គាប់ទៅលើអនីតិជនដែលជាជនត្រូវចោទលែងមានប្រសិទ្ធិភាពតទៅទៀត ឬក្នុងកាលៈទេសៈពិសេសដែលចាំបាច់ត្រូវតែចេញដីកាបង្គាប់ឲ្យនាំខ្លួន ដោយត្រូវរំលងនូវនីតិវិធីនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួនដោយសារជាទូទៅដីកាបង្គាប់ឱ្យនាំខ្លួនតែងតែកើតឡើងនៅក្រោយពីការចេញនូវដីកាបង្គាប់ឲ្យចូលខ្លួន។ ក្នុងករណីនេះ ការរស់នៅបែកគ្នាបណ្តាលមកពីវិធានការណាមួយទាក់ទង នឹងការឃាត់ ឬការឃុំខ្លួន ការដាក់ពន្ធនាគារ រដ្ឋត្រូវជូនដំណឹងទៅកាន់សមាជិកគ្រួសារ[79] ។ ចំពោះការចេញដីកាបង្គាប់ឲ្យនាំខ្លួនអាចធ្វើទៅបាន កាលណាអនីតិជនដែលជាជនត្រូវចោទបានបដិសេធមិនព្រមចូលខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ នឹងមានចំណាររបស់មន្ត្រីមានសមត្ថកិច្ច ឬអនីតិជននោះបាននឹងកំពុងព្យាយាមរត់គេចខ្លួនចេញពីទីលំនៅ ដើម្បីគេចផុតពីការចោទប្រកាន់ពីបទឃាតកម្ម។ ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវចុះនិទ្ទេសជាអាទ៍ដូចខាងក្រោម ៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា
- ដីកានេះត្រូវមានចុះលេខរៀងនៃការចេញដីកាស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឲ្យនាំខ្លួន ។

[78] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[79] វាក្យខណ្ឌ៤ មាត្រា៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ចូលជាធរមាននៅថ្ងៃទី ២ កញ្ញា ១៩៩០។

ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវមានកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[80] ។ គួរបញ្ជាក់ដែរថា ដីកានេះត្រូវគោរពឱ្យបាននូវលក្ខខណ្ឌខាងលើឱ្យបានបើមិនដូច្នោះទេ ដីកានេះនឹងមិនមានអានុភាពគតិយុត្តិឡើយ ។

បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យនាំខ្លួនរួចហើយ ការអនុវត្តដីកានេះជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែក្នុងករណីចាំបាច់ ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ[81]ជាអាទិ៍មានដូចជាកាសែត ទូរទស្សន៍ វិទ្យុ ឬតាមប្រព័ន្ធអ៊ីនធឺណេតជាដើម ។ ស្ថានភាពបន្ទាន់នៃការអនុវត្តដីកានេះមកពីជនជាប់ចោទដែលជាអនីតិជនព្យាយាមរត់គេចចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហេតុនេះទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបើកសិទ្ធិឲ្យដីកានេះ អាចផ្សព្វផ្សាយបានលាតសន្ធឹងលើទឹកដីកម្ពុជាទាំងមូលតែម្តង។ ប៉ុន្តែទោះបីជាស្ថិតក្នុងស្ថានភាពបន្ទាន់យ៉ាងណាក៏ដោយ ក៏មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរពអោយបាននូវសិទ្ធិនៃលំនៅឋានដែរ មានន័យថាមន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានបុគ្គលដែលពាក់ព័ន្ធដើម្បីអនុវត្តដីកានេះនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង១៨ (ដប់ប្រាំបី)ល្ងាចបានទេ ហើយបើការអនុវត្តនូវបេសកកម្មជួបនូវបញ្ហាលំបាកមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងមកចៅក្រមស៊ើបសួរវិញភ្លាម[82]។ ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌បាននាំខ្លួនអនីតិជន និងបុគ្គលដែលពាក់ព័ន្ធបានហើយនោះ មន្ត្រីនគរបាល-យុត្តិធម៌ត្រូវនាំខ្លួនអនីតិជន និងបុគ្គលដែលពាក់ព័ន្ធទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរដែលជាម្ចាស់ដីកាភ្លាម ដើម្បីឲ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយ និងតម្រុយសំខាន់ៗដែលទាក់ទងនិងរឿងក្តីដែលព្រះរាជអាជ្ញាបានសម្រេចចោទប្រកាន់ ។

ប៉ុន្តែក្នុងករណី មន្ត្រីនគរបាលមិនអាចនាំខ្លួនអនីតិជន និងបុគ្គលដែលពាក់ព័ន្ធទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរបានទាន់ពេលវេលា ដោយហេតុថាកាលៈទេសៈមិនអំណោយផលទេនោះ បុគ្គលទាំងនេះត្រូវតែនាំខ្លួនទៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ។ ចំពោះអនីតិជនដែលត្រូវឃុំខ្លួន ត្រូវដាក់អនីតិជនដែលត្រូវចោទប្រកាន់នោះឲ្យនូវដាច់ដោយឡែកពីនីតិជនដែលជាត្រូវឃុំខ្លួនដែរ។ បន្ទាប់ពីរក្សាទុកបុគ្គលដែលពាក់ព័ន្ធមួយរយៈខ្លីរួចមក មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែនាំជនទាំងនេះទៅបង្ហាញខ្លួនយ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួសដែលទទួលបន្ទុករឿងនេះ តែបើមិនអាចធ្វើបាន

[80] មាត្រា ១៩១ និងមាត្រា ២៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[81] មាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[82] មាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បុគ្គលទាំងនេះត្រូវដោះលែងឲ្យមានសេរីភាពឡើងវិញ ហើយរយៈពេលនេះនៃការឃុំខ្លួននេះត្រូវតែគិតបញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើករណីនេះបានកើតឡើង[83] ។

ដីកាបង្គាប់ឲ្យនាំខ្លួនមានអានុភាពបញ្ជាដល់កងកម្លាំងសាធារណៈជាពិសេសមន្រ្តីនគរបាលយុត្តិធម៌តែម្តងឲ្យចាប់ខ្លួនអនីតិជនដែលជាជនត្រូវចោទ និងបុគ្គលដែលពាក់ព័ន្ធដទៃឲ្យមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកានេះក៏មានអានុភាពក្នុងការយកទៅផ្សព្វផ្សាយជា សាធារណៈតាមគ្រប់មធ្យោបាយនៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែដីកានេះមិនមានអានុភាពផ្សព្វផ្សាយលើទឹកដីអន្តរជាតិដូចដីកាបង្គាប់ឲ្យចាប់ខ្លួននោះទេ ។

**កថាខណ្ឌទី ៣ : ដីកាបង្គាប់ឲ្យចាប់ខ្លួន**

ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះ ទៅដាក់ក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ព្រមទាំងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ[84]។ ដីកានេះអាចចេញបានដោយសារបទឃាតកម្មជាបទឧក្រិដ្ឋ ហើយ ចៅក្រមស៊ើបសួរឃើញថាអនីតិជនដែលជាជនត្រូវចោទ បានគេចខ្លួនមិនដឹងថាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ផ្ទុយទៅវិញប្រសិនបើគ្មានស្ថានភាពដូចខាងលើទេដីកានេះនឹងមិនមានអានុភាពគតិយុត្តិនោះទេ។ លើសពីនេះទៅទៀត ទោះបីជាមានលក្ខខណ្ឌគ្រាប់គ្រាន់ហើយក៏ដោយ ក៏ដីកាមិនអាចភ្លាមៗបានដោយចៅក្រម-ស៊ើបសួរតែឯកឯងបាននោះទេ គឺត្រូវតែមានការឲ្យយោបល់ពីសំណាក់ព្រះរាជាអាជ្ញាជាមុនសិន តែមិនមែនមានន័យថាចៅក្រមស៊ើបសួរត្រូវតែគោរពទៅតាមយោបល់របស់ព្រះរាជអាជ្ញានោះទេ មានន័យថាចៅក្រមស៊ើបសួរនៅតែអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបានដដែលដោយសំអាងទៅលើអង្គហេតុ និងអង្គច្បាប់ត្រឹមត្រូវ ទោះបីជាយោបល់របស់ព្រះរាជអាជ្ញាមានលក្ខណៈផ្ទុយក៏ដោយ ។ បន្ទាប់ពីទទួលបានការឲ្យយោបល់ពីសំណាក់ព្រះរាជអាជ្ញាហើយនោះ ចៅក្រមស៊ើបសួរអាចដីកាចាប់ខ្លួនអនីតិជនបានហើយ ដោយមានចែងពីមូលហេតុនៅក្នុងដីកានេះផងដែរ ចំពោះបន្ទុកក្នុងការផ្សព្វផ្សាយព្រះរាជអាជ្ញាជាអ្នករ៉ាប់រង[85] ។

បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនរួចហើយ ការអនុវត្តដីកានេះត្រូវជាសមត្ថកិច្ចរបស់មន្រ្តីនគរបាលយុត្តិធម៌ ប៉ុន្តែក្នុងករណីបន្ទាន់ដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយជាអាទិ៍មានដូចជា សារព័ត៌មាន

---

[83] មាត្រា ១៩៣ និងមាត្រា ១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[84] កថាខណ្ឌទី ២ នៃមាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[85] មាត្រា ១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

កាសែត ទូរទស្សន៍ វិទ្យុ ឬតាមប្រព័ន្ធអ៊ីនធឺណេតជាដើម។ ជាក់ស្តែងមានដូចករណីសិក្សាខាងក្រោមៈ

***<u>ករណីសិក្សាទី ៤</u>***

ត្បូងឃ្មុំ ៖ បុរសម្នាក់ត្រូវបានប៉ូលិសស្រុកពញាក្រែកឃាត់ខ្លួននៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ តាមដីកាតុលាការខេត្តកំពង់ចាមពីបទឃាតកម្មកាលពីឆ្នាំ២០១១មកម្ល៉េះ។ ប៉ូលិសនិយាយថា កម្លាំងជំនាញនៃអធិការដ្ឋានប៉ូលិសស្រុកពញាក្រែក បានឃាត់ខ្លួនឈ្មោះ "ត" ហៅ "គ" ភេទប្រុស អាយុ១៧ឆ្នាំ ដោយ ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៦៨ ចុះថ្ងៃទី ២៤/០៤/២០១៣ របស់លោក "ស" ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម ក្នុងករណីឃាតកម្ម ប្រព្រឹត្តនៅភូមិត្រាចខោល ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក នៅថ្ងៃទី០៩ ឆ្នាំ២០១១។ បច្ចុប្បន្ន ជនល្មើសកំពុងឃាត់ខ្លួននៅអធិការដ្ឋាននគរបាលស្រុកពញាក្រែក និងកំពុងបំពេញនីតិវិធីបញ្ជូនទៅតុលាការ [86]។

យោងទៅតាមករណីសិក្សាខាងលើ បន្ទាប់ពីលោក "ស" ជាចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម បានចេញដីកាបង្គាប់អោយចាប់ខ្លួន កាលពីថ្ងៃទី ២៤ មេសា ឆ្នាំ២០១៣ ហើយនោះ មន្ត្រីនគរបាលយុត្តិធម៌ ខេត្តកំពង់ចាម ជាអ្នកដែលមានសមត្ថកិច្ចក្នុងការអនុវត្តដីកានេះ ។ ដើមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៦៨ ចុះថ្ងៃទី ២៤/០៤/២០១៣ របស់លោក "ស" ចៅក្រុមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម ត្រូវប្រគល់ក្នុងរយៈពេលខ្លីបំផុតឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ខេត្តកំពង់ចាម ដែលទទួលបន្ទុកអនុវត្តដីកានេះ ។

នៅពេលដែលប៉ូលិសស្រុកពញាក្រែក បានឃាត់ខ្លួនឈ្មោះ "ត" ហៅ "គ" ភេទប្រុស អាយុ១៧ឆ្នាំ (អនីតិជនដែលប្រព្រឹត្តបទឃាតកម្ម) ដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវបានមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចចាប់ខ្លួនបានហើយនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែនាំឈ្មោះ "ត" ហៅ "គ" ទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរភ្លាម ប្រសិនបើអំឡុងពេលនោះស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ ប៉ុន្តែប្រសិនបើមិនអាចនាំខ្លួនឈ្មោះ "ត" ហៅ "គ" ដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួនបានទាន់ពេលវេលាទេនោះ អធិការដ្ឋាននគរបាលស្រុកពញាក្រែកត្រូវតែទទួល និងឃុំខ្លួនបុគ្គលទាំងនេះដោយរក្សាទុកនូវដើមដីកា ឬចុងដីកាដែលមានបញ្ជាក់ត្រឹមត្រូវតាមច្បាប់ ចំពោះការផ្ទេរពន្ធនាគារ ឬមណ្ឌលឃុំពីកន្លែងមួយទៅកន្លែងមួយទៀតត្រូវបានទទួលការចាត់ចែងពីសំណាក់ព្រះរាជអាជ្ញា ។ ចំពោះជនជាប់ចោទឈ្មោះ "ត" ហៅ "គ" ជាអនីតិជនដែលត្រូវឃុំខ្លួននៅក្នុងអធិការដ្ឋាននគរបាលស្រុកពញាក្រែកនោះ ត្រូវដាក់ជននេះឱ្យនៅ

---

[86] ដកស្រង់ចេញពីគេហទំព័រ http://khmeread.com/posts/5884

ដាច់ដោយឡែកពីនីតិជនដែលត្រូវឃុំខ្លួនដែរ ។ បន្ទាប់ពីរក្សាជនជាប់ចោទឈ្មោះ "ត" ដែលជាកម្មវត្ថុនៃដីកានេះមួយរយៈខ្លីរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ស្រុកពញាក្រែកត្រូវតែនាំជនជាប់ចោទ ទៅបង្ហាញខ្លួនយ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរខេត្តកំពង់ចាម ឬដល់អ្នកជំនួសដែលទទួលបន្ទុករឿងនេះ តែបើជនជាប់ចោទឈ្មោះ "ត" មិនត្រូវបានគេនាំខ្លួន នៅថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួសដែលទទួលបន្ទុករឿងនេះទេនោះ ព្រះរាជអាជ្ញាខេត្តកំពង់ចាមជាអ្នកសួរ និងស្តាប់ចម្លើយ ហើយព្រះរាជអាជ្ញានោះត្រូវធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយមកកាន់ចៅក្រមស៊ើបសួរខេត្តកំពង់ចាមវិញ[87] ។

### កថាខណ្ឌទី ៤ : ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺជាសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដើម្បីឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន និងបញ្ជាឲ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនជនត្រូវចោទ ក្នុងគោលបំណងរក្សាកិច្ចស៊ើបសួរដើម្បីភាពយុត្តិធម៌ និងស្វែងរកការពិតនៃបទល្មើសឲ្យបានល្អិតល្អន់។ ការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន ជាវិធានការចុងក្រោយ[88] ។

ជាគោលការណ៍ ជនត្រូវចោទមិនថាជានីតិជន ឬអនីតិជននោះទេត្រូវតែមានសេរីភាព ប៉ុន្តែដោយហេតុថាបទឃាតកម្មជាបទឧក្រិដ្ឋ ហេតុនេះចៅក្រមស៊ើបសួរអាចឃុំខ្លួនអនីតិជនដែលជាជនត្រូវចោទបណ្តោះអាសន្នបានដោយមានសំអាងនូវមូលហេតុសំខាន់ៗមួយចំនួនដូចតទៅ ៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស[89] ។

***ករណីសិក្សាទី ៥***

ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃច័ន្ទ ទី ៣ ខែ សីហា ឆ្នាំ ២០១៥ កន្លងទៅ បានចេញដីកាឃុំខ្លួនយុវជនជាប់ចោទជន ៦នាក់ ពីបទ « ឃាតកម្មដោយមានទារុណកម្ម

---
[87] មាត្រា ២០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[88] មាត្រា ៣៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[89] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ» តាម មាត្រា២០៥ នៃក្រមព្រហ្មទណ្ឌ ជាប់ពាក់ព័ន្ធនឹងករណីចាប់រំលោភសេពសន្ថវៈបូកស្ត្រីម្នាក់ បានសម្រេចម្នាក់ម្តងៗ រួចសម្លាប់នាងចោល យកសពរុំក្នុងអង្រឹង ទៅបោះចោលនៅ ក្នុងដីឡូត៍មួយកន្លែង ក្បែរវត្តអង្គតាមិញ ស្ថិតនៅក្នុង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ កាលសប្តាហ៍មុន។ មន្ត្រីនគរបាល ខណ្ឌពោធិ៍សែនជ័យ បានឲ្យដឹងថា ជនត្រូវចោទទាំង ៦នាក់នេះ មានឈ្មោះ ទី១ ឈ្មោះ "ណ" អាយុ២៩ឆ្នាំ មុខរបរកម្មករសំណង់ , ទី២ ឈ្មោះ "ឡ" អាយុ២០ឆ្នាំ, ទី ៣ ឈ្មោះ "ស" អាយុ១៧ឆ្នាំ, ទី៤ ឈ្មោះ "ល" អាយុ១៩ឆ្នាំ, ទី៥ ឈ្មោះ "ខ" អាយុ២០ឆ្នាំ និង ទី ៦ ឈ្មោះ "ម" អាយុ២០ឆ្នាំ។ ជនសង្ស័យទាំង ៦នាក់នេះ គឺជាកម្មករសំណង់ និងស្នាក់នៅក្នុងការដ្ឋាន សំណង់ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ។ ជនសង្ស័យខាងលើ អាចប្រឈមនឹងការជាប់ពន្ធនាគារ អស់មួយជីវិត ប្រសិនបើតុលាការរកឃើញពីពិរុទ្ធភាពរបស់ពួកគេដូចការចោទប្រកាន់មែននោះ[90]។

ដោយហេតុថាកម្មវត្ថុនៃសារណានេះ ផ្តោតសំខាន់តែទៅលើអនីតិជនដែលប្រព្រឹត្តបទឃាតកម្មតែប៉ុណ្ណោះ ហេតុនេះការបកស្រាយ យើងសូមលើកយកតែជនជាប់ចោទឈ្មោះ "ស" អាយុ១៧ឆ្នាំ មកបកស្រាយតែប៉ុណ្ណោះ ។

បន្ទាប់ពីចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចេញដីកាឃុំខ្លួនទៅលើជនត្រូវចោទឈ្មោះ "ស" អាយុ ១៧ឆ្នាំ ក្នុងចំណោមជនជាប់ចោទ ៦នាក់ ពីបទ « ឃាតកម្មដោយមាន ទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ» កាលពីថ្ងៃច័ន្ទ ទី៣ ខែសីហា ឆ្នាំ២០១៥ ហើយនោះចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ត្រូវជូនដំណឹង ដល់អនីតិជនឈ្មោះ "ស" នោះ ព្រមទាំងទទួលការកត់សម្គាល់របស់អនីតិជននេះទៀតផង។ នេះបើយោងទៅតាមមាត្រា២០៦ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា *"ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឲ្យដំណឹងដល់ជនត្រូវចោទ នឹងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន"*។ ក្រោយពីឃុំខ្លួនជនជាប់ចោទ មន្ត្រីនគរបាលយុត្តិធម៌ខណ្ឌពោធិ៍សែនជ័យត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនឈ្មោះ "ស" បន្ទាប់ពីការចាប់ខ្លួន ប៉ុន្តែប្រសិនបើមិនអាចជូនដំណឹងជាបន្ទាន់បានទេ មន្ត្រីនគរបាលយុត្តិធម៌ខណ្ឌពោធិ៍សែនជ័យត្រូវជូនដំណឹងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានដោយការជូនដំណឹងនោះ ត្រូវជូនដំណឹងអំពីមូលហេតុ

[90] ដកស្រង់ចេញពីគេហទំព័រ https://www.khmerload.com/news/40186

នៃការឃុំខ្លួន និងប្រភេទនៃបទល្មើស ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ និងសិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ចំពោះករណីដែលមន្ត្រីនគរបាលយុត្តិធម៌ខណ្ឌពោធិ៍សែនជ័យមិនអាចធ្វើការទាក់ទងទៅកាន់អ្នកតំណាងដែលច្បាប់បានកំណត់ មន្ត្រីនគរបាលយុត្តិធម៌ខណ្ឌពោធិ៍សែនជ័យត្រូវប្រឹងប្រែងទាក់ទងអ្នកទំនុកបម្រុងដែលឈ្មោះ "ស" បានជ្រើសរើសឬដោយមន្ត្រីនគរបាលយុត្តិធម៌ខណ្ឌពោធិ៍សែនជ័យតែម្តង ដែលមានការទទួលយល់ព្រមពីអនីតិជននោះហើយ នគរបាលខណ្ឌពោធិ៍សែនជ័យក៏ត្រូវជូនដំណឹងភ្លាមទៅកាន់ភ្នាក់ងារសង្គមកិច្ច ដើម្បីឱ្យភ្នាក់ងារសង្គមកិច្ចជួយសេវាគាំទ្រផ្លូវចិត្ត និងសង្គមដល់យុវជន "ស" ។ ប្រសិនបើ "ស" មានមេធាវីការពារខ្លួនរួចរាល់ហើយ មន្ត្រីនគរបាលយុត្តិធម៌ខណ្ឌពោធិ៍សែនជ័យ ត្រូវជូនដំណឹងភ្លាមទៅកាន់មេធាវីនោះ ប៉ុន្តែបើអនីតិជននោះមិនទាន់មានមេធាវីទេ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចត្រូវយកតារាងឈ្មោះមេធាវីដែលមិនយកកម្រៃ ឱ្យទៅអនីតិជនឈ្មោះ "ស" ធ្វើការជ្រើសរើស។ ក្រោយពីមានមេធាវីការពារខ្លួនហើយនោះ មេធាវីដែលអមអនីតិជននោះត្រូវបង្ហាញមធ្យោបាយការពារខ្លួន មានន័យថាមេធាវីត្រូវតែប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ក្នុងការការពារ និងបម្រើឧត្តមប្រយោជន៍ជនត្រូវចោទឈ្មោះ "ស" ដែលជាជនត្រូវចោទនោះតាមវិធីណាក៏បាន ប៉ុន្តែវិធីទាំងនោះត្រូវតែស្របទៅតាមនីតិវិធីច្បាប់ជាធរមាន ។

ជាទូទៅអានុភាពនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនមានអានុភាពឃុំខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ ១៨ (ដប់ប្រាំបី) ឆ្នាំតែប៉ុណ្ណោះ មានន័យថាអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ ។ ក្នុងករណីនេះចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះឲ្យឪពុក ម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល អនីតិជននោះត្រូវប្រគល់ទៅមជ្ឈមណ្ឌល អប់រំថែរក្សាបណ្តោះអាសន្ន ដើម្បីរង់ចាំសេចក្តីសម្រេចរបស់តុលាការ។ នេះបើយោងតាមមាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំពីចំណុច។

ចំពោះអនីតិជនឈ្មោះ "ស" ដែលមានអាយុចាប់ពី ១៧ (ដប់ប្រាំពីរ)ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទ « ឃាតកម្មដោយមាន ទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ» កាលពីថ្ងៃច័ន្ទ ទី ៣ ខែ សីហា ឆ្នាំ ២០១៥ ដោយចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញដែលត្រូវបានចាត់ចូលជាបទឧក្រិដ្ឋ ចិរវេលានៃការឃុំបណ្តោះអាសន្ន យោងតាមមាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តនាថ្ងៃពី០៧ ខែមិថុនា ឆ្នាំ២០០៧បានចែងថា « ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជននោះ មានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ »។

## ផ្នែកទី ៤ : ការបិទការស៊ើបសួរ

***ករណីសិក្សាទី ៦***

"មន្ត្រីនគរបាលយុត្តិធម៌បានប្រាប់អោយដឹងថា យុវនារីអាយុ ១៤ ឆ្នាំម្នាក់នៅខេត្តកំពង់ស្ពឺ បានសារភាពថានាងពិតជាបានចាប់ជ្រមុជទឹកសម្លាប់កុមារម្នាក់អាយុ ៤ ឆ្នាំ ដែលត្រូវជាសាច់ញាតិរបស់ខ្លួន ដើម្បីលួចក្រវិលមាសរបស់ជនរងគ្រោះនោះ យកទៅលក់ ដើម្បីយកទៅទិញទូរស័ព្ទ ។ លោក "ក" ជាអ្នកគ្រប់គ្រងនៅក្នុងអង្គការការពារកុមារភ្នំពេញដែលធ្វើការស៊ើបអង្កេតរាល់អំពើហិង្សាទៅលើកុមារបានប្រាប់ថា នាថ្ងៃសៅរ៍វេលាម៉ោងប្រហែល ២រសៀល ជនសង្ស័យបានប្រើប្រាស់អំពៅសម្រាប់ល្បួងជនរងគ្រោះអាយុ ៤ឆ្នាំនោះ ទៅកាន់ទំនប់ទឹកតូចមួយ នៅក្នុងភូមិក្រាំងស្វាយ សង្កាត់សំរោងទង។ លោក "ក" បានប្រាប់ថា ជនសង្ស័យ បានសារភាពថា ខ្លួនបានជ្រមុជជនរងគ្រោះនោះចូលទៅក្នុងទឹកដោយមានការដាក់សង្កត់ដុំថ្មនៅពីលើខ្លួនជនរងគ្រោះ ដើម្បីឱ្យជនរងគ្រោះលិចចូលទៅក្នុងទឹក ហើយខ្លួនបានលួចក្រវិលរបស់ជនរងគ្រោះ ដែលខ្លួនបានយកទៅលក់បានតម្លៃ ២០.៥ ដុល្លារអាមេរិច រួចជនសង្ស័យនោះបានទិញទូរស័ព្ទម៉ាកណូគា (Nokia) ក្នុងតម្លៃ ១៩ដុល្លារអាមេរិច ពីកន្លែងលក់ដែលមានចម្ងាយ ៥០ម៉ែត្រពីផ្ទះរបស់ជនរងគ្រោះ ។ លោកបានបន្ថែមទៀតថា លោកមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលជនល្មើសនោះជាកុមារីទើបតែអាយុ ១៤ឆ្នាំ ហើយជននោះត្រូវជាបងជីដូនមួយសាច់ឆ្ងាយនៃជនរងគ្រោះទៀត នេះបើតាមលោកប៉ូលីស "ខ" សង្កាត់សំរោងទុងប្រាប់។

លោក "ស" អធិការនគរបាលស្រុកសំរោងទងបាននិយាយថា « ជនរងគ្រោះគឺជាបងប្អូនជីដូនមួយរបស់ជនសង្ស័យ។ ជនសង្ស័យនិងត្រូវបានបញ្ជូនទៅកាន់តុលាការខេត្ត ហើយទំនងជាត្រូវបានចោទប្រកាន់នៅថ្ងៃនេះតែម្តង ។ វាច្បាស់ណាស់ថាវាជាករណីឃាតកម្មហើយវា កើតឡើងដោយចេតនា » ។

លោក "ក" ដែលត្រូវបានគេប្រាប់ឱ្យដឹងពីការលង់ទឹក ដែលបានលិចនៅយប់ថ្ងៃសៅរ៍បានមកដល់កន្លែងកើតហេតុនៅប្រហែលម៉ោង ៥ ព្រឹក នេះបើតាមលោក "ក" និយាយ ។ លោក "ក" បានសរសើរអាជ្ញាធរក្នុងការស៊ើបអង្កេតរបស់ពួកគេ ដែលរកឃើញភស្តុតាងរួមមានក្រវិលជនរងគ្រោះ សំលៀកបំពាក់ដែលជនសង្ស័យបានពាក់នៅពេលប្រព្រឹត្តបទល្មើស និង ទូរស័ព្ទ ដែលនាងបានទិញ នេះបើតាមការនិយាយរបស់លោក "ក"។ លោក "ក" បាននិយាយបន្ថែមទៀតថាលើសពីការសារភាពកំហុស ជនសង្ស័យបានបង្ហាញពីរបៀបដែលនាងបានសម្លាប់ដ៏ឃោរឃៅលើរីដេអូចំពោះមុខអាជ្ញាធរមានសមត្ថកិច្ចផងដែរ។ លោក "ឃ" ដែលជាមេធាវី និងអ្នកជំនាញ ផ្នែកច្បាប់បានថ្លែងថា « នៅក្នុងប្រទេសកម្ពុជាអាយុអប្បបរមានៃ ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺ ១៤ ឆ្នាំ។

ដោយមានភស្តុតាងគ្រាប់គ្រាន់ តុលាការខេត្តនឹងចោទប្រកាន់ជនសង្ស័យនោះពីបទមនុស្សឃាតដោយចេតនា។ ដោយសារតែនាងជាអនីតិជនទំនងជាទទួលបានការពិន័យតិចជាងមនុស្សពេញវ័យដែលប្រព្រឹត្តបទឧក្រិដ្ឋដូចគ្នា »។ លោកមេធាវី "យ" បានមានប្រសាសន៍បន្ថែមថា "ប្រសិនបើនាងមានអាយុ ១៨ឆ្នាំមែន មានន័យថានាងឈានដល់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ...ប៉ុន្តែទំនងជាទទួលបានការកាត់ទោសត្រឹមតែពាក់កណ្តាលនៃមនុស្សពេញវ័យប៉ុណ្ណោះ" ។ លោក "យ" បាននិយាយថាការពិន័យសម្រាប់ឃាតកម្មដោយចេតនានៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាប់ពន្ធនាគារពី ១០ ទៅ ១៥ ឆ្នាំ។ ជនសង្ស័យទំនងជានឹងត្រូវប្រឈមនឹង ៥ ទៅ ៧ឆ្នាំកន្លះប្រសិនបើនាងត្រូវបានផ្តន្ទាទោស។ អាយុរបស់ជនសង្ស័យ និងការចោទប្រកាន់ពីបទឧក្រិដ្ឋយ៉ាងឃោរឃៅនេះបានធ្វើឱ្យលោក "យ" មានការភ្ញាក់ផ្អើល ដោយថ្លែងថា "ខ្ញុំមិនធ្លាប់ឃើញមានករណីស្រដៀងគ្នាដូចនេះទេ ...មិនទាន់ជួបប្រទះ ។" នៅក្នុងឆ្នាំ ២០១៤ មាន ២២១ ករណីនៅក្នុងខេត្តចំនួន ១៧ ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងររួមទាំងការចាប់រំលោភ និងឃាតកម្មដែលជនរងគ្រោះមានអាយុក្រោម ១៥ ឆ្នាំ នេះបើតាមលោក "ក" និយាយ[91]។

លោក "វ" ចៅក្រមនៅតុលាការខេត្ត កំពង់ស្ពឺ បាននិយាយថាក្មេងស្រីនេះត្រូវបានគេដាក់នៅក្នុងការថែទាំបណ្តោះអាសន្នរបស់អង្គការក្រៅរដ្ឋាភិបាលមួយ ។ លោកបាននិយាយថា « នាងមិនអាចស្ថិតក្រោមការមើលថែ របស់ឪពុកម្តាយនាងបានទេ ដោយសារគ្រួសារនាងបារម្ភថានាងទៅធ្វើបាបអ្នកដទៃទៀត »។ លោក "វ" បាននិយាយបន្ថែមថា « ដូចដែលខ្ញុំដឹងក្មេងស្រីអាយុ ១២ឆ្នាំនេះបានប្រើថ្នាំញៀនជាមួយអ្នកដទៃ បើតាមការពិនិត្យគំរូទឹកនោម »។ គ្រួសារជនបង្កនៅតែរស់នៅក្នុងភូមិទំនប់ខ្ពស់ជើងដដែល ហើយទំនាក់ទំនងរវាងពួកគេ និងគ្រួសារជនរងគ្រោះនៅតែមានភាពរកាំរកូសនិងគ្នា ពួកគេស្ថិតនៅក្នុងភាពមិនអើពើនិងគ្នាមិនថាពួកគេជួបគ្នានៅតាមដងវិថី ឬវត្ត ។ អ្នកស្រី "ហ" អាយុ ៥៨ ឆ្នាំជាជីដូនរបស់ជនរងគ្រោះអាយុ ៤ឆ្នាំបានប្រាប់កាសែតភ្នំពេញប៉ុស្តិ៍កាលពីសប្តាហ៍មុនថាក្មេងដែលសម្លាប់ កុមារ "ឈ" មានសភាពដូចជាធម្មតា។ អ្នកស្រីបាននិយាយទៀតថា ពេលពួកគេពិនិត្យទឹកនោមនាងហើយ ពួកគេនិយាយថា នាងប្រើប្រាស់គ្រឿងញៀន « ខ្ញុំមិនដែលឃើញនាងប្រើវាហើយខ្ញុំមិនប្រាកដថាវាជាការពិត ឬអត់នោះទេ » ។ អ្នកស្រី "ហ" បានចាប់អារម្មណ៍លើការផ្តល់សំណងផ្នែករដ្ឋប្បវេណីជាង គាត់បាននិយាយថាគ្រួសារគាត់បានទទួលប្រាក់ ២០០០ដុល្លារ ប៉ុន្តែគាត់គិតថាវាមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ គាត់និយាយទៀតថា "ខ្ញុំបានប្រាប់តុលាការថាខ្ញុំនឹងមិនទទួលយកប្រាក់សំណងទោះបី ១០,០០០ ដុល្លារអាមេរិកក៏ដោយ ដោយសារតែវាមិនអាចទិញជីវិតរបស់ចៅស្រីគាត់អោយត្រឡប់មកវិញបានឡើយ" នោះជាសម្តី

[91] ដកស្រង់ និងបកប្រែចេញពីគេហទំព័រhttp://m.phnompenhpost.com/national/girl-14-admits-killing-child-4

ពេលដែលខ្ញុំខឹងខ្លាំង ប៉ុន្តែឥឡូវនេះខ្ញុំមិនចង់ធ្វើឱ្យមានបញ្ហាវែងឆ្ងាយទៀតឡើយ ប្រសិនបើពួកគេបង់ប្រាក់ ១០,០០០ដុល្លារខ្ញុំនឹងទទួលយកវា។ គាត់បន្តទៀតថា គ្រួសារគាត់ពេលនេះមិនខ្វល់ថានាង ( ជនបង្ក ) ត្រូវឃុំឃាំង ឬអត់ទេ ដោយគាត់និយាយថា "វាមិនសំខាន់ទេថា តើនាងស្ថិតនៅក្នុងគុកឬអត់នោះយើងគ្រាន់តែចង់បានសំណងប៉ុណ្ណោះ។ គ្រាន់តែបើពួកគេដោះលែងនាង នោះឃាតករអាចនិងធ្វើអ្វីដែលនាងចង់ធ្វើ" [92]។

**កថាខណ្ឌទី ១ : ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ ដែលអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់ ។ ចំពោះដីកាបញ្ជូនទៅជំនុំជម្រះ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា អនីតិជនបានប្រព្រឹត្តបទឃាតកម្មដែលជាបទឧក្រិដ្ឋ ហេតុនេះចៅក្រមស៊ើបសួរអាចសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ ។ ដីកានេះត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។ កាលណាចៅក្រមស៊ើបសួរសម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ[93] ។

ប៉ុន្តែក្នុងករណីជាក់ស្តែងដូចករណីសិក្សាទី៦ ជនត្រូវចោទត្រូវបានគេរកឃើញថាមានអាយុត្រឹមតែ ១២ ឆ្នាំតែប៉ុណ្ណោះ ដោយក្រមព្រហ្មទណ្ឌ មាត្រា៣៩ វាក្យខណ្ឌទី២ បានចែងយ៉ាងច្បាស់ថា អាយុទាបបំផុត ១៤ឆ្នាំ ទើបអាចត្រូវទទួលទោសព្រហ្មទណ្ឌបាន។ ដោយយោងទៅតាមអាយុរបស់ជនត្រូវចោទ ចៅក្រមស៊ើបសួរយល់ឃើញថា ជនត្រូវចោទមិនទាន់គ្រប់លក្ខខណ្ឌនៅក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនៅឡើយទេ ហេតុនេះចៅក្រមស៊ើបសួរខេត្តកំពង់ស្ពឺបានបិទការស៊ើបសួរ ដោយអនីតិជននោះស្ថិតក្រោមការត្រួតពិនិត្យរបស់អង្គការក្រៅរដ្ឋាភិបាលដូចដែលបានលើកឡើងនៅក្នុងករណីសិក្សាខាងលើដោយហេតុថាឪពុកម្តាយក្មេងស្រី ១២ ឆ្នាំ ដែលជាឃាតករមិនហ៊ានទទួលនាងមករក្សាបីបាច់ទេ ដោយខ្លាចនាងទៅប្រព្រឹត្តបទល្មើសលើអ្នកដទៃទៀត ។ ដូច្នេះ ការសម្រេចរបស់ចៅក្រមស៊ើបសួរនេះមានសុពលភាពឲ្យភាគីគោរពតាម។

ក្នុងករណីនេះលោក "វ" ដែលជាចៅក្រម ខេត្តកំពង់ស្ពឺយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ហេតុនេះក៏សម្រេចបញ្ជូន អនីតិជននោះទៅកាន់អង្គការក្រៅរដ្ឋាភិបាលមួយដើម្បីឲ្យអនីតិជន រូបនេះទទួលការអប់រំកែប្រែ[94]។ ឯអង្គការក្រៅរដ្ឋាភិបាល ក៏ត្រូវចាត់វិធាន ការសុំព្យួរ ឬសុំ

[92] ដកស្រង់ និងបកប្រែចេញពី https://www.cambodianchildrensfund.org/news/child-protection-unit-despite-confession-girls-murder-still-a-mystery-phnom-penh-post/

[93] មាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[94] មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដកហូតអំណាចមេបា របស់ក្មេងស្រីអាយុ ១២ ឆ្នាំនេះផងដែរ។ ទោះបីចៅក្រមស៊ើបសួរខេត្តកំពង់ស្ពឺបានសម្រេចឲ្យដោះលែងអនីតិជនជាជនត្រូវចោទ ដែលកំពុងត្រូវបានជាប់ឃុំបណ្ដោះអាសន្នហើយក៏ដោយ ក៏អនីតិជននោះត្រូវបានរក្សាទុកនៅក្នុងពន្ធនាគារ ឬ មណ្ឌលណាមួយរហូតដល់ផុតរយៈពេលសម្រាប់បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទនោះ។ ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឲ្យនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំត្រូវបានរក្សាទុកក្នុងពន្ធនាគាររហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្ដឹងឧទ្ធរណ៍។ លើសពីនេះប្រសិនបើក្រោយពេលដែលដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរ ប្រសិនមានលេចឡើងបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញ តាមការផ្ដើមគំនិតរបស់ព្រះរាជអាជ្ញា[95] ។

ដីកាដំណោះស្រាយត្រូវជូនដំណឹង ទៅដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងរយៈពេលខ្លីបំផុត[96] ។

## កថាខណ្ឌទី ២ : ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

បន្ទាប់ពីឆ្លងផុតនូវដំណាក់កាលជាច្រើនក្នុងដំណាក់កាលស៊ើបសួរដោយចៅក្រមស៊ើបសួរហើយនោះ ប្រសិនបើចៅក្រមស៊ើបសួរ ខេត្តកំពង់ស្ពឺយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ហើយចៅក្រមស៊ើបសួរត្រូវតែជូនព័ត៌មាននេះទៅព្រះរាជអាជ្ញា អនីតិជនអាយុ ១២ឆ្នាំនោះដែលជាជនត្រូវចោទ គ្រួសារកុមារ "ឈ" ដែលជាជនរងគ្រោះ និងមេធាវីទាំងសងខាង (ប្រសិនបើមាន)។ ក្រៅពីជូនដំណឹងនេះរួចហើយចៅក្រមស៊ើបសួរក៏ត្រូវបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាក្នុងរយៈពេល ២ (ពីរ)ថ្ងៃបន្ទាប់ពីជូនដំណឹងរួចហើយ ដើម្បីឲ្យព្រះរាជអាជ្ញាពិនិត្យ។ ប៉ុន្តែនៅពេលដែលព្រះរាជអាជ្ញាពិនិត្យសំណុំរឿងរួចរាល់ហើយតែបែរជាយល់ឃើញថារឿងក្ដីនេះចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីម្ដងទៀត ព្រះរាជអាជ្ញាអាចសុំឲ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍បានគ្រប់ពេលវេលា។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមស៊ើបសួរត្រូវតែចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដោយដីកានេះត្រូវមានសំអាងហេតុច្បាស់លាស់ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងរយៈពេលឆាប់បំផុត ។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ

---

[95] មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[96] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

នោះ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[97] ។

បន្ទាប់ពីព្រះរាជអាជ្ញាទទួលបានសំណុំរឿងពីចៅក្រមស៊ើបសួររួចហើយ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយភ្ជាប់ជាមួយដីកាសន្និដ្ឋានស្ថាពរផងដែរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ ក្នុងករណីដែលអនីតិជនដែលជាជនត្រូវចោទត្រូវឃុំខ្លួន និងក្នុងរយៈពេល ១ (មួយ) ខែ បើអនីតិជនដែលជាជនត្រូវចោទនៅក្រៅឃុំ ដោយថិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង ។

ចំពោះករណីដែលព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់ដែរនោះ ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុភ្ជាប់ជាមួយផងដែរ ។ លើសពីនេះទៀតនោះ ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនអនីតិជនដែលជាជនត្រូវចោទ ទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងការចោទប្រកាន់តែម្តង[98] ។

[97] មាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[98] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូក ៤ : ការជំនុំជម្រះលើបទល្មើស

បន្ទាប់ពីឆ្លងកាត់ដំណាក់កាលស្មុគស្មាញជាច្រើននៅក្នុងនីតិវិធីព្រហ្មទណ្ឌរួចរាល់ហើយ ចៅក្រមស៊ើបសួរបានចេញដីកាបញ្ជូនទៅជំនុំជម្រះទៅលើអនីតិជន នោះអនីតិជននឹងត្រូវបាន បញ្ជូនទៅជំនុំជម្រះនៅក្នុងសវនាការទៅតាមនីតិវិធីដូចតទៅ ៖

## ផ្នែកទី ១ : ដំណើរការនីតិវិធីជំនុំជម្រះ

នៅក្នុងដំណាក់កាលសវនាការជាដំណាក់កាលមួយដែលសំខាន់បំផុតដែលអាចសម្រេចថា អនីតិជនត្រូវទទួលទោស ឬត្រូវរួចផុតពីការទទួលទោស ។ ទន្ទឹមនឹងនេះដែរ អនីតិជនត្រូវបាន ទទួលនូវសិទ្ធិពិសេសៗមួយចំនួននៅក្នុងដំណាក់កាលនេះផងដែរ ។

***<u>ករណីសិក្សាទី ៧</u>***

យោងតាមសេចក្តីរាយការណ៍របស់ប៉ូលីសបានអោយដឹងថាក្មេងប្រុសបីនាក់ត្រូវបានក្មេង ជំទង់ម្នាក់កាប់យ៉ាងសាហាវឃោឃៅបណ្តាលអោយស្លាប់ នៅក្នុងខេត្តសៀមរាប កាលពីថ្ងៃសៅរ៍ ព្រោះតែភាពប្រច័ណ្ឌ។

យោងតាមលោក "ក" ប្រធានអង្គការសង្គមស៊ីវិលបានអោយដឹងថា ក្មេងប្រុសឈ្មោះ "ស" អាយុ 8ឆ្នាំ ក្មេងប្រុសឈ្មោះ "ម" អាយុ 13ឆ្នាំ និងក្មេងប្រុសឈ្មោះ "គ" អាយុ 16ឆ្នាំ ត្រូវបានកាប់ ដោយកណ្តៀវច្រូតស្រូវមួយ នៅឃុំគោកដូង ស្រុកអង្គរជុំ បន្ទាប់ពីពួកគេត្រូវបានទម្លាក់ពីលើ ចេញ ពីម៉ូតូ ។ លោកបានថ្លែងថា: «ពីម៉ោង 12 ទៅ 12:30 យប់កាលពីម្សិលមិញ ខណ:ពេលក្មេងប្រុសពា នាក់កំពុងជិះម៉ូតូនៅតាមផ្លូវលំមួយ ពួកគេត្រូវបានប្រឈមមុខនឹងជនល្មើស ដែលជនល្មើសមាន ប្រដាប់ដោយកាំបិតផ្គាក់វែង ហើយវាយប្រហារពួកគេបណ្តាលឱ្យធ្លាក់ពីម៉ូតូ»។ ជនល្មើសបានបន្ត ការវាយប្រហាររបស់គាត់ទៅលើក្បាលជនរងគ្រោះដែលបណ្តាលឱ្យរបួសក្បាលធ្ងន់ធ្ងរទាំងបី និង រងរបួសផ្សេងទៀត។ " ឃាតករដែលត្រូវបានចោទប្រកាន់ បានជិះម៉ូតូជនរងគ្រោះរត់គេចខ្លួនពី កន្លែងកើតហេតុ ប៉ុន្តែត្រូវបានចាប់ខ្លួននៅថ្ងៃបន្ទាប់។ លោក "ភ" អធិការនគរបាលស្រុក អង្គរជុំបាន មានប្រសាសន៍ថា "ប្រហែលប្រាំម៉ោងបន្ទាប់ពីកើតហេតុអាជ្ញាធរបានចាប់ជនសង្ស័យ "ច" អាយុ 17 ឆ្នាំនៅភូមិគោកដូង ឃុំគោកដូង។ " លោកបានបន្ថែមថាជនរងគ្រោះពីរនាក់បានស្លាប់នៅកន្លែង កើតហេតុតែម្តង ហើយម្នាក់ទៀតបានស្លាប់ដោយសាររបួសធ្ងន់នៅតាមផ្លូវទៅកាន់មន្ទីរពេទ្យ។

យោងតាមលោក "ក" ជនរងគ្រោះដែលជាគោលដៅរបស់ឃាតករ គឺជនរងគ្រោះដែល ចាស់ជាងគេក្នុងចំណោមក្មេងប្រុសដែលត្រូវគេសម្លាប់នោះ នេះបើតាមអ្វីដែល ជនសង្ស័យឈ្មោះ "ច" បានសារភាព។ លោកបានបន្ថែមទៀតថា ជនល្មើសបានប្រាប់ប៉ូលីសថាកាលពីប៉ុន្មានថ្ងៃមុន គាត់បានឃើញជនរងគ្រោះជិះម៉ូតូជាមួយនារីម្នាក់នេះជាមូលហេតុមួយដែលគាត់បានសម្រេចធ្វើ

ការប្រព្រឹត្តបទល្មើស។ ជនសង្ស័យឈ្មោះ "ច" ក៏ត្រូវបានគេរាយការណ៍ដែរថា រូបគេបានសារភាពក្នុងការសំលាប់ ជនរងគ្រោះវ័យក្មេង ២រូបទៀត ដោយសារតែពួកគេគឺជាសាក្សីដ៏សំខាន់នៃបទឧក្រិដ្ឋនេះ។ ក្រៅពីស្នេហាត្រីកោណ ពួកគេក៏ធ្លាប់មានប្រវត្តិប្រទូសរ៉ាយរវាងជនរងគ្រោះវ័យច្រើនជាងគេ និងឃាតករ ដែលពួកគេទាំងពីរនាក់សុទ្ធតែរស់នៅក្នុងភូមិគោកដូង។ លោក "ក" បាននិយាយទៀតថា " ជនរងគ្រោះ និងជនល្មើសដែលមានវ័យច្រើនជាងគេ បានធ្វើការនៅប្រទេសថៃនៅចុងឆ្នាំ 2014 ហើយពួកគេក៏បានស្គាល់គ្នានៅទីនោះ។ " ជនរងគ្រោះបានត្រឡប់មកប្រទេសកម្ពុជាវិញដើម្បីគេចពីជនល្មើស ព្រោះពួកគេទាំងពីរក៏ធ្លាប់មានបញ្ហាជាមួយគ្នានៅក្នុងប្រទេសថៃដែរ។ លោក "ក" បានបន្ថែមថាប៉ូលីសអាចយកសំណាក DNA ពីឈាមនៅលើអាវុធរបស់ឃាតករនិងស្នាមប្រឡាក់ឈាមនៅលើអាវរបស់ជនសង្ស័យនិងជនរងគ្រោះ។

លោក "វ" ស្នងការរងនគរបាលខេត្តបានមានប្រសាសន៍ថាឯកសារកំពុងត្រូវបានរៀបចំសម្រាប់ជនជាប់ចោទរូបនេះ ដើម្បីចូលខ្លួននៅតុលាការនៅថ្ងៃនេះសម្រាប់ចោទប្រកាន់ពីបទមនុស្សឃាត និងចោរប្លន់[99]។

## កថាខណ្ឌទី ១ : សិទ្ធិពិសេសដែលអនីតិជនទទួលបានក្នុងការជំនុំជម្រះ

### ក. អាទិភាពក្នុងការជំនុំជម្រះ

ដោយយោងទៅតាមករណីសិក្សាទី៧ ដែលមានជនបង្កជាអនីតិជនឈ្មោះ "ច" បានជាប់សង្ស័យពីបទឃាតកម្ម ហេតុនេះតុលាការខេត្តសៀមរាបត្រូវលើកយករឿងក្តីរបស់អនីតិជននេះមកចាត់ការជាអាទិភាពពិសេសតែម្តង ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន។ មានន័យថា ប្រសិនបើតុលាការដែលមានសមត្ថកិច្ចនេះមានសំណុំរឿងដទៃទៀតដែលត្រូវដោះស្រាយតំណាលគ្នា នោះតុលាការត្រូវលើកយករឿងក្តីក្នុងករណីទី៧ នេះមកចាត់ការមុនប្រសិនបើរឿងក្តីដទៃទៀតជារឿងក្តីរបស់នីតិជនធម្មតា ឬអាចពន្យាពេលបាន។ ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ តុលាការខេត្តសៀមរាបក៏ត្រូវពិចារណាផងដែរពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាពឡើងវិញបានគ្រប់ពេលវេលាប្រសិនបើតុលាការយល់ថាមិនចាំបាច់ធ្វើការឃុំខ្លួន[100] ។

### ខ. ភាពអសាធារណនៃសវនាការ

សវនាការដែលធ្វើឡើងសម្រាប់វិនិច្ឆ័យលើបទឃាតកម្ម ដែលប្រព្រឹត្តដោយអនីតិជនឈ្មោះ "ច" អាយុ ១៧ឆ្នាំខាងលើ ត្រូវធ្វើឡើងជាអសាធារណ: ទាំងការពិភាក្សាដេញដោល និងការប្រកាសសាលក្រម ការធ្វើបែបនេះគឺដើម្បីការពារឧត្តមប្រយោជន៍របស់អនីតិជននេះ ដោយហេតុថាជនបង្ក

---

99 ដកស្រង់ និងបកប្រែពីគេហទំព័រ http://www.phnompenhpost.com/national/teen-accused-triple-murder

100 មាត្រា ៩៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

នៅក្មេងមិនទាន់ចេះពិចារណាច្បាស់លាស់ និងដើម្បីបញ្ចៀសការភ័យខ្លាចនៅពេលសវនាការចាប់ផ្តើមដំណើរការ។ ទោះបីជាសវនាការត្រូវប្រព្រឹត្តឡើងជាអសាធារណៈក៏ពិតមែន ប៉ុន្តែបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីនេះ (អនីតិជនដែលជាជនជាប់ចោទ មេធាវី សាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ) នៅតែអាចចូលរួមក្នុងសវនាការបានដដែល ។ ដោយឡែកចំពោះ ឪពុកម្តាយរបស់យុវជន "ច" ដែលជាជនបង្កក៏ត្រូវតែចូលរួមសវនាការដែរ ប៉ុន្តែប្រសិនបើមានការសំណូមពរពីសំណាក់អនីតិជនរូបនេះផ្ទាល់ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនេះមិនបម្រើ ឬប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់អនីតិជន នោះជនទាំងនេះគឺមិនអាចចូលរួមសវនាការបានទេ[101] ។

## កថាខណ្ឌទី ២ : នីតិវិធីជំនុំជម្រះ

### ក. សមត្ថកិច្ចក្នុងការជំនុំជម្រះ

ចំពោះបទឃាតកម្មសំលាប់ក្មេងប្រុសបីនាក់ខាងលើ ត្រូវបានចាត់ចូលជាបទឧក្រិដ្ឋដោយមានអនីតិជនឈ្មោះ "ច" ជាជនជាប់ចោទជាអ្នកប្រព្រឹត្ត ការជំនុំជម្រះជាលើកដំបូងត្រូវធ្វើឡើងនៅសាលាដំបូងដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន[102] ប៉ុន្តែសម្រាប់ការអនុវត្តជាក់ស្តែងវិញឃើញថាសាលាដំបូងពុំទាន់មានបែងចែកច្បាស់លាស់ទាក់ទងនឹងសមត្ថកិច្ចជំនាញរបស់ចៅក្រមជំនុំជម្រះទៅលើអនីតិជននៅឡើយទេ។ ការជំនុំជម្រះលើបទឃាតកម្មនេះ ការសម្រេចលើរឿងក្តីនៅជំណាក់កាលសាលាដំបូងចៅក្រមដែលមានសមត្ថកិច្ចត្រូវសម្រេចជាក្រុមសមូហភាពដោយមានចៅក្រម ៣ ( បី ) រូប[103]។ គួរបញ្ជាក់ជាថ្មីថាសាលាដំបូងដែលមានសមត្ថកិច្ចលើរឿងក្តីនេះត្រូវតែជាសាលាដំបូងដែលបទល្មើសបានកើតឡើង ឬសាលាដំបូងនាលំនៅឋានរបស់អនីតិជនដែលជាជនជាប់ចោទ ឬសាលាដំបូងនាទីកន្លែងដែលចាប់ខ្លួនអនីតិជន និយាយឱ្យចំទៅគឺ តុលាការខេត្តសៀមរាបតែម្តង [104]។

### ខ. នីតិវិធីនៃដំណើរការក្នុងពេលសវនាការ

បន្ទាប់ពីតុលាការខេត្តសៀមរាបបានត្រួតពិនិត្យនូវរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច ព្រមទាំងឆ្លងកាត់នូវរាល់នីតិវិធីមុនពេលសវនាការរួចរាល់ហើយ តុលាការត្រូវបើកសវនាការដោយមាននីតិវិធីមួយចំនួនដែលនឹងត្រូវបានបកស្រាយដូចតទៅ ៖

---

[101] មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[102] មាត្រា ៤៤ វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[103] មាត្រា ៤៤ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[104] មាត្រា ២៩០ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

➢ **ដំណាក់កាលនៃការពិភាក្សាដេញដោល**

ជាទូទៅការពិភាក្សាដេញដោលត្រូវធ្វើឡើងជាសាធារណៈ ប៉ុន្តែចំពោះករណីដូចករណីទី៧ ដែលអនីតិជនជាជនជាប់បែបនេះសវនាការត្រូវបានធ្វើឡើងជាអសាធារណៈវិញ។ នៅក្នុងដំណាក់កាលនេះ ប្រធានសវនាការជាអ្នកដឹកនាំការពិភាក្សាដេញដោល ដោយត្រូវរ៉ាប់រងឲ្យសិទ្ធិខាងការការពារបានប្រព្រឹត្តដោយសេរី សណ្តាប់ធ្នាប់ ប៉ុន្តែប្រធានសវនាការអាចធ្វើការបដិសេធពីការពិភាក្សាដេញដោលនូវអ្វីដែលមានគោលបំណងអូសបន្លាយ ឬគ្មានប្រយោជន៍ ឬគ្មានវិភាគទានអ្វីដល់ការសំដែងឲ្យឃើញការពិត ។ ប្រធានសវនាការអាចហាមឃាត់អនីតិជនខ្លះ ឬទាំងអស់ ព្រមទាំងបុគ្គលទាំងអស់ដែលបង្កឲ្យមានការច្របូកច្របល់ដល់របៀបរៀបរយ នៃការពិភាក្សាដេញដោលមិនឲ្យចូលក្នុងបន្ទប់សវនាការ។ ក្នុងការបំពេញមុខងាររបស់ខ្លួន ប្រធានសវនាការអាចប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីរក្សាឲ្យបាននូវការប្រព្រឹត្តទៅឲ្យបានល្អនៃដំណើរការសវនាការ[105] ។

ជាកិច្ចចាប់ផ្តើមការពិភាក្សាដេញដោលគិតចាប់ពីពេល ក្រឡាបញ្ជីហៅឈ្មោះអនីតិជនឈ្មោះ "ច" ដែលជាជនជាប់ចោទ ភាគីខាងក្មេងប្រុសបីនាក់ដែលជាជនរងគ្រោះ(ដើមបណ្តឹងរដ្ឋប្បវេណី) ភាគីខាងជនជាប់ចោទ (អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) សាក្សី និងអ្នកជំនាញ ហើយធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណជនទាំងនោះឲ្យបានត្រឹមត្រូវ។ ក្នុងករណីភាគីខាងក្មេងប្រុសបីនាក់ដែលជាជនរងគ្រោះ (ដើមបណ្តឹងរដ្ឋប្បវេណី) ឬ ភាគីខាងជនជាប់ចោទ (អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) ត្រូវបានតំណាងដោយសហព័ទ្ធ ឬញាតិលោហិត ក្រឡាបញ្ជីក៏ត្រូវត្រួតពិនិត្យអត្តសញ្ញាណនៃអ្នកតំណាង និងសុពលភាពនៃការប្រគល់សិទ្ធិជាអ្នកតំណាង។ បន្ទាប់ពីធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរួច ភាគីនីមួយៗត្រូវអង្គុយនៅតាមកន្លែងដែលទុកសម្រាប់ឲ្យពួកគេនៅក្នុងបន្ទប់សវនាការ។ ចំពោះអ្នកជំនាញ និងសាក្សីត្រូវថយខ្លួនទៅនៅក្នុងបន្ទប់រង់ចាំ ដែលនៅក្នុងបន្ទប់នោះ ពួកគេមិនអាចមើលឃើញ ឬ ឮអ្វីដែលប្រព្រឹត្តនៅក្នុងសវនាការនោះទេ។ ឯសាក្សីវិញគឺតម្រូវមិនឲ្យទាក់ទងនឹងគ្នាឡើយមិនថានៅក្នុងបន្ទប់រង់ចាំ ឬក្នុងពេលសវនាការនោះទេ[106] ។

❖ **ការសួរចម្លើយអនីតិជនជាជនជាប់ចោទ**

មុនពេលការសួរចម្លើយលើអនីតិជនឈ្មោះ "ច" ត្រូវបានកើតឡើង ប្រធានសវនាការត្រូវប្រាប់ដល់ជនជាប់ចោទឲ្យបានដឹង អំពីអំពើដែលគេចោទប្រកាន់លើខ្លួន និងធ្វើការសួរចម្លើយទៅលើអនីតិជននូវគ្រប់សំណួរដែលមានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត ទាំងផ្នែកដាក់បន្ទុកទាំងផ្នែកដោះបន្ទុក។ បន្ទាប់ពីប្រធានសវនាការបានចោទសួរអនីតិជនរួចរាល់ហើយ ព្រះរាជអាជ្ញា

[105] មាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[106] មាត្រា ៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរសួរដល់អនីតិជនជាជនជាប់ចោទ ប៉ុន្តែគ្រប់សំណួរទាំងអស់ដែលត្រូវលើកឡើងសួរទៅអនីតិជន ត្រូវតែមានការអនុញ្ញាតពីប្រធានសវនាការ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរឬទេ[107] ។

នៅពេលសវនាការ តុលាការប្រើប្រាស់នីតិវិធីកុមារមេត្រីទៅលើអនីតិជន។ ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឲ្យតុលាការខេត្តសៀមរាបប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ[108] ។ ចំពោះ ករណីជាក់ស្តែង នីតិវិធីត្រូវបានអនុវត្តឡើង គឺអាស្រ័យទៅលើរឿងក្តីនោះ ប៉ុន្តែភាគច្រើននៃរឿងក្តីទាំងអស់នោះ គឺពុំបានអនុវត្តនោះទេ។ បន្ទាប់ពីតុលាការបានស្តាប់ចម្លើយរបស់អនីតិជន "ច" រួចរាល់ហើយ តុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ ។ ចម្លើយសារភាពដែលបានមកពីការគំរាមគំហែងការបង្ខិតបង្ខំ ឬការមិនយល់ដឹងអំពីផលវិបាកនៃការសារភាពមិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ ។ លើសពីនេះ តុលាការក៏ត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីសង្វាក់គ្នានៃចម្លើយសារភាព និងភស្តុតាងផ្សេងៗទៀតនៃបទល្មើស[109] ។

- ❖ **ការស្តាប់ចម្លើយភាគីដែលពាក់ព័ន្ធ**

ក្រោយពីសួរ និងស្តាប់ចម្លើយរបស់អនីតិជនឈ្មោះ "ច" អាយុ ១៧ឆ្នាំ ដែលជាជនជាប់ចោទរួចរាល់ ប្រធានសវនាការក៏ត្រូវស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញទៅតាមលំដាប់លំដោយដែលប្រធានសវនាការយល់ឃើញថាមានប្រយោជន៍។ ក្រៅពីជនទាំងឡាយខាងលើប្រធានសវនាការក៏អាចធ្វើការស្តាប់នូវចម្លើយរបស់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី ។ ទន្ទឹមនឹងនេះដែរ បន្ទាប់ពីសហចៅក្រមបានសាកសួររួចរាល់ហើយ ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរសួរទៅជនទាំងដែលបានរៀបរាប់ខាងលើ ប៉ុន្តែគ្រប់ការលើកឡើងនូវសំណួរទាំងអស់ត្រូវតែមានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់ព្រះរាជអាជ្ញា

107 មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
108 មាត្រា ៤៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
109 មាត្រា ៥៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

មេធាវី សំណួរផ្សេងៗទៀតដែលបានលើកឡើងត្រូវសួរតាមរយៈប្រធានសវនាការ ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥតស្សរចិត្តថា តើសំណួរនេះត្រូវតែសួរ ឬទេ[110] ។

ប្រសិនបើការពិភាក្សាដេញដោលមិនបានបញ្ចប់ក្នុងពេលសវនាការនោះទេ តុលាការអាចបន្តនៅពេលសវនាការក្រោយ តាមកាលបរិច្ឆេទដែលខ្លួនបានកំណត់[111] ។

➢ **ដំណាក់កាលធ្វើសេចក្តីសន្និដ្ឋាន**

បន្ទាប់ពីបានធ្វើការពិភាក្សាដេញដោលទៅលើអនីតិជនឈ្មោះ "ច" អាយុ ១៧ឆ្នាំ និងជនដែលពាក់ព័ន្ធចប់សព្វគ្រប់ហើយនោះ ប្រធានសវនាការបើកសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អនីតិជនដែលជាជនជាប់ចោទធ្វើការកត់សម្គាល់ខ្លីៗ។ ក្រោយពីនេះជាការសន្និដ្ឋានការពារពីសំណាក់មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ព្រះរាជអាជ្ញាខេត្តសៀមរាបត្រូវធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ បន្ទាប់ពីមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើការសន្និដ្ឋានចប់ ការសន្និដ្ឋានរបស់ព្រះរាជអាជ្ញា សំដៅដល់ការបកស្រាយបំភ្លឺឲ្យឃើញថាអនីតិជនជាជនជាប់ចោទមានពិរុទ្ធភាព ឬមិនមានពិរុទ្ធភាពដើម្បីឲ្យចៅក្រមជំនុំជម្រះពិចារណា និងធ្វើការវិនិច្ឆ័យឲ្យស្របតាមច្បាប់។ ព្រះរាជអាជ្ញាក៏អាចធ្វើប្តឹងសុំដោយផ្ទាល់មាត់ ប្រសិនបើខ្លួនយល់ថាសមស្របទៅនិងប្រយោជន៍ល្អនៃយុត្តិធម៌។ បន្ទាប់ពីព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានចប់ មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទនឹងត្រូវធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីរបស់ខ្លួន ចំពោះការសន្និដ្ឋាននេះព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការឆ្លើយតបទៅវិញបាន។ ដោយឡែកអនីតិជនដែលជាជនជាប់ចោទ និងមេធាវីរបស់ខ្លួន ត្រូវនិយាយក្រោយគេបង្អស់ជានិច្ច[112] ។

➢ **ដំណាក់កាលថយទៅពិភាក្សារបស់សហចៅក្រម**

បន្ទាប់ពីសវនាការបានឆ្លងផុតនូវនីតិវិធីពិភាក្សាដេញដោល និងការធ្វើសេចក្តីសន្និដ្ឋានរួចរាល់ហើយ សហចៅក្រមដែលមានចៅក្រមមួយរូបជាប្រធានសវនាការនឹងប្រកាសថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាដើម្បីសម្រេចមុននឹងចេញសាលក្រម ។ ក្រោយពីសហចៅក្រមបានថយខ្លួនចូលទៅពិភាក្សាសម្រេចនៅក្នុងបន្ទប់សម្ងាត់ហើយនោះ គ្មានបណ្តឹងសុំណាមួយអាចត្រូវបានដាក់ជូនតុលាការបានទៀតទេ ហើយក៏គ្មានទឡ្ហីករណ៍ ឬភស្តុតាងណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានឡើយ ។ នៅក្នុងការពិភាក្សារបស់សហចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងការពិភាក្សាសម្រេចនេះទេ[113] ។

---

110 មាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

111 មាត្រា ៣៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

112 មាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

113 មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**ផ្នែកទី២: ការចេញសាលក្រមផ្តន្ទាទោសលើអនីតិជន**

ការប្រកាសសាលក្រមជាដំណាក់កាលចុងក្រោយនៃនីតិវិធីជំនុំជម្រះ សាលក្រមអាចត្រូវបានប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ចំពោះករណីដែលការពិភាក្សាដេញដោលមិនត្រូវបានបញ្ចប់នៅក្នុងសវនាការលើកមុន ។ ក្នុងករណីដែលការប្រកាសសាលក្រមត្រូវប្រកាសនៅពេលសវនាការលើកក្រោយ ប្រធានសវនាការត្រូវប្រកាសជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមាន អំពីថ្ងៃដែលត្រូវប្រកាសសាលក្រម[114] ។

ជាគោលការណ៍ សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជនឈ្មោះ "ច" អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី ។ ទោះជាយ៉ាងនេះក្តីសាលក្រមក៏អាចប្រកាសកំបាំងមុខអនីតិជនបានដែរ ប្រសិនបើការប្រកាសសាលក្រមចំពោះមុខធ្វើឲ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជន[115] ។

**កថាខណ្ឌទី១ : ទោសដែលត្រូវអនុវត្តលើអនីតិជន**

ក្នុងករណីតុលាការខេត្តសៀមរាបសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនឈ្មោះ "ច" អាយុ ១៧ឆ្នាំ ទៅលើបទល្មើសដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ពីបទឃាតកម្ម អតិបរមា និងអប្បបរមានៃទោសត្រូវបានបន្ថយមកត្រឹមពាក់កណ្តាល។ គួរបញ្ជាក់ដែរថា បទឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ[116] ។ ការបន្ថយកម្រិតនៃទោសបែបនេះធ្វើអោយ អនីតិជនត្រូវទទួលទោសជាប់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ទៅ ៧ (ប្រាំពីរ) ឆ្នាំ ៦ (ប្រាំមួយ) ខែ ហើយក្រមព្រហ្មទណ្ឌក៏មិនបានចែងពីការពិន័យជាប្រាក់ឡើយចំពោះបទឃាតកម្ម។ ការបន្ថយទោសជាប់ពន្ធនាគារមកត្រឹមពី ៥(ប្រាំ)ឆ្នាំ ទៅ ៧(ប្រាំពីរ)ឆ្នាំ ៦(ប្រាំមួយ)ខែ មិនអាចឲ្យអនីតិជនរួចផុតពីបទឧក្រិដ្ឋបានទេ ដោយសារទោះបីជាការបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬ តិចជាង ៥ (ប្រាំ)ឆ្នាំក៏ដោយ ក៏បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល[117] ។

ទោះបីជាអនីតិជននោះត្រូវបានទទួលនូវការបន្ថយទោសពាក់កណ្តាលក៏ពិតមែន ប៉ុន្តែអនីតិជនក៏អាចទទួលរងនូវទោសបន្ថែមមួយចំនួនដែលបានចែងក្នុងមាត្រា ១៦១នៃក្រមព្រហ្មទណ្ឌ ៖

*"១-ការរឹបអូសឧបករណ៍ សម្ភារ: ឬ វត្ថុអ្វីមួយដែលប្រើក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមាន*

[114] មាត្រា ៣៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[115] មាត្រា ៥៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[116] មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[117] មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

*គោលដៅប្រព្រឹត្តបទល្មើស ។*

*២-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។*

*៣-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។*

*៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។*

*៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ។"*

ទោសការងារសហគមន៍ និងការព្យួរទោសសាកល្បងមិនអាចយកមកអនុវត្តបានទេក្នុងករណីនេះ ដោយហេតុថាទោសការងារសហគមន៍អាចអនុវត្តបាន កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ ( បី ) ឆ្នាំ[118] ឯការព្យួរទោសសាកល្បងអាចអនុវត្តបាន កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលមានរយៈពេលពី ៦ ( ប្រាំមួយ ) ខែ ទៅ ៥ ( ប្រាំ ) ឆ្នាំ[119] ។ ប៉ុន្តែក្នុងករណីនេះអតិបរមានៃទោសដែលអនីតិជនត្រូវទទួលគឺរហូតដល់ទៅ ៧ ( ប្រាំពីរ) ឆ្នាំ ៦ ( ប្រាំមួយ ) ខែឯណោះ អាស្រ័យហេតុនេះអនីតិជនមិនអាចទទួលទោសការងារសហគមន៍ ឬការព្យួរទោសសាកល្បងជំនួសទោសជាប់ពន្ធនាគារបាននោះទេ ។ លើសពីនេះទោះបីជាអនីតិជនបានប្រព្រឹត្តបទឃាតកម្ម ហើយស្ថិតនៅក្នុងស្ថានភាពមិនរាងចាលក៏ដោយក៏តុលាការមិនអាចយកបទប្បញ្ញត្តិស្ដីពីការមិនរាងចាល ទៅអនុវត្តលើអនីតិជនបានដែរ[120]។ ផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថាអនីតិជនគួរតែទទួលបាននូវស្ថានសម្រាលទោស អប្បបរមានៃមូលទោសនៃបទឧក្រិដ្ឋដែលមានអប្បរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១០ ( ដប់ ) ឆ្នាំ នោះអប្បរមាត្រូវបន្ថយមកត្រឹម ១ ( មួយ ) ឆ្នាំ[121]។ ជាក់ស្តែងបទឃាតកម្មត្រូវទទួលទោសដែលមានអប្បបរមានៃទោសស្មើនឹង ១០ ( ដប់ ) ឆ្នាំ ហេតុនេះប្រសិនបើ អនីតិជនទទួលបាននូវស្ថានសម្រាលទោសនោះអប្បរមានៃទោសត្រូវបន្ថយមកត្រឹម ១ (មួយ) ឆ្នាំវិញ ។

**កថាខណ្ឌទី២ : ការអនុវត្តទោស**

បន្ទាប់ពីសហចៅក្រមខេត្តសៀមរាបបានចេញសាលក្រម ដោយសម្រេចតាមការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលបានចោទប្រកាន់ទៅអនីតិជនពីបទឃាតកម្មបានចូលជាស្ថាពរ

118 មាត្រា ៧២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

119 មាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

120 មាត្រា ១៦៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

121 កថាខណ្ឌទី២ ចំនុចទី ១ នៃមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ហើយនោះ អនីតិជននោះនឹងក្លាយទៅជាទណ្ឌិត ។ ក្រោយពីក្លាយខ្លួនជាទណ្ឌិតហើយនោះ ទណ្ឌិត "ច" នឹងត្រូវបញ្ជូនទៅមណ្ឌលយុវនីតិសម្បទាដើម្បីធ្វើការឃុំខ្លួនក្នុងគោលបំណងឲ្យ អនីតិជន "ច" ជាទណ្ឌិតទទួលបាននូវកម្មវិធីស្តារនីតិសម្បទាជាអាទិ៍មាន ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈ ក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយទៅជាពលរដ្ឋសុចរិត និង មានប្រយោជន៍ដល់សង្គមជាតិ[122] ។

នៅក្នុងមណ្ឌលយុវនីតិសម្បទាការអនុវត្តទោស គឺតម្រូវឲ្យអនីតិជនជាទណ្ឌិតត្រូវបានឃុំខ្លួនដោយឡែកពីនីតិជន ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលដល់អាយុ ១៨ ( ដប់ប្រាំបី ) ក្នុងពេលបាន និងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវរក្សាទុកនៅក្នុងមណ្ឌលបន្តរហូតដល់អាយុក្រោម ២៤ ( ម្ភៃបួន ) ឆ្នាំ ។ នៅពេលទណ្ឌិតឈានចូលដល់អាយុ ២៤ (ម្ភៃបួន) ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជនវិញ។ ការអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទាអនីតិជន ត្រូវបានឃុំខ្លួននៅក្នុងអគារដាច់ដោយឡែកទៅតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ។ ចំពោះអនីតិជនជាទណ្ឌិតដែលមានភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា ។ ក្នុងករណីមានអនីតិជនជាទណ្ឌិតណាម្នាក់កើតជម្ងឺឆ្លង ទណ្ឌិតនោះត្រូវរក្សាទុកនៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកពីទណ្ឌិតដទៃដែលមានសុខភាពធម្មតា[123] ។

ថ្វីត្បិតតែអនីតិជនបានក្លាយជាទណ្ឌិតហើយក៏ពិតមែនប៉ុន្តែ នៅក្នុងដំណាក់កាលនៃការអនុវត្តទោសពួកគេត្រូវបានទទួលនូវសិទ្ធិជាមូលដ្ឋានយ៉ាងច្រើន ដែលមានចែងក្នុងមាត្រា ៨០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលមានចែងដូចតទៅ ៖

- *"សិទ្ធិទទួលបានការសិក្សាអប់រំ*
- *សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបរាងកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឲ្យនៅឯកា ការដាក់កំហិត ឬការបដិសេធមិនឲ្យមានប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ*
- *សិទ្ធិទទួលបានវិធានការដាក់ពិន័យដែលស្របតាមសេចក្តីថ្លៃថ្នូររបស់អនីតិជន*
- *សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច*

[122] មាត្រា ៧៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[123] មាត្រា ៨២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- *សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី*
- *សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជំងឺ ឬរបួស និងផ្តល់ដំណឹងទៅតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី*
- *សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្តិ*
- *សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធិភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន*
- *សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន ។"*

ក្នុងនាមជាទណ្ឌិតពិតមែន ប៉ុន្តែការអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទាអនីតិជន "ច" មិនត្រឹមតែទទួលបាននូវសិទ្ធិជាមូលដ្ឋានប៉ុណ្ណោះទេ នៅថែមទាំងទទួលបាននូវសេវាមួយចំនួនទៀត។ អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបន្ទុកនៅក្នុងមណ្ឌលយុវនីតិសម្បទាទាំងអស់ជាអ្នកផ្តល់ឲ្យអនីតិជន ដោយសេវាទាំងនោះរួមមានសេវា ៖

- ការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ
- សុខភាពផ្លូវកាយ និងផ្លូវចិត្តសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងអនីតិជនជាប់ឃុំនៃព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងទៀតដែលលើកស្ទួយសុខភាព និងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឲ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានអាកប្បកិរិយា និងជំនាញដែលជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយឲ្យពួកគេ វិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង[124] ។

[124] មាត្រា ៨១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ក្នុងករណីដែលអនីតិជន "ច" ជាទណ្ឌិតបានអនុវត្តទោសបានចំនួនពាក់កណ្តាលនៃទោស នៅក្នុងមណ្ឌលឃុំនីតិសម្បទា នោះឈ្មោះ "ច" ខ្លួនឯងផ្ទាល់ មេធាវីរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ប្រធានមណ្ឌលឃុំនីតិសម្បទា ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ បេសកកម្មការទូត ឬកុងស៊ុលបរទេស ចំពោះអនីតិជនជាជនបរទេស សុទ្ធតែអាចស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌបាន[125]។ ការតម្រូវឲ្យអនីតិជនត្រូវអនុវត្តទោសនៅក្នុងមណ្ឌលឃុំនីតិសម្បទាឲ្យបានចំនួនពាក់កណ្តាល ទើបអាចស្នើសុំដោះលែងដោយមានលក្ខខណ្ឌបានដោយសារតែបទល្មើសដែលអនីតិជន "ច" បានប្រព្រឹត្តជាបទឃាតកម្ម ។

[125] មាត្រា ៧២ និង ៧៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើ យើងឃើញថាគ្មានបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទឃាតកម្មហើយអាចគេចវៀសមិនទទួលខុសត្រូវនូវបទល្មើស ដែលជាបទឧក្រិដ្ឋមានការប៉ះពាល់ដល់ជីវិតមនុស្សបានឡើយ សូម្បីតែអនីតិជនក៏ត្រូវប្រឈមមុខនឹងការទទួលទោសផងដែរ។ ដូច្នេះ នៅពេលដែលអនីតិជនណាមួយជាប់សង្ស័យថាបានសម្លាប់មនុស្ស មន្ត្រីនគរបាលយុត្តិធម៌ចាប់ផ្តើមស្វែងរក ប្រមូលភស្តុតាងនានា និងធ្វើការសួរចម្លើយអនីតិជននោះ ដើម្បីធានាដល់ភាពយុត្តិធម៌ជៀសវាងការចោទប្រកាន់ខុស។ ក្នុងដំណាក់កាលនេះ បើអនីតិជននោះពុំត្រូវបានរកឃើញពីពិរុទ្ធភាពរបស់ខ្លួនទេ អនីតិជននោះនឹងត្រូវបានដោះលែង។ ផ្ទុយមកវិញ ករណីរកឃើញថាមានពិរុទ្ធភាព មន្ត្រីនគរបាលយុត្តិធម៌ត្រូវកសាងសំណុំរឿង និងបញ្ជូនអនីតិជននោះទៅអង្គអយ្យការសម្រាប់ពិនិត្យ និងសម្រេចក្នុងការចោទប្រកាន់។ ក្រោយពីអង្គអយ្យការពិនិត្យឃើញថា សំណុំរឿង និងភស្តុតាង ដែលដាក់បញ្ជូនមកសអោយឃើញពីពិរុទ្ធភាពរបស់អនីតិជននោះពិតមែន ព្រះរាជអាជ្ញា នឹងសម្រេចធ្វើការចោទប្រកាន់ទៅលើអនីតិជននោះអំពីបទឃាតកម្មដែលជននោះបានប្រព្រឹត្ត រួចបញ្ជូនជននោះទៅកាន់ចៅក្រមស៊ើបសួរសម្រាប់បន្តនីតិវិធី។ ចៅក្រមស៊ើបសួរ នឹងបើកការស៊ើបសួរភ្លាមបន្ទាប់ពីទទួលបានដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ព្រោះដោយសារតែបទឃាតកម្មជាបទឧក្រិដ្ឋ ការស៊ើបសួរគឺជានីតិវិធីមួយចាំបាច់ដែលត្រូវអនុវត្តដូចមានចែងក្នុងច្បាប់។ ក្រោយពីបញ្ចប់នីតិវិធីនៃការស៊ើបសួររួច អនីតិជនរូបនោះនឹងត្រូវបញ្ជូនទៅជំនុំជម្រះនៅក្នុងសវនាការ។ នៅពេលនោះហើយ ជាពេលដែលសហចៅក្រមថ្លឹងថ្លែងអំពីទម្ងន់ទោស នឹងសម្រេចថាត្រូវលើកលែងការចោទប្រកាន់ ឬត្រូវផ្តន្ទាទោសទៅលើជនជាប់ចោទ ជាអនីតិជនត្រឹមកម្រិតណា។

ចំនុចខាងលើនេះ គឺឆ្លើយតបទៅនឹងបញ្ហាដែលបានចោទទាក់ទងទៅនឹងចម្ងល់អំពីចំណាត់ការលើបទឃាតកម្មក្នុងករណីជនល្មើសនោះជាអនីតិជន។ បន្ថែមពីនេះ លក្ខណៈគួរឱ្យកត់សម្គាល់គឺថាអាយុរបស់អនីតិជនសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ ដូចបទឃាតកម្មជាដើម គឺចាប់ពីអាយុ ១៤ឆ្នាំឡើងទៅ ហើយចំពោះទោសទណ្ឌវិញ គឺត្រូវបានបន្ធូរបន្ថយទោសពាក់កណ្តាលស្របតាមច្បាប់កំណត់។ នេះជាចំនុចគួរឱ្យកត់សម្គាល់មួយផងដែរ ព្រោះគ្មានទេការបន្ធូរបន្ថយទោសពាក់កណ្តាលសម្រាប់នីតិជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទេ។ ចំនុចពិសេសមួយទៀត ត្រង់ថារាល់សំណុំរឿងបទឃាតកម្ម ដែលអនីតិជនជាអ្នកប្រព្រឹត្ត គឺត្រូវបានតុលាការបន្លឿននីតិវិធីជា

និច្ច បានសេចក្ដីថាទោះបីជានៅសាលាដំបូងរាជធានី-ខេត្តមានសំណុំរឿងជាច្រើនពុំទាន់បានយកមកជំនុំជម្រះក៏ដោយ ក៏នៅពេលដែលសំណុំរឿងរបស់អនីតិជននោះដាក់បញ្ជូនទៅ នោះសាលាដំបូងរាជធានី-ខេត្តនឹងយកសំណុំរឿងនោះមកពិនិត្យ និងជំនុំជម្រះមុនគេ។ រីឯចំណាត់ការវិញ គឺអនុវត្តទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ច្បាប់ស្ដីយុត្តិធម៌អនីតិជន និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលមានជាធរមាន។

បើក្រឡេកទៅមើលក្នុងសង្គមជាក់ស្ដែង យើងសង្កេតឃើញថាទោះបីជាមានការពង្រឹងផ្នែកច្បាប់ ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច រួមទាំងស្ថាប័នកំពូលទាំងបី គឺ ស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ហើយក៏ដោយក៏នៅតែមានបទល្មើសឃាតកម្មបានកើតឡើងដដែលជាក់ស្ដែងដូចមានក្នុងករណីសិក្សាដែលបានបកស្រាយនៅក្នុងខ្លឹមសារខាងលើ។ នេះសបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាជាពិសេសអនីតិជនមិនទាន់យល់ច្បាស់អំពីចំណាត់ការ និងទណ្ឌកម្មនៃបទឃាតកម្មនៅឡើយទេ ។

## អនុសាសន៍

ថ្វីត្បិតតែ ការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជាមានការវិវត្តពីមួយដំណាក់កាលទៅមួយដំណាក់កាលមានភាពប្រសើរជាងមុនឆ្ងាយហើយយ៉ាងណាក៏ដោយ ក៏នៅតែមានភាពខ្វះចន្លោះប្រហោងខ្លះបានកើតមានឡើង ជាពិសេសក្នុងបទល្មើសទាំងនោះមានបទឃាតកម្មជាបទឧក្រិដ្ឋដែលគួរស្ដប់ខ្ពើម ហើយជនល្មើសជាអនីតិជនដែលជាទំពាំងស្នងឬស្សីថែមទៀត ។

ហេតុនេះក្នុងនាមពួកយើងជានិស្សិត ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ យល់ឃើញថា ដើម្បីបង្ការ និងបញ្ឈប់បទឃាតកម្ម ដែលប្រព្រឹត្តដោយអនីតិជននៅក្នុងប្រទេសកម្ពុជាបាន ត្រូវពឹងផ្អែកទៅលើកត្តាមួយចំនួនដូចជា ៖

- ស្ថាប័នជាតិៗកំពូលមានអង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការគួរតែ បន្តនូវការពង្រឹងផ្នែកផ្សព្វផ្សាយ ទាក់ទងមូលដ្ឋានច្បាប់ ដើម្បីឱ្យប្រជាពលរដ្ឋទូទៅនៅទូទាំងប្រទេសបានយល់ដឹងអំពីច្បាប់កាន់តែច្បាស់ ព្រោះនៅពេលដែលពួកគាត់បានដឹងពីទោសទណ្ឌដែលមានជាធរមានហើយនោះនឹងធ្វើឱ្យប្រជាពលរដ្ឋគ្រប់រូបមានការក្រែងរអាល មិនហ៊ានប្រព្រឹត្តបទល្មើសទៀតនោះទេ។
- រដ្ឋាភិបាលគួរតែជួយសម្រួល ក្នុងការបង្កើតមូលនិធិ ឬអង្គការក្រៅរដ្ឋាភិបាល ក្នុងគោលបំណងផ្ដត់ផ្គង់ជាជំនួយផ្នែកស្មារតី សតិបញ្ញា និងផ្សព្វផ្សាយពាក់ពន្ធ័នៅបញ្ហាច្បាប់នៅក្នុងប្រទេសកម្ពុជា។

- រដ្ឋមន្ត្រីក្រសួងអប់រំ គួរតែពិចារណាទៅលើការបញ្ចូលមូលដ្ឋានច្បាប់ជាពិសេសពាក់ពន្ធ័ជាមួយបទឃាតកម្ម ទៅក្នុងកម្មវិធីសិក្សាចំណោះទូទៅផងដែរ ។
- ត្រូវពង្រឹងអោយបាននូវការអនុវត្តច្បាប់ដោយយុត្តិធម៌មិនលំអៀង ទៅលើជនគ្រប់រូបដែលបានប្រព្រឹត្តបទល្មើសដូចគ្នា។
- ត្រូវជ្រើសរើសយកតែបុគ្គលណាដែលមានសមត្ថភាព និងឆន្ទៈក្នុងការបម្រើផលប្រយោជន៍សាធារណៈ អោយមកទទួលបន្ទុកភារកិច្ច ដើម្បីធានាអោយបាននូវការអនុវត្តពីនីតិវិធីមួយទៅនីតិវិធីមួយ ប្រកបដោយប្រសិទ្ធិភាព និងយុត្តិធម៌។
- អាណាព្យាបាល អ្នកថែទាំ ជាពិសេស ឪពុកម្តាយអនីតិជនគួរតែចំណាយពេលវេលាខ្លះជាមួយកូន ដើម្បីអប់រំ និងទូន្មានពាក់ពន្ធ័ជាមួយបុត្រធីតារបស់ខ្លួនបញ្ហាគតិយុត្តិ ដល់បុត្រធីតារបស់ខ្លួនឲ្យបានយល់នូវផលប៉ះពាល់ និងទោសទណ្ឌ ដែលបណ្តាលមកពីបទឃាតកម្ម ៕

# ឯកសារពិគ្រោះ

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាតិ

១ ) រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២ ) ក្រមនីតិវិធីព្រហ្មទណ្ឌ,នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧

៣ ) ក្រមព្រហ្មទណ្ឌ ,នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

៤ ) ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ

១ ) សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័តនៅថ្ងៃទី ១០ ធ្នូ ១៩៤៨

២ )អនុសញ្ញាស្តីពីសិទ្ធិកុមារ ចូលជាធរមាននៅថ្ងៃទី ២ កញ្ញា ១៩៩០

## សៀវភៅ

១ )សៀវភៅ ឧក្រិដ្ឋនិច្ច័យ របស់សាស្ត្រាចារ្យបណ្ឌិត ឯក ឆេងហួត ឆ្នាំ២០០៦

២ )សៀវភៅ នីតិភស្តុតាង របស់លោក អ៊ុន បូផា ឆ្នាំ២០១៦

៣ )សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌរបស់ក្រសួងយុត្តិធម៌ បោះពុម្ពខែកុម្ភៈ ឆ្នាំ២០០៦

## ព័ត៌មាន

១ ) http://www.phnompenhpost.com/national/suspect-detained-rape-murder-kampot-teen ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦

២ ) http://www.phnompenhpost.com/national/third-suspect-held-kampot-murder ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦

៣ ) https://www.khmerload.com/news/39944

៤ )https://www.cambodianchildrensfund.org/news/child-protection-unit-despite-confession-girls-murder-still-a-mystery-phnom-penh-post/ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥

៥ ) http://khmeread.com/posts/5884 ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦

៦ ) https://www.khmerload.com/news/40186

៧ ) http://m.phnompenhpost.com/national/girl-14-admits-killing-child-4 ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៥

៨ ) http://www.phnompenhpost.com/national/teen-accused-triple-murder ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៦។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ១

# ព័ត៌មានទី ១

phnompenhpost.com

## Suspect detained in rape-murder of Kampot teen



Authorities investigate the site in a Kampot province rice filed where the body of a raped and murdered 14-year-old girl was found yesterday. CPU

21 Jan, 2016 Niem Chheng

A teenage suspect has been detained in the suspected rape and murder of a 14-year-old girl whose body was found in a rice field in Kampot province yesterday.

On Monday evening,ក្មេងស្រី "ខ"disappeared from her house in the Lboeuk commune of Chhouk district.

Yesterday morning "ខ"'s body was found a few hundred metres from her house, with severe injuries to her neck, face and jaw. According to លោក "ច" director of the Phnom Penh-based Child Protection Unit, a witness heard a scream in the distance around the time "ខ" disappeared, but thought nothing of it.

"ខ" disappearance went unreported because her family believed her to be staying at a friend's house.

“We can conclude this is a rape-murder case because the victim's underwear was taken off,” said លោក "ស" , technical office chief at the Kampot police department.

Deputy Chhouk district police chief លោក "ហ" said that the death was likely “not a robbery because the victim is poor”.

Commune police detained a 17-year-old neighbour in connection with the case yesterday after finding one of his shoes 70 metres from the crime scene, said លោក "ផ" , Lboeuk commune police chief.

The teen is being temporarily detained at the commune police station.

Rights group Adhoc said ក្មេងស្រី "ខ"'s case was the fourth underage rape incident reported this month in Kampot province.

Police have apprehended a third suspect in the case of the suspected rape and murder of a 14-year-old girl in Kampot province, and have also found what they believe to be a second murder weapon.

phnompenhpost.com

The first suspect, a 17-year-old boy, was brought in by police that day for questioning. Two days later police in Phnom Penh apprehended a second teenage suspect. According to Kampot deputy police chief លោក "អ" both boys have been released.

The new suspect, identified as 24-year-old លោក "គ" was arrested on Saturday at 9am. He was found inside his house, located only 15 metres from the victim's residence, where he lives with his wife and child, according to Lboeuk commune police chief លោក "ផ"

លោក "ផ" said Kampot police had told him that they were “almost 100 per cent sure” this suspect was the killer.

Though the suspect has denied killing the girl, investigators found “blood on his collar and some scratches on his face and neck”, said Kampot deputy police chief លោក "អ"

“We will send him to the provincial court on Monday to charge him with rape and murder,” he added.

According to Lboeuk commune police chief លោក "ផ" villagers told investigators that they had witnessed the suspect involved in an argument with the victim on the night of her disappearance in which the victim allegedly remarked that the suspect had “an ugly face; no one loves you”, to which the suspect allegedly replied, “Wait and see.”

phnompenhpost.com

A fisherman who was out in the rice field that night told investigators that around 8pm he heard a ruffling in the distance. When he pointed his torch towards the noise, he saw a man running from a woman lying down in the brush. He thought he was witnessing a pair of hiding, spooked lovers, he said.

លោក "ច" director of the Phnom Penh-based Child Protection Unit, which has been assisting Kampot police in the investigation, said that a new suspected weapon found at the crime scene on Saturday, a 10-centimetre wooden plank, had been ripped off from the suspect's own fence. “It fit like a glove” on the fence, he said.

Another suspected weapon, a bloodied palm frond, had been found on Wednesday.

The blood found on the new suspect's clothes would be sent to Vietnam for DNA testing, he added.

*Additional reporting by Niem Chheng*

# ព័ត៌មានទី ២

khmerload.com

សង្គម

## សមត្ថកិច្ចពិនិត្យឃើញ ស្នាមវាយ និងច្របាច់ក លើរាងកាយ សពនារីម្នាក់ ដែលគេរុំអង្រឹង ប្លុងចោល ក្នុងដីឡូត៍

សម្លាប់ស្រ្តីម្នាក់ ច្រកក្នុងអង្រឹង យកទៅបោះចោល នៅខាងលិច វត្តអង្គតាមិញ សមត្ថកិច្ច អំពាវនាវរកសាច់ញាតិ

ភ្នំពេញ : ស្រ្តីម្នាក់អាយុជាង ៣០ឆ្នាំ មិនស្គាល់អត្តសញ្ញាណនៅឡើយនោះ ត្រូវបានឃាតក វាយសម្លាប់ ហើយយកសពខ្ចប់ដោយអង្រឹង ទាំងអាក្រាតកាយ រួចយកទៅបោះចោល នៅក្នុងដីឡូត៍មួយកន្លែង ស្ថិតនៅខាងលិច វត្តអង្គតាមិញ ភូមិតាពាំងល្វា សង្កាត់កកាប ខណ្ឌពោធិសែនជ័យ បង្កអោយមានការភ្ញាក់ផ្អើល ដល់ប្រជាពលរដ្ឋ និងសមត្ថកិច្ច កាលពីព្រឹកព្រលឹមថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៥នេះ។

លោក "ឃ" អធិការនគរបាលខណ្ឌពោធិសែនជ័យ បានបញ្ជាក់ថា រហូតមកដល់រសៀលថ្ងៃដដែលនេះ អត្តសញ្ញាណជនរងគ្រោះ នៅមិនទាន់ស្គាល់នៅឡើយទេ ដោយកំពុងស្វែងរកសាច់ញាតិ ហើយជនរងគ្រោះអាចជាកម្មករសំណង់។

លោក "ឃ" បានបញ្ជាក់ទៀតថា ស្រ្តីរងគ្រោះ អាចត្រូវឃាតក រំលោភហើយសម្លាប់ រួចយកមកបោះចោលនៅទីនេះ ប៉ុន្តែត្រូវរង់ចាំ ការពិនិត្យ និងធ្វើកោសល្យវិច័យ ទឹកកាមជាមុនសិន ពីមន្ទ្រី និងគ្រូពេទ្យជំនាញ។

រាជធានីភ្នំពេញ ៖ សេចក្តីរាយការណ៍បានឱ្យដឹងថា សពស្រ្តីម្នាក់ដែលគេសម្លាប់រួច រុំនឹងអង្រឹងប្លុងចោលក្នុងដីឡូត៍ជិតភ្លិបផ្កាយផត ត្រូវបានសមត្ថកិច្ចពិនិត្យ ធ្វើកោសល្យវិច័យ ឃើញមាន ស្នាមបែកមាត់ ស្នាមច្របាច់ក និងស្នាមខាំនៅលើកំភួនដៃស្តាំ។

សពនេះត្រូវគេសង្ស័យថា ជានារីបម្រើការ នៅហាងខារ៉ាអូខេ ឬកោសជប់ណាមួយក្បែរៗ កន្លែងកើតហេតុ។

ប្រភពពីកន្លែងកើតហេតុបានសង្ស័យថា ឃាតករសម្លាប់ស្រ្តីរងគ្រោះអាចជាមនុស្សស្រីដូចគ្នា ហើយមានទំនាស់គ្នាក្នុងកន្លែងធ្វើការ។

# ព័ត៌មានទី ៣

cambodianchildrensfund.org

## Child Protection Unit: 'Despite confession, girl's murder still a mystery', Phnom Penh Post

NOVEMBER 17, 2015

Read the full article here

*In the aftermath of the horrific murder of a nine-year-old* ក្មេងស្រី "ល" *in Kandal province's Tomloup Kpos Cheung village, questions remain unanswered*

Sitting beneath her stilt home in Kandal province's Tomloup Kpos Cheung village this week, អ្នកស្រី "ស" appeared more angry than sad. Only days earlier, her 9-year-old daughter, "ល", had been found strangled to death in a rice paddy nearby.

After police arrested her neighbour ឈ្មោះ "ល" 16, the teenager admitted to killing the girl for her gold earrings and a ring, which she sold at a nearby market for $28.

"When I think about her doing that to my daughter, I want to kill her," "ស" 32, spat, her two-year-old son nuzzling at her side, whining for attention. "But I cannot do it because I need to respect the law.

cambodianchildrensfund.org

"At the same time, if the police didn't come on time to arrest her, maybe my family and the other villagers would have tortured her to death."

According to police, ក្មេងស្រី "ល" went missing last Friday afternoon. ឈ្មោះ "ភ" even helped with the search, but after the little girl's body was found about 7pm the next day, she hid in a field. She was found and arrested later that night.

With a confession and an obvious motive identified, it seems like case closed. And yet the larger question of how an apparently ordinary young woman could commit such a horrific act for such a petty reason remains largely unanswered.

According to village chief , 71, crime had never been an issue before in Tomloup Kpos Cheung, located just west of Phnom Penh off National Highway 4, an area where, despite the semi-rural setting, the majority of women work in nearby garment factories and the men in construction. The village is neither particularly rich nor particularly poor.

"In the morning, the villagers go to work and come back in the evening," said, her voice nearly drowned out by workers putting up a solid metal fence around her yard. "They never get jealous with each other, because if they want something, they just save up for it. This is the first murder ever in the village that I know of."

# ព័ត៌មានទី ៤

KhmeRead MENU ≡

## ឃាត់យុវជនម្នាក់តាមដីកាពីបទឃាតកម្ម

សង្គម | April 26, 2016 09:19AM | 0

ក- ក ក+

ត្បូងឃ្មុំ ៖ បុរសម្នាក់ត្រូវបានប៉ូលិសស្រុកពញាក្រែកឃាត់ខ្លួននៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ តាមដីកាតុលាការខេត្តកំពង់ចាមពីបទឃាតកម្មកាលពីឆ្នាំ២០១១មកម្ល៉េះ។

ប៉ូលិសនិយាយថា កម្លាំងជំនាញនៃអធិការដ្ឋានប៉ូលិសស្រុកពញាក្រែក បានឃាត់ខ្លួនឈ្មោះ "ត" ហៅ "គ" ភេទប្រុស អាយុ១៧ឆ្នាំ ដោយ ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៦៨ ចុះថ្ងៃទី ២៤/០៤/២០១៣ របស់លោក "ស" ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម ក្នុងករណីឃាតកម្ម ប្រព្រឹត្តនៅភូមិត្រាចខោល ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក នៅថ្ងៃទី០៩ ឆ្នាំ២០១១។

បច្ចុប្បន្ន ជនល្មើសកំពុងឃាតខ្លួននៅអធិការដ្ឋាននគរបាលស្រុកពញាក្រែក និងកំពុងបំពេញនីតិវិធីបញ្ជូនទៅតុលាការ។

# ព័ត៌មានទី ៥

khmerload.com

## ឃុំខ្លួនយុវជន៦នាក់ ពាក់ព័ន្ធករណី ចាប់រំលោភសេពសន្ថវៈ ប្ញកស្រ្តីម្នាក់ រួចសម្លាប់យក សពរុំក្នុងអង្រឹង ទៅបោះចោលនៅ ក្នុងដីទុំឡូត៍ មួយកន្លែង ក្បែរវត្តអង្គតាមិញ

351
SHARE

Share

ភ្នំពេញ ៖ ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃច័ន្ទ ទី ៣ ខែ សីហា ឆ្នាំ ២០១៥ បានចេញដីកាឃុំខ្លួន យុវជន ជាប់ចោទជន ៦នាក់ ពីបទ « ឃាតកម្ម ដោយមាន ទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ» តាម មាត្រា២០៥ នៃក្រមព្រហ្មទណ្ឌ ជាប់ពាក់ព័ន្ធនឹង ករណីចាប់រំលភសេព សន្ថវៈប្ញកស្រ្តីម្នាក់ បានសម្រេចម្នាក់ម្តងៗ រួចសម្លាប់ នាងចោល យកសពរុំ ក្នុងអង្រឹង ទៅបោះចោលនៅ ក្នុងដីឡូត៍មួយកន្លែង ក្បែរវត្តអង្គតាមិញ ស្ថិតនៅក្នុង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ កាលសប្តាហ៍មុន។

khmerload.com

មន្រ្តីនគរបាល ខណ្ឌពោធិ៍សែនជ័យ បានឲ្យដឹងថា ជនត្រូវចោទទាំង ៦នាក់នេះ មានឈ្មោះ ទី១ ឈ្មោះ "ណ" អាយុ២៩ឆ្នាំ មុខរបរកម្មករ សំណង់ , ទី២ ឈ្មោះ "ឡ" , អាយុ២០ឆ្នាំ, ទី ៣ ឈ្មោះ "ស" អាយុ១៧ឆ្នាំ, ទី៤ ឈ្មោះ "ល" អាយុ១៩ឆ្នាំ, ទី៥ ឈ្មោះ "ខ" អាយុ២០ឆ្នាំ និង ទី ៦ ឈ្មោះ "ម" អាយុ២០ឆ្នាំ។ ជនសង្ស័យ ទាំង ៦នាក់នេះ គឺ ជាកម្មករសំណង់ និងស្នាក់នៅក្នុងការដ្ឋានសំណង់ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ។

ជនសង្ស័យខាងលើ អាចប្រឈមនឹងការជាប់ពន្ធនាគារអស់មួយជីវិត ប្រសិន បើតុលាការ រកឃើញ ពីពិរុទ្ធភាព របស់ពួកគេ ដូចការ ចោទប្រកាន់នោះ៕



# ព័ត៌មានទី ៦

phnompenhpost.com

phnompenhpost.com

## Girl, 14, admits killing child, 4



Police and members of the Child Protection Unit inspect a waterway in Kampong Speu's Samrong Tong district over the weekend after a young girl's body was found. PHOTO SUPPLIED

5 Jan, 2015 Sean Teehan and Kim Sarom

A 14-year-old in Kampong Speu has reportedly confessed to drowning her 4-year-old relative in order to steal and sell the victim's gold earrings and buy a new mobile phone, according to officials.

At about 2pm on Saturday, the suspect, the teenage girl used sugarcane to lure , 4, to a small dam in Samrong Tong district's Krang Svay village, said លោក "ក" operations manager at the Phnom Penh-based Child Protection Unit, which investigates violence against children.

The teen reportedly confessed to drowning the child in the water, placing rocks on her body to keep her down and stealing her earrings, which she sold at a local market for $20.50, according to 'លោក "ក" who said the suspect then purchased a $19 Nokia mobile about 50 metres from the victim's home.

"I am a bit shocked that it was a female offender and that the offender was only 14 years old," លោក "ក" said yesterday

The victim was a distant cousin of the suspect. said Samrong Tong district Police Chief លោក "ខ"

The suspect has been sent to the provincial court and will likely be charged today, លោក "ខ" said.

"It is obvious it is a murder case, and it was intentional."

CPU officials, who were alerted to the alleged drowning late on Saturday night, arrived on the scene at about 5am, លោក "ក" said. He praised local authorities in their investigation, which produced evidence including the victim's earrings, the clothes the suspect wore at the time of the incident and the phone she purchased.

Along with a confession, the suspect demonstrated how she carried out the gruesome killing on video for authorities, លោក "ក" said.

In Cambodia, the minimum age of "criminal responsibility" is 14; given the evidence, the provincial court will probably charge the suspect with intentional murder, said legal expert and lawyer លោក "ឃ"

Because she is a minor, the teen will likely receive a lesser penalty than an adult who committed the same crime.

"If her age is 14, it means she's reached the age of criminal responsibility … [but would likely receive a sentence] half of what an adult would," លោក "ឃ" said.

The penalty for intentional murder in the Kingdom is 10 to 15 years of imprisonment, លោក "ឃ" said. The suspect would likely face five to seven-and-a-half years if convicted.

The age of the suspect and alleged brutal nature of the crime surprised លោក "ឃ", he said.

"I do not see similar cases like that … [with seemingly] no mitigating circumstances."

The age of the suspect and alleged brutal nature of the crime surprised Sam Oeun, he said.

"I do not see similar cases like that … [with seemingly] no mitigating circumstances."

In 2014 there were 221 cases in 17 provinces involving serious crimes – including rape and murder – where the victim was under 15, លោក "ក" said.

លោក "វ", a judge at Kampong Speu Court, said the girl had been placed in the care of an NGO for an indeterminate period.

"She cannot be at her home because the family is afraid that she might hurt someone else," he said. "As I know, the 12-year-old girl used drugs with other people according to a urine sample."



The killer's family still lives in the village – a place as nondescript and ordinary as Tomloup Kpos Cheung – and while the relationship between them and the family of the victim is still tense – their houses are within eyesight of each other – they ignore each other if they meet in the street or pagoda.

អ្នកស្រី "ហ" the 58-year-old grandmother of the four-year-old victim, this week told Post Weekend that the child who murdered កុមារ "ឈ" had seemed normal,

"When the authorities checked her urine, they said she used drugs," she said. "I never saw her using it, and I am not sure whether it is true or not."

អ្នកស្រី "ហ" was more interested in being properly financially compensated; the family had received $2,000, she said, but it was not enough.

"I told the court 'I won't accept even $10,000 for compensation because it could not buy her life back' when I was really angry, but now I don't want to make problems, so if they pay us $10,000, I will accept it."

She said the family now didn't even care whether the girl was locked up or not.

"It doesn't matter whether she's in jail or not – we just want compensation. If they release her, the murderer can do whatever she wants to," she said.

# ព័ត៌មានទី ៧



## Teen accused of triple murder



Suspect ( sits on the ground on Saturday night after he was arrested in Siem Reap's Angkor Chum district for his alleged involvement in a triple murder. Photo supplied

4 Jan, 2016 Pech Sotheary and Jamie Elliott

Three boys were savagely hacked to death by a teenager in an apparent fit of jealousy in Siem Reap province on Saturday, according to police.

ក្មួងប្រុស "ស", 8, ក្មេងប្រុស "ម" 13, and ក្មេងប្រុស "គ" 16, were attacked with a scythe in a cassava field in Angkor Chum district's Kok Doung commune after they were knocked from their motorbike, according to លោក "ក" , director of the National Police's Child Protection Unit.

phnompenhpost.com

"Between 12pm and 12:30pm yesterday, while riding a motorcycle on a provincial dirt track, three young males were confronted by the offender who was armed with a long machete-type weapon and attacked them, causing the motorcycle to crash," លោក "ក" said. "The offender continued his attack on the heads of the victims, causing all three fatal head injuries as well as defensive injuries."

The alleged killer, who fled the murder scene on the motorbike his victims had been riding, was arrested later that day.

"About five hours after the incident, authorities arrested the suspect, ជនសង្ស័យ "ច" 17, at Kok Doung village, Kok Doung commune," said Angkor Chum district police chief, លោក "ភ"

He added that two of the victims died at the murder scene, while a third succumbed to his injuries on the way to hospital.

The oldest of the murdered boys was the target of the attack, according to លោក "ក" who added that "ច" had made a full confession.

"The suspect has told police that a few days ago he saw the victim riding his moto with a girl, and that this is one of the reasons he carried out the attack," McCabe said.

ជនសង្ស័យ "ច" also reportedly admitting to killing the younger victims because they were potential witnesses of the crime.

"The younger boys knew the suspect, and were simply in the wrong place at the wrong time," លោក "ក" added.

In addition to a possible love triangle, there was a history of antipathy between the older victim and his alleged murderer, who are both from Kok Doung village.

"The oldest victim and the offender had been working in Thailand in late 2014, and knew each other there," លោក "ក" said.

"The victim came back to Cambodia, to get away from the offender, because the pair had problems with each other in Thailand."

Police were able to take DNA samples from blood on the murder weapon, blood stains on the suspect's shirt and from the victims themselves, លោក "ក" added.

Deputy provincial police chief លោក "វ" said that documents were being prepared for ( "ច") to appear in court today to be charged with premeditated murder and robbery.



# ឧបសម្ព័ន្ធទី ២